សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាល តាមប្រព័ន្ធអេឡិចត្រូនិចនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ទេព សុខសាវនា**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **សឿន សោភ័ណ**

ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ
ជំនាន់ទី ១០ (អាហារូបករណ៍)

ឆ្នាំចូលរៀន ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ទេព សុខសាធនា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ ឆ្នាំទី៤ ជំនាន់ទី១០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៣-២០១៧។

សូមឧទ្ទិសស្នាដៃនេះជូនដល់វិញ្ញាណក្ខន្ធ លោកពុក **ទេព លក្ខិណា** និងសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះព្រះកន្លោងគឺអ្នកម៉ែ **ញ៉ែប វណ្ណា** ដែលបានផ្តល់កំណើតដល់រូបខ្ញុំបាទ ចិញ្ចឹមបីបាច់ថ្នាក់ថ្នមថែរក្សា ហើយក្នុងនោះក៏មានលោកតា **ឃី សួន** លោកយាយ **ឡេីន ញឹក** លោកពុក **ញឹម ស៊ីខ** និងលោកយាយ លោកតាអ៊ីពូមីងទាំងអស់ ដែលតស៊ូប្រឹងប្រែងទាំងយប់ថ្ងៃ ហូរញើស ស្រក់ឈាម ក៏ដើម្បីធ្វើជាអាណាព្យាបាលដ៏សែនកក់ក្តៅក្នុងការផ្គត់ផ្គង់ការរស់នៅ ការសិក្សារៀនសូត្រ អប់រំទូន្មានប្រៀនប្រដៅឱ្យមានព្រហ្មវិហារធម៌ ដឹងគុណ និងមានសីលធម៌ល្អក្នុងការរស់នៅ ជាពិសេសជំរុញឱ្យរូបខ្ញុំបាទមានឱកាសទទួលបានការអប់រំ ដែលជាទ្រព្យសម្បត្តិដ៏មហាសាលមិនអាចកាត់ថ្លៃបាន។

សូមឧទ្ទិសស្នាដៃនេះជូនដល់វិញ្ញាណក្ខន្ធ **សម្តេចវិបុលបញ្ញា សុខ អាន** និងថ្លែងអំណរគុណយ៉ាង ជ្រាលជ្រៅបំផុតចំពោះ **លោកជំទាវ** ដែលលោកទាំងពីរបានផ្តល់អាហារូបករណ៍សិក្សាដោយឥតបង់ថ្លៃ ថ្នាក់បរិញ្ញាបត្រដ៏មានតម្លៃនេះដល់រូបខ្ញុំបាទ។ ខ្ញុំបាទមានតែឧទ្ទិសបួងសួងវត្ថុស័ក្តិសិទ្ធិក្នុងលោកតាមថែរក្សា ដួងវិញ្ញាណក្ខន្ធ **សម្តេចវិបុលបញ្ញា** ឱ្យបានដល់ឋានសុគតិភព និងសូមទេវតា តេជៈបារមីទាំងឡាយតាមថែរក្សា **លោកជំទាវ** បុត្រាបុត្រី ចៅប្រុសចៅស្រី មានសុខភាពល្អ និងបន្តដឹកនាំស្ថាប័ន អង្គភាព និងសង្គមជាតិឱ្យរីកចម្រើនជានិច្ចនិរន្តរ៍។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណដល់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោកគ្រូ-អ្នកគ្រូ សាស្រ្តាចារ្យ និងបុគ្គលិកទាំងអស់ ដែលបានគ្រប់គ្រង ដឹកនាំ បង្ហាត់បង្ហាញ អប់រំណែនាំ បង្រៀនទាំងផ្នែកទ្រឹស្តី និងការអនុវត្តផ្ទាល់ ជាពិសេសផ្តល់ដំបូន្មានល្អៗទាំងការរស់នៅក្នុងសង្គមឱ្យមានតម្លៃដល់រូបខ្ញុំបាទ និងនិស្សិតគ្រប់រូប ប្រកបដោយបទពិសោធន៍ ការទទួលខុសត្រូវខ្ពស់ ក្នុងគោលដៅដើម្បីអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់អនាគតកាន់តែប្រសើររបស់ប្រទេសកម្ពុជា។ ជាមួយគ្នានេះដែរខ្ញុំបាទសូមគោរពដឹងគុណនិងថ្លែងអំណរគុណជាពិសេសដល់ លោកគ្រូសាស្រ្តាចារ្យ **បណ្ឌិត សឿន សោភ័ណ** ដែលលោកបានចំណាយពេលដ៏មានតម្លៃពីការងារជាសាកលវិទ្យាធិការរង ការងារជាសាស្រ្តាចារ្យ ការងារជាមេគ្រួសារ និងការងារដ៏មានសារៈសំខាន់ដទៃទៀត ដើម្បីផ្តល់នូវការណែនាំ គន្លឹះសិក្សាស្រាវជ្រាវ មតិយោបល់កែលម្អសំខាន់ៗ ហើយលោកសាស្រ្តាចារ្យបានចូលរួមយ៉ាងធំធេងក្នុងកិច្ចការអប់រំ ជាពិសេសកិច្ចការស្រាវជ្រាវ និងចងក្រងសារណាដ៏ប្រសើរមួយនេះឡើង។

ជាមួយគ្នានេះដែរ ខ្ញុំបាទក៏សូមដឹងគុណ និងអរគុណដល់បងប្រុស បងស្រី រួមក្រុមការងារ និងមិត្តភក្តិទាំងអស់ ដែលតែងតែលើកទឹកចិត្ត ផ្តល់ជំនួយគ្រប់ផ្នែក ទាំងស្មារតី និងឯកសារពិគ្រោះនានាតាមគ្រប់មធ្យោបាយ និងលទ្ធភាព។ ខ្ញុំបាទក៏សូមគោរពដឹងគុណយ៉ាងធំធេងដល់បុព្វបុរស ដូនតា ថ្នាក់ដឹកនាំគ្រប់ជំនាន់ ដែលបានធ្វើពលិកម្មដើម្បីប្រទេសជាតិ និងបន្សល់ទុកនូវមរតកជាប្រវត្តិសាស្រ្តយ៉ាងច្រើនដល់កូនចៅជំនាន់ក្រោយ ជាពិសេសថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នាពេលបច្ចុប្បន្នដែលបានលះបង់ដើម្បីសុខសន្តិភាព និងផ្តល់នូវការអភិវឌ្ឍន៍រីកចម្រើនឥតឈប់ឈរ។

សូមឧទ្ទិសកុសលជូន **លោកពុក** និងសូមគោរពជូនពរលោកអ្នកមានគុណគ្រប់រូបប្រកបដោយសេចក្តីសុខសុភមង្គល ចម្រុងចម្រើន ទទួលបាននូវសុខភាពល្អ ដើម្បីបន្តចិញ្ចឹមបីបាច់ថែរក្សា អប់រំ និងផ្តល់ចំណេះដឹង ដល់កូនចៅ និស្សិត យុវជនជំនាន់ក្រោយៗទៀត។

# អារម្ភកថា

ប្រធានបទស្តីអំពី ការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធអេឡិចត្រូនិចនៅកម្ពុជា ដែលបាននឹងកំពុងបង្ហាញវត្តមាននេះ ជាកិច្ចការសំខាន់មួយដោយបានលើកយកពីដំណើរការ និងការប្រព្រឹត្តទៅរបស់បច្ចេកវិទ្យានាសតវត្សរ៍ទី២១ ស្របពេលដែលនេះជាសម័យកាលនៃបច្ចេកវិទ្យាកំពុងរីករាលដាលពេញសកលលោក។ ភាពជឿនលឿន និងការអភិវឌ្ឍរបស់ប្រទេសមួយ ដរាបណាបានដើរតាមទាន់នូវរបត់បច្ចេកវិទ្យាថ្មីៗដោយធ្វើដំណើរទន្ទឹមគ្នាទាំងវិស័យឯកជន និងវិស័យកិច្ចការសាធារណៈរបស់រដ្ឋ។ ចំណុចរសើបទាំងនេះហើយ ដែលបណ្តាលចិត្តរបស់ខ្ញុំបាទឱ្យធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងសារណា ក្រោមប្រធានបទនេះឡើង ដោយការយកចិត្តទុកដាក់ខ្ពស់ដើម្បីបង្ហាញពីសមត្ថភាពរបស់បច្ចេកវិទ្យា នៅក្នុងកិច្ចការបម្រើវិស័យសាធារណៈនៅកម្ពុជាដែលបាននឹងកំពុងអនុវត្តព្រមទាំងចក្ខុវិស័យអភិវឌ្ឍខ្លួនរបស់ រដ្ឋបាលទំនើបកម្ពុជា ឱ្យកាន់តែប្រសើរឡើងបន្ថែមទៀតដូចនឹងប្រទេសអភិវឌ្ឍក្នុងតំបន់ក៏ដូចជាពិភពលោកទាំងមូល។

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ពិតជាបានផ្តល់នូវគុណតម្លៃយ៉ាងច្រើន និងជួយផ្តល់ឱកាសដល់រូបខ្ញុំបាទបានទទួលនូវពុទ្ធិចំណេះដឹងថ្មីៗ បទពិសោធន៍ល្អៗ ដែលកើតចេញពីខិតខំប្រឹងប្រែង និងការទទួលបានការឧបត្ថម្ភគាំទ្រគ្រប់រូបភាពពី លោកគ្រូ-អ្នកគ្រូ បងៗក្រុមការងារ និងមិត្តភក្តិ ជាពិសេសលោកគ្រូសាស្ត្រាចារ្យដឹកនាំផ្ទាល់។ ជាមួយគ្នាដែរកិច្ចការនេះបានផ្សារភ្ជាប់ទំនាក់ទំនងសង្គមជាមួយមជ្ឈដ្ឋានខាងក្រៅកាន់តែច្រើន ជាពិសេសជាមួយស្ថាប័នពាក់ព័ន្ធដោយវាត្រូវបានលាតត្រដាងពីស្ថានភាពថ្មីនៃ ដំណើរការអនុវត្តតាមប្រព័ន្ធអេឡិចត្រូនិច នៅក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ន។

ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា សារណានេះ នឹងក្លាយជាឯកសារពិគ្រោះស្មារតី និងស្រាវជ្រាវសម្រាប់ការអភិវឌ្ឍក្នុងការគ្រប់គ្រងរដ្ឋបាលទំនើបនៅកម្ពុជា និងជាពិសេសសម្រាប់មិត្តភក្តិនិស្សិតក៏ដូចជាអ្នកសិក្សាស្រាវជ្រាវគ្រប់រូបបានស្វែងយល់បន្ថែមដើម្បីចូលរួមពង្រឹង និងពង្រីកការរីកចម្រើនរបស់សង្គមកម្ពុជានាពេលបច្ចុប្បន្នជាមួយនឹងបច្ចេកវិទ្យាថ្មី។

ជាមួយគ្នានេះដែរ ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយជានិច្ចក្នុងការទទួលយកនូវមតិយោបល់រិះគន់ ដើម្បីស្ថាបនាក្នុងគោលបំណងកែលម្អកិច្ចការស្រាវជ្រាវនេះ ជាពិសេសដើម្បីចូលរួមអភិវឌ្ឍគំនិតថ្មីៗជុំវិញប្រធានបទនេះឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម ............................................................ ១**

**ជំពូកទី១៖ អភិបាលកិច្ច និងប្រព័ន្ធអេឡិចត្រូនិច ............................ ៤**

១.១. អំពីអភិបាលកិច្ច ........................................................ ៤

១.១.១. គោលបំណងនៃអភិបាលកិច្ច ........................................... ៥

១.១.២. តួអង្គសំខាន់ៗក្នុងអភិបាលកិច្ច ......................................... ៦

១.១.៣. ចក្ខុវិស័យជាយុទ្ធសាស្រ្ត ................................................ ៦

១.២. អំពីប្រព័ន្ធអេឡិចត្រូនិច (E-Governance) .................................. ៧

១.២.១. និយមន័យ ............................................................ ៧

១.២.២. គោលបំណង .......................................................... ៨

១.២.៣. អត្ថប្រយោជន៍ ........................................................ ១០

**ជំពូកទី២៖ ការអនុវត្តប្រព័ន្ធអេឡិចត្រូនិចនៅកម្ពុជា ........................ ១២**

២.១. វត្តមានប្រព័ន្ធអេឡិចត្រូនិចនៅកម្ពុជា ........................................ ១២

២.១.១. អំពីប្រវត្តិ ............................................................ ១៣

២.១.២. អំពីការអនុវត្ត ........................................................ ១៨

២.២. ចក្ខុវិស័យរបស់កម្ពុជា ..................................................... ២៥

**ជំពូកទី៣៖ ការវិភាគលើរបកគំហើញនៃការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច....២៩**

៣.១. លទ្ធផលនៃការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច .................................. ២៩

៣.២. ឧបសគ្គនៃការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច..................................... ៣១

៣.៣. ដំណោះស្រាយនៃការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច ............................ ៣៣

**សេចក្តីសន្និដ្ឋាន.......................................................... ៤០**

**អនុសាសន៍............................................................... ៤២**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

## ១- លំនាំបញ្ហា

សតវត្សរ៍ទី២១ ជាយុគសម័យដែលត្រូវបានជ្រាតចូលនូវបច្ចេកវិទ្យាទំនើបៗ ដោយមិនអាចប្រកែកបាននៅពាសពេញពិភពលោក ដែលនេះក៏អាស្រ័យទៅលើប្រទេសនីមួយៗអាចបត់បែនទាន់អ្វីដែលជាភាពថ្មីរបស់សកលបានកម្រិតណាដែរ។ ប្រទេសកម្ពុជា ដែលយើងដឹងថាជាប្រទេសកំពុងអភិវឌ្ឍ ក៏មានរបត់មួយទៅតាមបច្ចេកវិទ្យាសម័យថ្មី ហើយមានលក្ខណៈប្រសើរឡើងជាបន្តបន្ទាប់ជាមួយនូវការប្រើប្រាស់កើនឡើងឥតឈប់ឈរនូវបច្ចេកវិទ្យាទំនើបលើគ្រប់វិស័យ។ ជាមួយគ្នានេះដែរ ការងារគ្រប់គ្រងរដ្ឋបាល និងអភិបាលកិច្ចនៅកម្ពុជាបច្ចុប្បន្ន បាននឹងកំពុងដាក់បញ្ចូលឱ្យអនុវត្តតាមរយៈប្រព័ន្ធអេឡិចត្រូនិចភាគច្រើននៅតាមស្ថាប័ននានាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ប្រការនេះជាចំណុចដែលកម្ពុជាបានចាប់ផ្ដើម និងបន្តអនុវត្តក្នុងទស្សនៈវិស័យជាវិជ្ជមានមួយដើម្បីជំរុញ និងគាំទ្រដំណើរការនៃការគ្រប់គ្រងធនធានមនុស្ស ចាត់ចែង គ្រប់គ្រងបញ្ហា និងធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលហើយឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍របស់សង្គមជាតិទាំងមូល។

ការគ្រប់គ្រង ដឹកនាំ ដោយរួមបញ្ចូលការប្រើប្រាស់តាមប្រព័ន្ធអេឡិចត្រូនិច ដែលប្រទេសជឿនលឿននានាបានអនុវត្តនិងទទួលបានជោគជ័យនោះ វាមានកត្តារួមផ្សំជាច្រើនទាំងបច្ចេកទេស ធនធានមនុស្ស ហិរញ្ញវត្ថុ ស្ថានភាពសេដ្ឋកិច្ច នយោបាយជាដើម។ កត្តារួមផ្សំទាំងនេះហើយដែលកម្ពុជាបាននឹងកំពុងកែប្រែមុខមាត់របស់ខ្លួន និងអនុវត្តជាដំណាក់កាលក្នុងអភិបាលកិច្ចរដ្ឋបាលទំនើបរបស់ខ្លួន ព្រមទាំងបន្តស្វែងយល់លើបញ្ហាប្រឈមនានា ដែលរាំងស្ទះដល់ការអនុវត្តមិនទាន់បានពេញលេញ។ អភិបាលកិច្ចល្អ គឺជាបុរេលក្ខខណ្ឌសំខាន់បំផុតមួយដើម្បីធានាឱ្យមានការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយចីរភាពសមធម៌ និងយុត្តិធម៌ក្នុងសង្គម ទាំងនេះជាភាពត្រឹមត្រូវតាមគោលនយោបាយ ដែលជាលក្ខខណ្ឌចាំបាច់ដំបូងគេបំផុតនៃអភិបាលកិច្ចល្អ ហើយកិច្ចការងារនេះត្រូវបានផ្ដោតសំខាន់ទៅលើកត្តាគាំទ្ររបស់ប្រជាពលរដ្ឋភាគច្រើន ឬទាំងអស់ និងការបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋបានច្រើនបំផុត ឬទាំងអស់។ ករណីនេះបើសិនជារដ្ឋ ស្ថាប័ន ឬអង្គភាពមិនមានភាពត្រឹមត្រូវតាមគោលនយោបាយទេ នោះយើងមិនអាចនិយាយអំពីអភិបាលកិច្ចល្អបានឡើយ ហើយការអនុវត្តតាមប្រព័ន្ធអេឡិចត្រូនិចនេះក៏មិនអាចដំណើរការបានដែរ។

## ២- ចំណោទបញ្ហា

ការសិក្សាពីប្រធានបទខាងលើ អំពី ការគ្រប់គ្រងរដ្ឋបាល តាមប្រព័ន្ធអេឡិចត្រូនិចនៅកម្ពុជាបង្ហាញឱ្យឃើញនូវបញ្ហាចោទដូចខាងក្រោម៖

- តើការអនុវត្តប្រព័ន្ធអេឡិចត្រូនិចនៅប្រទេសកម្ពុជាបម្រើផលប្រយោជន៍ជាវិជ្ជមានអ្វីខ្លះដល់ប្រជាពលរដ្ឋ?
- តើស្ថាប័នណាខ្លះ ដែលបានប្រើប្រាស់ការគ្រប់គ្រងតាមប្រព័ន្ធអេឡិចត្រូនិច?
- តើប្រទេសកម្ពុជាជួបបញ្ហាប្រឈមអ្វីខ្លះក្នុងការអនុវត្តតាមប្រព័ន្ធអេឡិចត្រូនិច?
- តើកម្ពុជាមានចក្ខុវិស័យ និងបានត្រៀមខ្លួនដូចម្តេចខ្លះក្នុងការពង្រឹងនិងពង្រីកការអនុវត្តតាមប្រព័ន្ធអេឡិចត្រូនិចនេះ?

## ៣- គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះ គឺមានគោលបំណងលើកយកអំពីការអនុវត្តតាមបច្ចេកវិទ្យានៅកម្ពុជា ដែលនាំឱ្យមានភាពងាយស្រួល តម្លាភាព សមធម៌ និងយុត្តិធម៌សង្គម សិក្សាលើការអនុវត្តរបស់ស្ថាប័នពាក់ព័ន្ធនាពេលបច្ចុប្បន្ន ហើយនឹងចូលរួមចំណែកស្វែងយល់ពីបញ្ហាប្រឈមនានាដែល កើតមានឡើងលើការអនុវត្តតាមប្រព័ន្ធអេឡិចត្រូនិចក្នុងគោលដៅផ្សព្វផ្សាយ និងស្វែងរកដំណោះស្រាយដ៏សមស្របមួយ ដើម្បីកម្ពុជាមានភាពជឿនលឿន ក្នុងកិច្ចការងារបម្រើប្រយោជន៍សាធារណៈក៏ដូចជាវិស័យឯកជននានាផងដែរ។

## ៤- ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងកិច្ចការស្រាវជ្រាវលើប្រធានបទនេះ គឺសំដៅទៅលើការគ្រប់គ្រង និងអភិបាលកិច្ចតាមក្រសួង ស្ថាប័ន និងអង្គភាពមួយចំនួននៅប្រទេសកម្ពុជាដោយការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចដើម្បីសម្រួលការងារ និងបម្រើសេវាសាធារណៈបានទាន់ពេលវេលា តម្លាភាព និងឆ្លើយតបតាមតម្រូវការនានារបស់ប្រជាពលរដ្ឋ។ ឯកសារស្រាវជ្រាវនេះស្ថិតក្នុងក្របខណ្ឌពេលវេលាឆ្នាំ២០១៥។

## ៥- សារៈសំខាន់នៃការស្រាវជ្រាវ

លទ្ធផល ដែលទទួលបាននៃការស្រាវជ្រាវនេះ វាអាចជាចំណេះដឹង និងគោលការណ៍ក្នុងការចូលរួមចំណែកពង្រឹងស្មារតីនិស្សិត យុវជន និងអ្នកស្រាវជ្រាវគ្រប់រូបនូវសមត្ថភាពបច្ចេកវិទ្យាដែល ជាភាសាទំនាក់ទំនងថ្មីនាសម័យបច្ចុប្បន្ន ក្នុងគោលដៅចូលរួមអភិវឌ្ឍសង្គមជាតិទាំងមូល ហើយ សៀវភៅនេះនឹងអាចក្លាយឯកសារពិគ្រោះលើបញ្ហាប្រឈម ដើម្បីស្វែងរកដំណោះស្រាយដែល សមប្រកបក្នុងកិច្ចការអភិបាលកិច្ចទំនើបនេះផងដែរ។

## ៦- វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទ **ការគ្រប់គ្រងរដ្ឋបាល តាមប្រព័ន្ធអេឡិចត្រូនិច នៅកម្ពុជា** ដើម្បីស្វែងរកទិន្នន័យ និងប្រភពព័ត៌មានដែលមានស្រាប់មកធ្វើការចងក្រងជាសារណាដ៏ល្អប្រសើរនេះឡើង និងមានសកម្មភាពស្រាវជ្រាវជាច្រើនដូចជា៖

- នៅបណ្ណាល័យនៃសាកលវិទ្យាល័យនានា
- ប្រសាសន៍តាមព័ត៌មានពីថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- គេហទំព័រឯកជន និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា

## ៧- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

- សេចក្ដីផ្ដើម
- ជំពូកទី១៖ ជំពូកនេះនឹងលើកយកពីទ្រឹស្ដីអភិបាលកិច្ចមួយចំនួន និងគោលការណ៍ជារួមរបស់ប្រព័ន្ធបច្ចេកវិទ្យាអេឡិចត្រូនិច។
- ជំពូកទី២៖ ជំពូកនេះ គឺបង្ហាញពីការអនុវត្តតាមប្រព័ន្ធបច្ចេកវិទ្យាអេឡិចត្រូនិច តាមក្រសួងស្ថាប័ននានានៅកម្ពុជា និងបញ្ហាប្រឈមដែលបាននឹងកំពុងជួបប្រទះ ព្រមទាំងបង្ហាញអំពីចក្ខុវិស័យជាវិជ្ជមានរបស់កម្ពុជាក្នុងការពង្រឹងការអនុវត្តតាមអេឡិចត្រូនិច ឱ្យបានកាន់តែប្រសើរឡើងបន្ថែមទៀត។
- ជំពូកទី៣៖ ជំពូកនេះនឹងបង្ហាញពីការវិភាគលើរបកគំហើញនៃការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច នៅកម្ពុជា ដោយលើកយកពីលទ្ធផល ដែលបានអនុវត្តកន្លងមក ឧបសគ្គនានាក្នុងការធ្វើឱ្យរីកចម្រើនលើវិស័យនេះ និងដំណោះស្រាយជាវិជ្ជមានដែលនាំឱ្យមានភាពជឿនលឿន ។
- សេចក្ដីសន្និដ្ឋាន
- អនុសាសន៍
- ឯកសារយោង
- ឧបសម្ព័ន្ធ

# ជំពូកទី១
# អភិបាលកិច្ច និងប្រព័ន្ធអេឡិចត្រូនិច

អភិបាលកិច្ចល្អ ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជំរុញ និងគាំទ្រដំណើរការនៃការគ្រប់គ្រងធនធានរបស់ស្ថាប័ន អង្គភាព និងការអភិវឌ្ឍមួយប្រកបដោយនិរន្តរភាព។ អភិបាលកិច្ចដែលប្រកបដោយសុភវិនិច្ឆ័យ គឺជាអភិបាលកិច្ចល្អ ដោយការចាត់ចែង និងការគ្រប់គ្រងបញ្ហា និងធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព ហើយឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍របស់សង្គមជាតិទាំងមូល។ ភាពត្រឹមត្រូវតាមគោលនយោបាយ គឺជាលក្ខខណ្ឌចាំបាច់ដំបូងគេបំផុតនៃអភិបាលកិច្ចល្អ។ ភាពត្រឹមត្រូវតាមគោលនយោបាយ ត្រូវបានពិចារណាដោយផ្តោតជាសំខាន់ទៅលើកត្តាពីរយ៉ាងគឺ៖ ១) ការគាំទ្រដោយប្រជាពលរដ្ឋភាគច្រើនបំផុត ឬទាំងអស់ និង ២) ការបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋភាគច្រើនបំផុត ឬទាំងអស់។ បើរដ្ឋ ស្ថាប័ន ឬអង្គភាពមិនមានភាពត្រឹមត្រូវតាមគោលនយោបាយទេ នោះយើងមិនអាចនិយាយអំពីអភិបាលកិច្ចល្អបានឡើយ។

ដោយយល់ឃើញពីសារៈសំខាន់នៃអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថា **អភិបាលកិច្ចល្អ គឺជាបុរេលក្ខខណ្ឌសំខាន់បំផុតមួយ ដើម្បីធានាឱ្យមានការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយចីរភាពសមធម៌ និងយុត្តិធម៌ក្នុងសង្គម**។ ផ្អែកលើសារៈសំខាន់នៃអភិបាលកិច្ចល្អរាជរដ្ឋាភិបាល បាននឹងកំពុងបន្តអនុវត្តផែនការសកម្មភាពអភិបាលកិច្ចល្អ ដោយបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា និងបានបញ្ចូលគោលការណ៍នៃអភិបាលកិច្ចល្អទៅក្នុងក្របខ័ណ្ឌ នយោបាយ ច្បាប់ និងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍប្រទេសប្រកបដោយជោគជ័យ។

ជាមួយគ្នានេះដែរស្របពេល ដែលប្រព័ន្ធអេឡិចត្រូនិចបានឈានជើងចូលមកដល់ប្រទេសកម្ពុជាយើង អភិបាលកិច្ច កិច្ចការគ្រប់គ្រង និងការងារបម្រើសេវាសាធារណៈ ដែលជាប្រយោជន៍រួម របស់ប្រជាពលរដ្ឋ ត្រូវបាននឹងកំពុងដាក់ឱ្យអនុវត្តទន្ទឹមគ្នានៅលើគ្រប់វិស័យ ទាំងសាធារណៈ និង ឯកជន គឺក្នុងគោលដៅតែមួយដើម្បីឆ្លើយតបបានទាន់ពេលវេលានូវតម្រូវការចាំបាច់នានារបស់ ប្រជាពលរដ្ឋ។

## ១.១. អំពីអភិបាលកិច្ច

អភិបាលកិច្ចត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នាជាច្រើន អាស្រ័យនឹងស្ថានភាពជាក់ស្តែង។ ជាសាមញ្ញ អភិបាលកិច្ចមានន័យថា គឺជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការ

គ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ។ ស្រដៀងគ្នានេះដែរកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP1997) បានឱ្យនិយមន័យថា អភិបាលកិច្ចជាការប្រើប្រាស់អំណាចខាងនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ដើម្បីគ្រប់គ្រងកិច្ចការរបស់ប្រទេស។

### ១.១.១. គោលបំណងនៃអភិបាលកិច្ច

គោលបំណងនៃអភិបាលកិច្ច គឺដើម្បីគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងវិបត្តិទាំងឡាយ តាមមធ្យោបាយមួយដែលផ្តល់នូវផលប្រយោជន៍យ៉ាងច្រើនបំផុតដល់ប្រជាពលរដ្ឋ។ ដើម្បីសម្រេចបាននូវគោលបំណងខាងលើនេះ គេបានទទួលស្គាល់ជាទូទៅថា អភិបាលកិច្ចទាមទារនូវការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយនិរន្តរភាព ហើយនិងមានការបញ្ចូលការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចក្នុងការងារគ្រប់គ្រង និងបម្រើសេវាផងដែរ។ ចំណុចសំខាន់ៗ នៃការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយនិរន្តរភាពរួមមានដូចខាងក្រោម៖

- ត្រូវមានសេវាថៃទាំសុខភាពល្អសមស្រប និងគ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋទាំងអស់ ដើម្បីជួយឱ្យពួកគេមានសុខភាពមាំមួន និងអាយុយឺនយូរ។ នេះជាកត្តាដែលអាចធ្វើអោយប្រជាពលរដ្ឋមានសុខុមាលភាព និងថាមពលគ្រប់គ្រាន់ ដើម្បីចូលរួមបានយ៉ាងពេញលេញនៅក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គម។
- ត្រូវមានសេវាអប់រំល្អ សមស្រប និងគ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋទូទៅ ដើម្បីឱ្យពួកគេមានចំណេះដឹងនិងជំនាញពេញលេញក្នុងការបង្កើតឱកាសឱ្យបានច្រើន និងសមស្របបំផុតសម្រាប់ខ្លួន។
- ត្រូវបង្កើតឱកាសសម្រាប់ប្រជាពលរដ្ឋទូទៅ ដើម្បីទទួលបាននូវផលប្រយោជន៍ពីសកម្មភាពសេដ្ឋកិច្ច និងមានការងារធ្វើដើម្បីរកប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការជាមូលដ្ឋាន ដូចជាស្បៀងអាហារ សំលៀកបំពាក់ ជម្រកជាដើម សម្រាប់ពួកគេផ្ទាល់ និងក្រុមគ្រួសាររបស់ពួកគេ។

កត្តាអភិវឌ្ឍធនធានមនុស្សនាសម័យបច្ចេកវិទ្យាទំនើបនេះ ត្រូវបានគិតគូរជាពិសេសក្នុងពង្រឹងសមត្ថភាពលើផ្នែកអេឡិចត្រូនិចលើគ្រប់វិស័យមិនថាការអប់រំ វិស័យសុខាភិបាល ឬឱកាសការងារផ្សេងៗនោះទេ ព្រោះវាត្រូវបានគេយល់ឃើញថាបានជួយពន្លឿនប្រសិទ្ធភាពការងារនានាលើគ្រប់វិស័យ បង្កលក្ខណៈងាយស្រួលដល់អ្នកបម្រើសេវានិងអ្នកទទួលសេវា ដែលជាប្រជា-ពលរដ្ឋផងដែរ។ ជាមួយគ្នានេះដែរតួអង្គសំខាន់ៗ ដែលពាក់ព័ន្ធនៅក្នុងការអភិវឌ្ឍធនធានមនុស្សនេះគឺមាននៅលើគ្រប់វិស័យដែលត្រូវយកចិត្តទុកដាក់។

### ១.១.២. តួអង្គសំខាន់ៗក្នុងអភិបាលកិច្ច

កាលពីមុនគេយល់ឃើញថាមានតែរដ្ឋាភិបាលមួយគត់ ដែលជាតួអង្គនៃអភិបាលកិច្ច។ ប៉ុន្តែបច្ចុប្បន្ននេះមានគំនិតថ្មីៗជាច្រើនបានបង្ហាញថា ផ្នែកឯកជន និងអង្គការសង្គមស៊ីវិលផ្សេងៗទៀតក៏បានដើរតួយ៉ាងសំខាន់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រទេសផងដែរ។ ដូច្នេះតួអង្គសំខាន់ក្នុងអភិបាលកិច្ចមានបីគឺៈ

- រដ្ឋាភិបាល ជាតួអង្គសំខាន់ជាងគេ
- ផ្នែកឯកជន
- សង្គមស៊ីវិល

ឥទ្ធិពលនៃតួអង្គផ្នែកឯកជន និងសង្គមស៊ីវិលមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ អាស្រ័យលើលក្ខខណ្ឌមួយចំនួន ដូចជាប្រព័ន្ធនយោបាយ លក្ខណៈអំណោយផលខាងធនធានធម្មជាតិ ប្រជាពលរដ្ឋ ទីតាំងភូមិសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌និងកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ច-ល-។

ជាក់ស្តែងនៅក្នុងប្រទេសខ្លះផ្នែកឯកជន និងសង្គមស៊ីវិលមានអំណាច និងវិសាលភាពយ៉ាងធំធេង ប៉ុន្តែប្រទេសមួយចំនួនផ្សេងទៀត ផ្នែកឯកជន និងសង្គមស៊ីវិលនេះមានអំណាចឱកាស និងឥទ្ធិពលតិចតួចទៅលើកិច្ចការប្រទេសជាតិ។

### ១.១.៣. ចក្ខុវិស័យជាយុទ្ធសាស្ត្រ

អភិបាលកិច្ចសម្រាប់មុខងារសាធារណៈ ដែលប្រកបដោយសុភវិនិច្ឆ័យ គឺជាអភិបាលកិច្ចល្អដោយការចាត់ចែង និងការគ្រប់គ្រងបញ្ហា និងធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព ហើយឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍របស់សង្គមជាតិទាំងមូល ហើយជាសកម្មភាព ដែលត្រូវបំពេញដោយជន ដែលធ្វើការអចិន្ត្រៃយ៍ និងជាវិជ្ជាជីវៈក្នុងការងាររបស់រាជការ។ ក្នុងន័យនេះគេសង្កត់ធ្ងន់លើសកម្មភាពអចិន្ត្រៃយ៍និងវិជ្ជាជីវៈដោយមិនគិតពីប្រភេទមនុស្សឬប្រភេទគតិយុត្តិឡើយ។ ដោយមានការគាំទ្រពីក្រសួងមហាផ្ទៃយ៉ាងពេញទំហឹងលើការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាព និងក្រោមការដឹកនាំ និងគ្រប់គ្រងបានល្អរបស់ប្រធានស្ថាប័ន ប្រកបសមត្ថភាព និងជំនាញ ក្នុងការដឹកនាំ មានផែនការច្បាស់លាស់ ហើយបុគ្គលិក មន្ត្រីម្នាក់ៗ មានការទទួលខុសត្រូវចំពោះ ខ្លួនឯងនិងអង្គភាពដោយមិនប្រកាន់បក្សពួក និងមានសាមគ្គីភាពផ្ទៃក្នុងបានល្អ ជាចំណុចខ្លាំងរបស់ស្ថាប័នមួយ ដែលអនុវត្តបានតាមគោលការណ៍អភិបាលកិច្ចល្អសម្រាប់មុខងារសាធារណៈ។ ម្យ៉ាងវិញទៀត ដើម្បីជម្រុញការអនុវត្តអភិបាលកិច្ចល្អ ស្ថាប័ន/អង្គភាពរៀងៗខ្លួន ត្រូវប្រជុំយ៉ាងទៀងទាត់ ដោយអនុវត្តតាមប្រតិទិនការងារដើម្បីធ្វើការតាមដានសកម្មភាព ដោយលើកយកបញ្ហាប្រឈមនានាមកពិនិត្យដោះស្រាយក្នុងអង្គប្រជុំ កែលម្អចំណុចខ្វះខាត និងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ។

អ្នកដឹកនាំទាំងអស់ និងស្ថាប័នសាធារណៈនានាត្រូវមានទស្សនទូលំទូលាយ និងសម្រាប់រយៈពេលវែងអំពីអភិបាលកិច្ចល្អ និងការអភិវឌ្ឍន៍ធនធានមនុស្សដោយយកចិត្តទុកដាក់អំពីតម្រូវការចាំបាច់នានា ដែលត្រូវអភិវឌ្ឍលើការងារនេះ។ ជាងនេះទៅទៀតអ្នកដឹកនាំទាំងអស់ត្រូវមានការយល់ដឹងឱ្យបានច្បាស់អំពីទិដ្ឋភាពនានាផ្នែកប្រវត្តិសាស្ត្រ វប្បធម៌ និងសង្គម ដែលពាក់ព័ន្ធនឹងអភិបាលកិច្ចល្អ[1]។

## **១.២.អំពីប្រព័ន្ធអេឡិចត្រូនិច** ( E-Governance )

របត់ថ្មីនៃបច្ចេកវិទ្យាត្រូវបានបង្ហាញ និងយកមកប្រើប្រាស់នៅក្នុងកិច្ចការងារដឹកនាំ និងគ្រប់គ្រងនៅស្ទើរគ្រប់ប្រទេស។ របៀបធ្វើកិច្ចការដែលបាននឹងកំពុងចាប់អារម្មណ៍នេះគឺការងារតាមរយៈ E-Governance ដែលជារបៀបគ្រប់គ្រងមួយផ្តល់ភាពងាយស្រួល និងពន្លឿនប្រសិទ្ធភាពការងារផងដែរ។

### **១.២.១. និយមន័យ**

E-Governance សំដៅទៅលើរបៀប ដែលអ្នកគ្រប់គ្រងបានប្រើប្រាស់អ៊ិនធឺណេត ដើម្បីអនុវត្តមុខងាររបស់ពួកគេក្នុងការត្រួតពិនិត្យការរៀបចំផែនការ ការរៀបចំការសម្របសម្រួល និងបុគ្គលិកដែលមានប្រសិទ្ធិភាព។[2]ការងារនេះគឺបាននឹងកំពុងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICTs) នៅគ្រប់លំដាប់ថ្នាក់នៃរដ្ឋាភិបាល និងវិស័យសាធារណៈ។ ក្រៅពីគោលបំណងដើម្បីលើកកម្ពស់អភិបាលកិច្ចនេះ E-Governance មិនចាំបាច់ចាំបាច់ត្រូវធ្វើឡើងដោយរដ្ឋាភិបាលទេ ក្រុមហ៊ុនឯកជន សមាគមន៍ អង្គការមិនមែនរដ្ឋាភិបាល ទាំងអស់សុទ្ធតែចូលរួមបាន និងមានការចូលរួមជាមួយស្ថាប័នរដ្ឋាភិបាលដើម្បីបង្កើតអភិបាលកិច្ចនេះ តែជួនកាលក៏មិនមានសិទ្ធិអំណាចរបស់រដ្ឋាភិបាលផងដែរ។ ច្បាស់ណាស់និយមន័យនេះបានបង្ហាញថាអភិបាលកិច្ចអេឡិចត្រូនិចមិនចាំបាច់ត្រូវបានកំណត់ចំពោះវិស័យសាធារណៈនោះទេ វាមានន័យថាដល់ការគ្រប់គ្រងគោលនយោបាយនិងនីតិវិធីនៅក្នុងវិស័យឯកជនផងដែរ។

យោងតាមធនាគារពិភពលោក (World Bank)[3] ធនាគារអភិវឌ្ឍន៍អាស៊ី[4] បានឱ្យនិយមន័យថា E-Governance សំដៅទៅលើការប្រើប្រាស់បច្ចេកវិទ្យាICT ដើម្បីបម្រើប្រជាជន និងកែលម្អអន្តរកម្មក្នុងជំនួញឧស្សាហកម្ម និងការផ្តល់សិទ្ធិអំណាចរបស់ប្រជាពលរដ្ឋតាមរយៈការទទួលបានព័ត៌មាន ឬប្រសិទ្ធភាពលទ្ធផលនៃបញ្ហាដែលបានដោះស្រាយដោយរដ្ឋាភិបាល។ អត្ថប្រយោជន៍នៃបញ្ហា

[1] What is Good Governance, United Nation Economics and Social Commission for Asia and the Pacific
[2] http://csi-sigegov.orgwww.csi-sigegov.org/1/1_369.pdf
[3] www.worldbank.org
[4] www.adb.org

នេះគឺថាវាអាចបង្កើនតម្លាភាព និងអភិបាលកិច្ច ដែលគ្មានអំពើពុករលួយ ផ្តល់ភាពងាយស្រួលកាន់តែច្រើន កំណើនប្រាក់ចំណូល និងកាត់បន្ថយចំណាយផ្សេងៗជាច្រើន ជាពិសេសចំណាយក្រៅផ្លូវការ។ E-Governance ឬ "អភិបាលកិច្ចអេឡិចត្រូនិច" គឺការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា (ICTs) ទៅក្នុងដំណើរការនៃមុខងាររបស់រដ្ឋាភិបាលក្នុងគោលបំណងដើម្បីធ្វើឱ្យមានភាពសាមញ្ញ, មានក្រមសីលធម៌ល្អ, ផ្តល់នូវគណនេយ្យភាព, ឆ្លើយតបបានរហ័សនូវតម្រូវការរបស់ប្រជាពលរដ្ឋជាពិសេសអ្នកក្រីក្រ និងអ្នកងាយរងគ្រោះបំផុត ក្នុងការធ្វើសេចក្តីសម្រេចស្តីអំពីការអភិវឌ្ឍសង្គមនានា។

ជាមួយគ្នានេះដែរ អង្គការយូណេស្កូ ក៏បានផ្តល់និយមន័យមួយអំពី E-Governance នេះដែរ គឺ E-Governance ជាការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ក្នុងវិស័យសាធារណៈក្នុងគោលបំណងធ្វើអោយប្រសើរឡើងនូវព័ត៌មាន និងការផ្តល់សេវាកម្មដោយលើកទឹកចិត្តដល់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងធ្វើឱ្យរដ្ឋាភិបាលមានការទទួលខុសត្រូវបន្ថែមទៀត ហើយការប្រើប្រាស់ប្រព័ន្ធនេះនឹងនាំឱ្យមានតម្លាភាព និងប្រសិទ្ធិភាពនៃសេវាសាធារណៈផងដែរ។ ការគ្រប់គ្រងតាមប្រព័ន្ធអេឡិចត្រូនិចនេះ គឺទាក់ទងនឹងរបៀបថ្មីនៃភាពជាអ្នកដឹកនាំដោយការជជែកវែកញែក ការសម្រេចគោលនយោបាយ និងការវិនិយោគថ្មីៗ ដោយការស្តាប់ប្រជាពលរដ្ឋ រៀបចំ ចែកចាយព័ត៌មាន និងផ្តល់សេវាកម្មដោយប្រសិទ្ធភាព និងប្រសិទ្ធផល។[5]

អភិបាលកិច្ចអាចជាសកម្មភាពគ្រប់គ្រងប្រទេសមួយដោយរដ្ឋាភិបាលរបស់ខ្លួន គ្រប់គ្រងអង្គភាព ឬក្រុមហ៊ុនដោយនាយកប្រតិបត្តិ ឬក្រុមប្រឹក្សាភិបាល ឬគ្រួតពិនិត្យផ្ទះរបស់មេដឹកនាំផ្ទះ។ ដូច្នេះ E-Governance អាចពាក់ព័ន្ធនឹងការគ្រប់គ្រងផងដែរនៃប្រទេស អង្គការ អង្គភាព ឬគ្រួសារ ទោះបីជាយ៉ាងណាក៏ដោយគឺត្រូវមានជំនួយពីបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ (ICT) ។ ប៉ុន្តែនៅពេលដែលយើងនិយាយពី E-Governance នៅក្នុងភាសាដែលមានប្រជាប្រិយភាព គឺយើងគ្រាន់តែសំដៅទៅលើការគ្រប់គ្រងនៃប្រទេស ឬរដ្ឋមួយដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាប៉ុណ្ណោះ។ ដូចនេះ E-Governance មានន័យថាជាការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា និងទូរគមនាគមន៍ (ICT) ដើម្បីបង្កើនប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ការផ្លាស់ប្តូរព័ត៌មាន និងប្រតិបត្តិការរវាងរដ្ឋាភិបាល ភ្នាក់ងាររដ្ឋាភិបាល ប្រជាពលរដ្ឋ និងកិច្ចការធុរកិច្ច[6]

### ១.២.២. គោលបំណង

ការគ្រប់គ្រងអេឡិចត្រូនិច ត្រូវបានគេចាត់ទុកថាជាគំនិតទូលំទូលាយព្រោះថាវាអាចនាំមកនូវការផ្លាស់ប្តូររបៀប ដែលពលរដ្ឋពាក់ព័ន្ធនឹងរដ្ឋាភិបាលជាមួយគ្នាទៅវិញទៅមក។ អភិបាលកិច្ច

[5] www.unesco.org

[6] http://indiaegovernance.blogspot.com/2008/03/e-governance-what-does-it-mean.html

អេឡិចត្រូនិចអាចនាំមកនូវគំនិតថ្មីនៃភាពជាពលរដ្ឋទាំងក្នុងលក្ខខណ្ឌនៃតម្រូវការរបស់ប្រជាពលរដ្ឋ និងការទទួលខុសត្រូវ។ គោលបំណងរបស់វា គឺដើម្បីចូលរួមបើកសិទ្ធិ និងផ្តល់អំណាចដល់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន និងការផ្តល់សេវាដែលត្រឹមត្រូវ និងមានប្រសិទ្ធភាព។[7]

គំនិតនៃ E-Governance ដែលត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សានៃទ្វីបអឺរ៉ុបគ្របដណ្តប់លើការប្រើប្រាស់បច្ចេកវិទ្យាអេឡិចត្រូនិចនៅក្នុងវិស័យសាធារណៈបីរួមមាន៖

- ទំនាក់ទំនងរវាងអាជ្ញាធរសាធារណៈ និងសង្គមស៊ីវិល(E-Administration)៖ សំដៅដល់ដំណើរការ និងការប្រព្រឹត្តទៅរបស់រដ្ឋាភិបាល ជាពិសេសកិច្ចសហប្រតិបត្តិការទាំងផ្ទៃក្នុង និងអង្គភាពខាងក្រៅ។
- ដំណើរការនៃអាជ្ញាធរសាធារណៈនៅគ្រប់ដំណាក់កាល នៃដំណើរការប្រជាធិបតេយ្យ (E-Democracy)៖ ជាការអនុវត្តប្រជាធិបតេយ្យដ៏ទំនើបមួយជាមួយការចូលរួមដោយផ្ទាល់របស់រដ្ឋាភិបាល និងប្រជាពលរដ្ឋ រវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល
- ការផ្តល់សេវាសាធារណៈ (E-Service)៖ ជាចំណុចមួយដែលល្អប្រសើរបំផុតក្នុងការផ្តល់សេវាដែល ជាតម្រូវការរបស់ប្រជាពលរដ្ឋតាមរយៈប្រព័ន្ធអេឡិចត្រូនិច ដែលជាសេវាសាធារណៈរបស់រដ្ឋ[8]។

ការអនុវត្តអេឡិចត្រូនិចត្រូវបានកំណត់ថាជាការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិកនៅក្នុង៖

- អន្តរកម្មរវាងរដ្ឋាភិបាល និងពលរដ្ឋ រដ្ឋាភិបាល និងធុរកិច្ច
- នៅក្នុងប្រតិបត្តិការរបស់រដ្ឋាភិបាលផ្ទៃក្នុង ដើម្បីធ្វើឱ្យភាពងាយស្រួល និងកែលម្អទិដ្ឋភាពប្រជាធិបតេយ្យរដ្ឋាភិបាល និងអាជីវកម្មនៃអភិបាលកិច្ច។

ការលើកឡើងមួយទៀតអំពី E-Governance គេបានឱ្យនិយមន័យថាជាការពង្រីកការគ្រប់គ្រង និងជាការបញ្ចូលបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ (ICT) នៅក្នុងគ្រប់ដំណើរការទាំងអស់ក្នុងគោលបំណងបង្កើនសមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការដោះស្រាយតម្រូវការរបស់សាធារណជនទូទៅ។ គោលបំណងជាមូលដ្ឋាននៃ E-Governance គឺដើម្បីធ្វើឱ្យដំណើរការងាយស្រួលសម្រាប់

[7] ក្រុមប្រឹក្សាអឺរ៉ុប, http://www.coe.int/T/E/Com/Files/Themes/e-voting/definition.asp

[8].សេវាសាធារណៈរបស់រដ្ឋរួមមាន៖ ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរបស់រដ្ឋ ចង្កោមសេវាពាក់ព័ន្ធនឹងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ចង្កោមសេវាពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាល ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម សហគ្រាសធុនតូច និងមធ្យម បរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាង និងការថែទាំងហេដ្ឋារចនាសម្ព័ន្ធ ចង្កោមសេវាសង្គមកិច្ច វប្បធម៌ និងកិច្ចការនារី ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ចង្កោមសេវាពាក់ព័ន្ធនឹងការប្រមូលចំណូល ការធ្វើវិចារណកម្មចំណាយ និងការបើកផ្តល់

ទាំងអស់គ្នាពោលគឺរដ្ឋាភិបាលជាមួយនឹងប្រជាពលរដ្ឋ និងរដ្ឋាភិបាលជាមួយនឹងអាជីវកម្ម។ល។ នៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។

E-Governance ក៏មានគោលបំណងផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋតាមរយៈការផ្តល់ឱ្យពួកគេនូវលទ្ធភាពទទួលបានព័ត៌មានផងដែរ។

**១.២.៣. អត្ថប្រយោជន៍**

E-Governance ដែលជាគំនិតទូលំទូលាយមួយនេះ គឺវាទាក់ទងនឹងវិសាលភាពទាំងមូលនៃទំនាក់ទំនង និងបណ្តាញនៅក្នុងរដ្ឋាភិបាលទាក់ទងនឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា និងជាវិធីនៃការពិពណ៌នាអំពីទំនាក់ទំនងរវាងរដ្ឋាភិបាល និងបរិយាកាសធំទូលាយនៃនយោបាយសង្គម និងរដ្ឋបាល។

ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចនេះ គឺពិតជាបានលើកកម្ពស់អភិបាលកិច្ចល្អជាច្រើន ដែលវាសំដៅដល់ការអនុវត្តបច្ចេកវិទ្យាព័ត៌មាននៅក្នុងដំណើរការការងារ និងមុខងាររបស់រដ្ឋាភិបាលដើម្បីធ្វើឱ្យអភិបាលកិច្ចមានលក្ខណៈសាមញ្ញ មានសីលធម៌ មានគណនេយ្យភាពនិងមានតម្លាភាព។ លើសពីនេះទៅទៀតវាតម្រូវឱ្យមានការទទួល និងការផ្តល់សេវារបស់រដ្ឋាភិបាលមានការផ្សព្វផ្សាយព័ត៌មាន ការប្រាស្រ័យទាក់ទងយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព។

អត្ថប្រយោជន៍សំខាន់ៗ នៃប្រព័ន្ធអេឡិចត្រូនិចនេះរួមមានជាច្រើនដូចជា៖

- កាត់បន្ថយអំពើពុករលួយ៖ តាមរយៈនេះអ្នកទទួលសេវា (ប្រជាពលរដ្ឋ) ជៀសវាងការចំណាយក្រៅផ្លូវការ និងដំណាក់កាលច្រើននៃការិយាធិបតេយ្យ។
- តម្លាភាពខ្ពស់៖ ទាំងអ្នកផ្តល់សេវា និងអ្នកទទួលសេវា បានឃើញពីដំណើរការប្រព្រឹត្តទៅទាំងអស់គ្នា មិនមានការលាក់បាំង ឬក្លែងបន្លំបាន។
- ការបង្កើនភាពងាយស្រួល៖ សំដៅដល់ភាពលឿន រហ័ស ចំណាយតិច នឹងទទួលសេវាបានច្រើន ឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ។
- កំណើន ផ.ស.ស៖ អ្នកផលិតក្នុងស្រុក អ្នកវិនិយោគក្នុងស្រុក មានលទ្ធភាពទទួលបានការបញ្ជាក់ ការទទួលស្គាល់ផលិតផលទំនិញបានលឿន និងមានការទុកចិត្ត តាមរយៈតម្លាភាព និងបង្កើនការផលិតបានកាន់តែច្រើនទាំងបរិមាណ និងគុណភាពសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក និងការនាំចេញ។
- ការចូលរួមដោយផ្ទាល់ពីមណ្ឌលបោះឆ្នោត៖ ទទួលបាននូវការជឿទុកចិត្តខ្ពស់ មានការកក់ក្តៅទៅលើសម្លេងគាំទ្ររបស់ខ្លួន

- កាត់បន្ថយចំណាយសរុបៈ ការចំណាយទាបជាងមុន ដែលរួមផ្សំនឹងការលុបបំបាត់ចំណាយក្រៅផ្លូវការច្រើន។
- ការពង្រីកនៃរដ្ឋាភិបាលៈ រដ្ឋាភិបាល នឹងនៅកាន់តែកៀកជិតជាមួយប្រជាពលរដ្ឋងាយស្រួលទទួលបានព័ត៌មាន ដែលជាបញ្ហាជួបប្រទៈ និងធ្វើការដោះស្រាយបានទាន់ពេលវេលា[៩]។

តាមរយៈអភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិច រដ្ឋាភិបាលមានគម្រោងបង្កើនការគ្របដណ្តប់ និងគុណភាពនៃព័ត៌មាន និងសេវាកម្ម ដែលបានផ្តល់ជូនសាធារណជនទូទៅដោយការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ក្នុងភាពងាយស្រួលឱ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផលខ្ពស់។ ដំណើរការនេះមានភាពស្មុគស្មាញខ្លាំង ដែលតម្រូវឱ្យមានការរៀបចំផ្នែក Hardware និង Software ការភ្ជាប់បណ្តាញ និងការបង្កើតឡើងវិញនូវរាល់ដំណើរការទាំងអស់ ដើម្បីសម្រួលដល់ការផ្តល់សេវា។[10]

[9] http://businessjargons.com/e-governance.html

[10] http://businessjargons.com/e-governance.html#ixzz4nSOVBXKJ

# ជំពូកទី២

# ការអនុវត្តប្រព័ន្ធអេឡិចត្រូនិចនៅកម្ពុជា

ការដាក់ជាក្រុមនៃបណ្ដាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ និងភាពជឿនលឿនខាងបច្ចេកវិទ្យាព័ត៌មានបានធ្វើឱ្យប្រទេសនានាអាចទទួលយកនូវការផ្លាស់ប្ដូរចាំបាច់ សម្រាប់ការរស់រានមានជីវិតនៅក្នុងក្រុម និងដើម្បីទទួលបានជោគជ័យនៅក្នុងសហាគមន៍ពិភពលោក។ នៅពេលចូលរួមជាមួយអាស៊ាននៅខែមេសាឆ្នាំ១៩៩៩ ប្រទេសកម្ពុជា បានខិតខំប្រឹងប្រែងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដើម្បីធ្វើជាអ្នកសំរេចចិត្តក្នុងការបំពេញតួនាទីរបស់ខ្លួននៅក្នុងក្រុមហើយបានចាប់ផ្ដើមកំណែទម្រង់រដ្ឋបាលសំខាន់ៗជាបន្តបន្ទាប់។

ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានមានប្រសាសន៍ថា « មន្ត្រីគ្រប់ក្រសួង-ស្ថាប័ន ត្រូវធ្វើអក្ខរកម្មព័ត៌មានវិទ្យា៖ យើងប្រកាសសុទ្ធតែរដ្ឋាភិបាលអេឡិចត្រូនិច (e-Government) ស្អីក៏ e ទាំងអស់ដែរ ប៉ុន្តែបើមនុស្សអត់ e ផង តើធ្វើម្ដេចទៅ[11]? ឯកឧត្តមរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ក៏បានថ្លែងផងដែរអំពីដំណើរការនៃការដាក់ឱ្យអនុវត្ត E-Administration នៅក្នុងស្ថាប័ននានា ដែលបច្ចុប្បន្នក្រសួងមុខងារសាធារណៈបាននឹងកំពុងដាក់ឱ្យប្រើប្រាស់ជាសាកល្បងផងដែរនូវ E-Administration ដែលសំដៅលើការគ្រប់គ្រងលំហូរនៃលិខិតចេញ-ចូល ការគ្រប់គ្រងចរន្តឯកសារនានា ដើម្បីពន្លឿនដល់ដំណើរការប្រព្រឹត្តទៅរបស់ក្រសួង[12]

រដ្ឋាភិបាល និងស្ថាប័នដទៃទៀត បានប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចនេះក្នុងគោលបំណងពង្រឹងអភិបាលកិច្ចដោយកែលម្អគណនេយ្យភាព តម្លាភាព ការចូលរួមប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធភាពនៃវិស័យសាធារណៈ និងវិស័យឯកជន។ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវការអភិវឌ្ឍមួយចំនួននៅក្នុងវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា ទោះបីជាមានការប្រឈមមួយចំនួនក៏ដោយ ហើយយុទ្ធសាស្ត្រ និងសកម្មភាពអនុវត្តបន្តនានាត្រូវបានពិចារណាដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាផងដែរ។

## ២.១. វត្តមានប្រព័ន្ធអេឡិចត្រូនិចនៅកម្ពុជា

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ជាកាលបរិច្ឆេទ ដែលបណ្ដាប្រទេសអាស៊ានត្រូវបានដាក់បញ្ចូលជាសហាគមន៍សេដ្ឋកិច្ចអាស៊ានតែមួយ។ បន្ទាប់ពីការធ្វើសមាហរណកម្មសហាគមន៍នឹងប្រឹង

[11] ប្រសាសន៍សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីចែកសញ្ញាបត្រដល់និស្សិតនៃវិទ្យាស្ថានវ៉ាន់ដា នាថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥

[12] ប្រសាសន៍ ឯកឧត្តម ពេជ្រ ប៊ុនធិន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ថ្លែងក្នុងពិធីប្រគល់វិញ្ញាបនបត្រដល់សិស្សសាលាភូមិន្ទរដ្ឋបាល នៅវិទ្យាស្ថានជាតិអប់រំ នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧

ប្រែងឱ្យអស់ពីសមត្ថភាពក្រោមគោលការណ៍អាស៊ាន ដែលមានចក្ខុវិស័យ បេសកកម្ម និងវាសនាដូចគ្នា។ សម្រាប់កម្ពុជាការវិវឌ្ឍ និងការអនុវត្តន៍អភិបាលកិច្ច មានសារៈសំខាន់ខ្លាំងណាស់នៅក្នុងប្រទេសនេះដើម្បីសម្របខ្លួនជាមុន។ រយៈកាលជាងមួយទស្សវត្សរ៍ចុងក្រោយនេះរាជរដ្ឋាភិបាលដែល ដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានព្យាយាមកំណត់ពីរបៀបដើម្បីសម្រេចបាននូវអភិបាលកិច្ចល្អទាំងវិស័យសាធារណៈ និងវិស័យ ឯកជន រដ្ឋបាល ច្បាប់ និងតុលាការ។ ប្រព័ន្ធនានាត្រូវបានធ្វើកំណែទម្រង់ដោយប្រុងប្រយ័ត្នដើម្បីពង្រឹងការអភិវឌ្ឍធនធានមនុស្ស នីតិកម្ម ក្រោមការគ្រប់គ្រងតាមរយៈប្រព័ន្ធអ៊ីនធឺណេត។ ដើម្បីបំពេញតាមលក្ខខណ្ឌធម្មនុញ្ញរបស់អាស៊ាន ប្រព័ន្ធលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានពីររបស់រាជរដ្ឋាភិបាលកម្ពុជាគឺវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានអនុវត្តយ៉ាងប្រុងប្រយ័ត្ននៅកម្ពុជាក្នុងឆ្នាំ២០០១-២០០៨ ហើយត្រូវបានធ្វើកំណែទម្រង់ក្នុងអំឡុងឆ្នាំ២០០៩-២០១២ ដែលបេសកកម្មរបស់ខ្លួនគឺដើម្បីធ្វើឱ្យល្អប្រសើរឡើងនៃរចនាសម្ព័ន្ធយន្តការថ្មី និងរដ្ឋបាលរបស់មូលដ្ឋាន ទាមទារឱ្យមានអភិបាលកិច្ចល្អ ដែលកំណត់ដោយការចូលរួមមានតម្លាភាព និងគណនេយ្យភាព។

### ២.១.១.អំពីប្រវត្តិ

ការបង្កើតរាជរដ្ឋាភិបាលកម្ពុជា ក្នុងឆ្នាំ១៩៩៣ ក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិស្តីពីការបង្កើតរដ្ឋាភិបាលជាបន្តបន្ទាប់នៅឆ្នាំ១៩៩៨ ហើយម្តងទៀតនៅឆ្នាំ២០០៣ បានទទួលជំនួយហិរញ្ញវត្ថុយ៉ាងច្រើនពីសហគមន៍អន្តរជាតិ។ ថវិកាវាប់ពាន់លានដុល្លារអាមេរិកត្រូវបានចំណាយលើកម្ពុជា។ ដើម្បីទទួលបានជំនួយហិរញ្ញវត្ថុសម្រាប់ការបង្កើត និងការប្រព្រឹត្តទៅរបស់រដ្ឋាភិបាលសហគមន៍អន្តរជាតិ ក៏តម្រូវឱ្យរាជរដ្ឋាភិបាលកម្ពុជាផ្តល់ជូនផងដែរនូវការទទួលខុសត្រូវច្បាស់លាស់នៃ មូលនិធិកំណែទម្រង់រដ្ឋបាលសាធារណៈ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ ការខកខានមិនបានបំពេញតាមស្តង់ដារកំណត់ជាមុនដោយសហគមន៍អន្តរជាតិអាចបណ្តាលឱ្យបញ្ចប់ ឬផ្អាកទាំងអស់ ឬផ្នែកនៃជំនួយហិរញ្ញវត្ថុមកដល់កម្ពុជា។

នៅខែមេសា ឆ្នាំ១៩៩៩ កម្ពុជាបានទទួលយកនូវរាល់កិច្ចព្រមព្រៀងទាំងអស់នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)។ នៅពេលដែលបានចូលរួមជាមួយអាស៊ាន កម្ពុជាបានដឹងយ៉ាងច្បាស់អំពីអត្ថប្រយោជន៍នៃការទទួលបានទីផ្សារមនុស្សចំនួន៥០០លាននាក់ និងកាតព្វកិច្ចដើម្បីចូលរួមជាមួយផលប្រយោជន៍ទាំងនេះ។ ជាមួយគ្នានេះដែរតម្រូវការដើម្បីទទួលបានជោគជ័យនៅក្នុងសហគមន៍ក្នុងតំបន់និងដើម្បីរស់នៅក្នុងសហគមន៍អន្តរជាតិ គឺជាកត្តាខាងក្រៅមួយដែលជំរុញ

ឱ្យរដ្ឋាភិបាលយកបច្ចេកវិទ្យាថ្មី។ តម្រូវការសេវាសាធារណៈល្អប្រសើរជាងមុនដោយអ្នកបោះឆ្នោតកម្ពុជាគឺជាកត្តាផ្ទៃក្នុងមួយផ្សេងទៀត។ គម្រោងប្រព័ន្ធគ្រប់គ្រងព័ត៌មានរដ្ឋបាលរបស់រដ្ឋាភិបាល (GAIS) បានកើតចេញពីតម្រូវការចាំបាច់ទាំងនេះ។

នៅក្រោមគ្រោងការណ៍ CEPT (Common Customs Effective Preferential Treatment) (CEPTពន្ធអនុគ្រោះចំណូលទូទៅមានប្រសិទ្ធិភាព[13]) កម្ពុជាត្រូវបន្ថយពន្ធនាំចូលឱ្យនៅត្រឹម 0-5% ត្រឹមឆ្នាំ២០១០[14]។ ការកាត់បន្ថយពន្ធគយនាំចូលពិតជានឹងប៉ះពាល់ដល់ថវិកាជាតិ ដោយសារតែថវិកាចំនួន១៦,៣១% នៃថវិកាជាតិគឺពឹងផ្អែកទាំងស្រុងទៅលើពន្ធនាំចូល។[15]ការព្រួយបារម្ភចំពោះការបាត់បង់ប្រាក់ចំណូល រដ្ឋាភិបាលបានប្តេជ្ញាចិត្តស្វែងរកមធ្យោបាយដើម្បីបំពេញបន្ថែមការខាតបង់បែបនេះ។ វិធានការមួយនេះគឺតាមរយៈការបង់ពន្ធផ្សេងៗរួមបញ្ចូល ប៉ុន្តែមិនកំណត់ចំពោះពន្ធលើប្រាក់ចំណូលពន្ធ អចលនទ្រព្យ និងពន្ធផ្លូវ រថយន្តទេ។ ទន្ទឹមនឹងនេះរូបភាព និងសេវាកម្មរបស់រដ្ឋាភិបាល ត្រូវតែមានការកែលំអយ៉ាងខ្លាំងក្លាដើម្បីធានានូវទំនុកចិត្តរបស់សាធារណជននៅក្នុងរដ្ឋាភិបាល។ ជាមួយនឹងការបង្កើតប្រាក់ចំណូលរូបភាព និងសេវាកម្មរបស់រដ្ឋាភិបាលកាន់តែប្រសើរឡើង រដ្ឋាភិបាលបានកំណត់លទ្ធភាពទាំងអស់ដើម្បីសម្រេចគោលបំណងបែបនេះ។ ដំណោះស្រាយមួយក្នុងចំណោមដំណោះស្រាយផ្សេងទៀត គឺប្រើបច្ចេកវិទ្យាព័ត៌មានជាអ្នកបង្កើតដើម្បីសម្រេចគោលបំណង ហើយដំណោះស្រាយនេះបាននាំឱ្យមានការអនុម័តប្រព័ន្ធគ្រប់គ្រងព័ត៌មានរដ្ឋបាលរបស់រដ្ឋាភិបាល (GAIS) ជាមួយកម្មវិធីសំខាន់ៗដូចជា៖ ប្រព័ន្ធអេឡិចត្រូនិច (EAS) ការចុះបញ្ជីអចលនទ្រព្យ ការចុះបញ្ជីលំនៅដ្ឋាន និងការចុះបញ្ជីរថយន្ត។

គម្រោង GAIS មិនមែនថ្មីទាំងស្រុងទេ។ គោលដៅនៃគម្រោងនេះគឺដើម្បីប្រើប្រាស់កុំព្យូទ័រដោយរដ្ឋាភិបាលជាមួយកម្មវិធីស្នូលចំនួនបួន ដែលក្នុងពេលកន្លងមកមានការប៉ុនប៉ងមិនជោគជ័យជាច្រើនត្រូវបានបង្កើតឡើងដើម្បីបញ្ចូលកុំព្យូទ័រទៅរដ្ឋាភិបាល។ មូលហេតុនៃការបរាជ័យនេះរួមមានឆន្ទៈនយោបាយ សមត្ថភាពបច្ចេកទេស ការចូលរួម និងភាពជាអ្នកដឹកនាំនៅក្នុងកិច្ចការថ្មីនេះ។ ដោយផ្អែកលើការបរាជ័យនេះរដ្ឋាភិបាលបានផ្តួចផ្តើមយ៉ាងតឹងរ៉ឹងដើម្បីបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា (NiDA) នៅខែសីហាឆ្នាំ

---

[13] CEPT គឺជាយន្តការដែលពន្ធគយលើទំនិញដែលបានជួញដូរនៅក្នុងតំបន់អាស៊ានដែលបំពេញតម្រូវការ 40% នៃបរិមាណអាស៊ានត្រូវបានកាត់បន្ថយនឹង 0-5% នៅឆ្នាំ 2002-2003 (2006 សម្រាប់វៀតណាមឆ្នាំ 2008 សម្រាប់ឡាវនិងមីយ៉ាន់ម៉ា) និង 2010 សម្រាប់ប្រទេសកម្ពុជា) https://www.usasean.org/regions/asean/afta/common-effective-preferential-tariff#main-content

[14]ASEAN Agreement

[15] 2002 Budget Law

២០០០ ដើម្បីបំពេញភារកិច្ចដ៏ធំធេង នៃការប្រើកុំព្យូទ័ររបស់រដ្ឋាភិបាល ជាមួយការអនុវត្តជាក់ស្តែង។ ការបង្កើត នីដា(NIDA) ដែលដឹកនាំដោយផ្ទាល់ពីនាយករដ្ឋមន្ត្រីបានផ្ញើសារច្បាស់លាស់ដល់សាធារណៈ មតិថារដ្ឋាភិបាលមានឆន្ទៈនយោបាយដ៏រឹងមាំបំផុត ដែលមិនធ្លាប់មានដើម្បីលើកកម្ពស់ការអភិវឌ្ឍ ICT និងជាពិសេសការអនុវត្តគម្រោង GAIS។ ជាពិសេសបញ្ហាពីមុនដែលបានជួបប្រទះដោយក្រសួងនានាថាតើអ្នកណាគួរនាំមុខ និងបង្កើតស្តង់ដារនៃការអនុវត្តដែលត្រូវទទួលយកនោះ ត្រូវ បានដោះស្រាយភាគច្រើនក្រោយបង្កើត នីដា ដែលដឹកនាំដោយនាយករដ្ឋមន្ត្រី។[16]

ការវិវឌ្ឍន៍នៃការគ្រប់គ្រងអេឡិចត្រូនិចនៅក្នុងប្រទេសកម្ពុជា ត្រូវបានកត់សម្គាល់តាមរយៈព្រឹត្តិការណ៍សំខាន់ៗ ដែលសម្របសម្រួលដល់ការអភិវឌ្ឍន៍វិស័យអេឡិចត្រូនិចនៅក្នុងប្រទេសកម្ពុជាដូចខាងក្រោម៖

- ឆ្នាំ១៩៧៩៖ រាជរដ្ឋាភិបាលកម្ពុជា បានទទួលជ័យជម្នះពីរបបកម្ពុជាប្រជាធិបតេយ្យ(រដ្ឋាភិបាលនៅក្នុងមុខងាររបស់រដ្ឋាភិបាលគឺមិនទាន់មានភាពច្បាស់លាស់) ។
- ឆ្នាំ១៩៩១៖ កិច្ចព្រមព្រៀងសន្តិភាពប៉ារីស (វាជានិមិត្តរូបនៃបន្ទាត់ពណ៌លឿងសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីអនុវត្តដំណាក់កាលដំបូងនៃការអនុវត្តន៍ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ (ICT) ក៏ដូចជាការអភិវឌ្ឍអភិបាលកិច្ចល្អនៅកម្ពុជាផងដែរ ។
- ឆ្នាំ១៩៩២៖ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា (MPTC) មានបណ្តាញចេញ-ចូលនៃទូរស័ព្ទជាតិ និងអន្តរជាតិ។
- ឆ្នាំ១៩៩៥ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានបង្កើតវិទ្យាស្ថានបច្ចេកវិទ្យាព័ត៌មានវិទ្យា និងបានឈ្នះពានរង្វាន់វិទ្យាស្ថានអប់រំបច្ចេកវិទ្យា(IT) ល្អបំផុតនៅឆ្នាំ២០១១។
- ឆ្នាំ២០០០ កិច្ចព្រមព្រៀងស្តីពីអាស៊ានត្រូវបានចុះហត្ថលេខាកាលពីខែវិច្ឆិកានៅសិង្ហបុរី។ កិច្ចព្រមព្រៀងនេះផ្តោតលើ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធ បច្ចេកវិទ្យា ព័ត៌មាន និងគមនាគមន៍ (ICT) របស់អាស៊ានដើម្បីលើកកម្ពស់ពាណិជ្ជកម្មអេឡិចត្រូនិច សេវាកម្មអេឡិចត្រូនិច ការវិនិយោគនៅក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា និងការអភិវឌ្ឍធនធានមនុស្សសម្រាប់ E-Governance។[17]
- ឆ្នាំ២០០០ ដដែល អាជ្ញាធរជាតិអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ជាតិ (NiDA) ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាដែលវាគឺជាអំណាចទទួលខុសត្រូវក្នុងការបង្កើតគោលនយោបាយ

[16] Leewood Phu, Secretary GeneralNational ICT Development Authority (NiDA): The Road to e-Governance in Cambodia

[17] សុន្ទរកថាសម្តេចតេជោ ហ៊ុន សែន ក្នុងពិធីបើកការដាក់ឱ្យប្រើប្រព័ន្ធអេឡិចត្រូនិកសម្រាប់ក្រុមប្រឹក្សារដ្ឋមន្ត្រីឆ្នាំ ២០០៤។

និងយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍(ICT) មិនត្រឹមតែលើកកម្ពស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាសម្រាប់ស្ថាប័នសាធារណៈទាំងអស់នោះទេ ថែមទាំងវិស័យឯកជនផងដែរ ដែលជាមួយគ្នានេះ ក្រសួងរដ្ឋាភិបាល ក៏មានរៀបចំ និងគ្រប់គ្រងរដ្ឋាភិបាលអេឡិចត្រូនិកផងដែរ។

- ឆ្នាំ២០០១ ប្រទេសកម្ពុជាត្រូវបានចាត់ថ្នាក់ថាជាប្រទេសកំពុងត្រៀមខ្លួន ដែលត្រូវបានកំណត់តម្រូវឱ្យមានការសាងសង់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា ជាមូលដ្ឋាន និងរៀបចំកម្លាំងពលកម្មនៃអាយស៊ីធី។[18]
- ឆ្នាំ២០០២ ប្រព័ន្ធព័ត៌មានរដ្ឋបាលរបស់រដ្ឋាភិបាល (GAIS) បានគ្រប់គ្រងដោយរដ្ឋបាលនីតិកម្ម ដោយប្រព័ន្ធអនុម័តអេឡិចត្រូនិចអនុញ្ញាតឱ្យក្រសួងរដ្ឋាភិបាលធ្វើការផ្លាស់ប្តូរឯកសារក្នុង និងក្រៅប្រទេស ដើម្បីកាត់បន្ថយការប្រើប្រាស់ឧបករណ៍ការិយាល័យ និងធ្វើកិច្ចការរដ្ឋបាល (ការអនុម័តតាមអេឡិចត្រូនិក,អ៊ីម៉ែលអេឡិចត្រូនិចការបង្ហោះព័ត៌មានលើបណ្តាញអ៊ីនធឺណេត រក្សាទុក និងគ្រប់គ្រងឯកសារ។ ល។)បានផ្តល់ភាពងាយស្រួល និងលឿន។ ការចុះបញ្ជីអចលនទ្រព្យ (ដោយមានការឃ្លាំមើលការជួញដូរអចលនៈទ្រព្យ រួមទាំងតម្លៃ និងពន្ធដែលបានបង់) ការចុះឈ្មោះអ្នកស្នាក់នៅ (រក្សាតាមដាន និងកំណត់ត្រានៃអ្នកស្រុក សមាសភាពគ្រួសារ, និងការងារសម្រាប់ការអប់រំជាកំហិតសម្រាប់ក្មេងអាយុសិក្សានិងប្រមូលពន្ធលើប្រាក់ចំណូល) ការចុះបញ្ជីយានយន្ត(រក្សាតាមដាននៃភាពជាម្ចាស់រថយន្ត ការបង់ពន្ធ និងការត្រួតពិនិត្យសុវត្ថិភាព និងវត្តមាននៃរដ្ឋាភិបាលនៅលើ World Wide Web (គេហទំព័រជាតិរបស់រដ្ឋាភិបាលបានផ្តល់ព័ត៌មានអំពីរដ្ឋាភិបាល អំពីព្រះរាជាណាចក្រកម្ពុជា ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ព្រឹទ្ធសភា រដ្ឋសភា អង្គការ និងព័ត៌មានផ្សេងៗទៀត ឬស្ថាប័ន)។
- ឆ្នាំ២០០៣ រដ្ឋាភិបាលបានអនុម័តគោលនយោបាយក្នុងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា (ICT) ដែលជាសក្តានុភាពដ៏មានសក្តានុពលសម្រាប់សេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍសង្គមដោយ (1) ការលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាទំនើបដើម្បីឆ្លើយតបទៅនឹងតម្រូវការបច្ចុប្បន្ននៅគ្រប់វិស័យទាំងអស់។ (2) ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាដើម្បីបំរើ និងបំពេញសេចក្តីត្រូវការប្រចាំថ្ងៃរបស់ប្រជាជនក្នុងរយៈពេលខ្លី។ (3) លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យានៅក្នុងវិស័យសាធារណៈ ដើម្បីផ្តល់ការឆ្លើយតបរហ័ស ប្រសិទ្ធភាព តម្លាភាពនិងអភិបាលកិច្ចល្អ (4) គោលនយោបាយ ICT

[18] យោងទៅតាមការប៉ាន់ប្រមាណអំពីការត្រៀមខ្លួនរបស់ ICT អាស៊ាន

កម្ពុជាអនុវត្តតាមឱកាសបែងចែកឌីជីថលផ្តោតលើរបៀបវារៈអភិវឌ្ឍន៍ស្ទួលប្រាំ នៃបណ្តាញទូទាំងតំបន់ ដោយដំណាក់កាលទី១ គឺរាជធានីភ្នំពេញ និងក្រសួង ដំណាក់កាលទី២ គឺនៅតាមបណ្តាខេត្ត ដំណាក់កាលទី៣ទៅដល់ថ្នាក់ស្រុក ដំណាក់កាលទី៤ ដល់ថ្នាក់ឃុំ និងដំណាក់កាលចុងក្រោយដល់កម្រិតភូមិ។

- ឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតវិស័យ ICT ដល់យុទ្ធសាស្ត្រចតុកោណដើម្បីអភិវឌ្ឍន៍កម្ពុជា ដំណាក់កាលទី២ ដោយរៀបចំវិធានការបច្ចេកទេសចំនួនប្រាំមួយ (1)ការវិនិយោគទៅនឹងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗខ្សែកាបអុបទិកទៅតំបន់ជនបទ (2) ស្នើសុំស្តង់ដារជាតិសម្រាប់ការកសាងផែនការ និងការប្រតិបត្តិការ នៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា (ប្រព័ន្ធស្តង់ដារ និងបទដ្ឋានសម្រាប់ការប្រើប្រាស់បច្ចេកវិទ្យាកុំព្យូទ័រនិងអ៊ីនធឺណិត) (3) ជំរុញ និងបង្កើនការផ្សាយប្រព័ន្ធ (4) ផ្តល់ឱកាសបើកចំហដល់វិស័យឯកជនសម្រាប់ការអភិវឌ្ឍ ICT (5) ការលើកកំពស់ធនធានមុស្សក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាសម្រាប់ការអនុវត្តអេឡិចត្រូនិចប្រសើរជាងមុន (6) ការបង្កើនការយល់ដឹងអំពី ICT សម្រាប់សាធារណជនទូទាំងប្រទេសតាមរយៈការរៀបចំកម្មវិធី ICT ពីសាលាបឋមសិក្សាដល់សាកលវិទ្យាល័យស្តីពីព័ត៌មានបច្ចេកវិទ្យា (IT) និងធ្វើឱ្យមានវឌ្ឍនភាពសាធារណៈ។[19]
- ឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ក្នុងកំឡុងឆ្នាំ២០០៦-២០១០ វាមានទិដ្ឋភាព និងវិស័យទាំងអស់នៃការអភិវឌ្ឍន៍របស់ជាតិរួមទាំងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍នៅគ្រប់ទិដ្ឋភាពទាំងអស់នៃអភិបាលកិច្ច និងរដ្ឋាភិបាល។ ចំពោះកំណើនវិស័យ ICT នៅកម្ពុជាក្នុងរយៈពេលវែងតើអ្វីទៅដែលប្រទេសកម្ពុជាតម្រូវការអាទិភាពរយៈពេលខ្លី មធ្យម និងរយៈពេលវែង? នោះគឺជាគំរោង ICT ដែលត្រូវការជាចាំបាច់ប្រជាជនកម្ពុជា អ្នកជាតិនិយម មន្ត្រីរាជការ អ្នករចនាគេហទំព័រ អ្នកប្រឹក្សាយោបល់បច្ចេកទេសប្រព័ន្ធវិស្វករផ្នែករឹង និងតម្រូវការជាក់លាក់មួយចំនួនផ្សេងទៀតដូចជា (1) ស្តង់ដាអន្តរជាតិភ្ជាប់នឹងអន្តរប្រតិបត្តិការ (2) ការបែងចែកឱ្យកាន់តែទូលំទូលាយនៃយូនីកូដខ្មែរ និងការអភិវឌ្ឍមាតិកា និងកម្មវិធីក្នុងតំបន់ (3) ការយល់ដឹងពីសន្តិសុខ និងការការពារពីវីរុស ការវាយប្រហារខុសច្បាប់។ ល។ (4) បង្កើនចំណេះដឹងកុំព្យូទ័រតាមរយៈការិយាល័យ និងប្រព័ន្ធអប់រំ (5) ដំណោះស្រាយចុងក្រោយដែលមានតំលៃសមរម្យដើម្បីទៅដល់ភូមិជនបទ។[20]

[19] សុន្ទរកថាសម្តេចតេជោ ហ៊ុន សែន ក្នុងពិធីបើកការដាក់ឱ្យប្រើប្រព័ន្ធអេឡិចត្រូនិកសម្រាប់ក្រុមប្រឹក្សារដ្ឋមន្ត្រីឆ្នាំ២០០៤។

[20] Miyata, UNDP 2006

- ឆ្នាំ២០០៩-២០១៣ មានកំណែទម្រង់រដ្ឋបាលតាមរយៈការលើកកម្ពស់បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាដើម្បីបម្រើប្រជាពលរដ្ឋ ដើម្បីធានាសុខុមាលភាពរបស់ពួកគេ និងវិបុលភាពរបស់ជាតិតាមរយៈរដ្ឋបាលសាធារណៈឱ្យក្លាយជាសេវាសាធារណៈ ដែលមានប្រសិទ្ធិភាពអ្នកផ្តល់សេវាសម្រាប់អ្នកទទួលសេវាកម្ម(ពលរដ្ឋ)[21]។

យោងតាមអាជ្ញាធរជាតិអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ជាតិ(NiDA) ដំណាក់កាលគម្រោងរដ្ឋាភិបាលអេឡិចត្រូនិកត្រូវបានបែងចែកជាបួនដំណាក់កាលគឺដំណាក់កាលទី១ (២០០០-២០០៤) ប្រព័ន្ធអេឡិចត្រូនិច AIS (ប្រព័ន្ធព័ត៌មានរដ្ឋបាល) ដំណាក់កាលទី២ (២០០៤-២០០៨) ការបង្កើត AIS ថ្នាក់ខេត្ត ដំណាក់កាលទី៣ (២០០៩-២០១២) ការបង្កើន AIS ខេត្ត និងដំណាក់កាលទី៤ (២០១៣-២០១៧) ការបង្កើន AIS នៅជនបទ។

### ២.១.២. អំពីការអនុវត្ត

គម្រោងប្រព័ន្ធគ្រប់គ្រងព័ត៌មានរដ្ឋបាលរបស់រដ្ឋាភិបាល(GAIS) ត្រូវបានរៀបចំ និងអនុវត្តដោយមានការចូលរួមសរុបពីក្រសួងនីមួយៗ និងសាលារាជធានីភ្នំពេញតាមរយៈតំណាងរបស់ខ្លួននៅក្នុងក្រុមការងារជាមួយលេខាធិការដ្ឋាន NiDA ជាចំនុចប្រសព្វ។[22]គម្រោង GAIS ត្រូវបានបង្កើតឡើងតាមរយៈកម្ចីសម្បទានពីរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ដោយមានមូលនិធិសមភាគីពីរាជរដ្ឋាភិបាលកម្ពុជាហើយមានរយៈពេលពីរឆ្នាំសម្រាប់ការអភិវឌ្ឍន៍ ដោយចាប់ផ្តើមនៅខែមេសា ឆ្នាំ២០០២ និងថែទាំពីរឆ្នាំដែលបានចាប់ផ្តើមនៅខែមេសា ឆ្នាំ២០០៤។ ដូចដែលបានលើកឡើងខាងលើនេះ គម្រោង GAIS គឺត្រូវតភ្ជាប់ និងបញ្ចូលកុំព្យូទ័រទៅក្នុងប្រតិបត្តិការការងាររបស់រដ្ឋាភិបាលដោយប្រើកម្មវិធីអនុវត្តជាក់ស្តែងចំនួនបួនគឺប្រព័ន្ធអេឡិចត្រូនិច (EAS) ការចុះឈ្មោះអចលនទ្រព្យ ការចុះឈ្មោះអ្នកស្នាក់នៅ និងការចុះឈ្មោះយានយន្ត ព្រមទាំងវត្ថុមានរបស់រដ្ឋាភិបាលផងដែរ។

គម្រោងនៃប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋាភិបាល(GAIS) បានរួមចំណែកយ៉ាងធំធេងដល់គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិទាំងមូលជាពិសេសយុទ្ធសាស្ត្រចតុកោណ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ប៉ុន្តែគួរឱ្យភ្ញាក់ផ្អើលវាត្រូវបានគេមើលរំលងដោយប្រទេសម្ចាស់ជំនួយ និងស្ថាប័នម្ចាស់ជំនួយ។ គម្រោងនេះសម្រេចបាននូវគោលបំណងច្បាស់លាស់នៃការបង្កើតប្រាក់ចំណូល រូបភាព និងសេវាកម្មល្អរបស់រដ្ឋាភិបាល។

ការចុះបញ្ជីទាំងបីគឺ អចលនទ្រព្យ អ្នកតាំងទីលំនៅ និងរថយន្តបានផ្តល់ឱ្យអាជ្ញាធរនូវឧបករណ៍ទំនើប និងព័ត៌មានច្បាស់លាស់ដើម្បីប្រមូលពន្ធត្រឹមត្រូវសមស្រប និងតម្លាភាពដើម្បី

[21] A Key to Good Governance in Cambodia, (Vol 5, No.1,2015, author: PHO Kevreaksmey
[22] http://www.nida.gov.kh

កាត់បន្ថយ ឬទប់ស្កាត់លទ្ធភាពឧក្រិដ្ឋកម្មទាក់ទងនឹងការប្លន់រថយន្ត ឬការរំលោភដីធ្លី និងដើម្បីបម្រើឱ្យសាធារណៈជនបានល្អប្រសើរ។ កម្មវិធីទាំងបីនេះឆ្លើយតបដោយផ្ទាល់ទៅស្នូលនៃយុទ្ធសាស្ត្រចតុកោណ ដែលផ្តោតលើអភិបាលកិច្ចល្អ។ លើសពីនេះទៅទៀតកម្មវិធីទាំងនេះឆ្លើយតបដោយផ្ទាល់ទៅផ្នែកទីមួយនៃយុទ្ធសាស្ត្រចតុកោណ ដែលរួមមានកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើពុករលួយរដ្ឋបាលសាធារណៈ និងវិមជ្ឈការ។ ផ្នែកទីពីរនៃយុទ្ធសាស្ត្រចតុកោណ ដែលរួមមានសន្តិភាព ស្ថេរភាព និងសណ្តាប់ធ្នាប់ ភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធ។ ផ្នែកទីបីនៃយុទ្ធសាស្ត្រចតុកោណ ដែលរួមមានកំណើនវិស័យឯកជន និងការងារស្តារឡើងវិញ និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស។ ផ្នែកទីបួននៃយុទ្ធសាស្ត្រចតុកោណ ដែលរួមបញ្ចូលទាំងផលិតភាពប្រសើរឡើងពង្រឹងវិស័យឯកជន និងការវិនិយោគលើកកម្ពស់សហគ្រាសខ្នាតតូច និងមធ្យមបង្កើតការងារ និងបង្កើនលក្ខខណ្ឌការងារបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន និងសមភាពយេនឌ័រ។

ប្រព័ន្ធអនុម័តអេឡិចត្រូនិចបានផ្តល់ជូនបុគ្គលិករដ្ឋាភិបាលនូវឧបករណ៍ ដើម្បីធ្វើការដោយឆ្លាតវៃមិនពិបាកនិងដើម្បីបំរើដល់សាធារណជនឱ្យបានកាន់តែប្រសើរ។ ប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិច (EAS)បានអនុញ្ញាតឱ្យឯកសារផ្ញើចេញ-ចូល ត្រូវបានអនុម័តរក្សាទុកនិងទាញយកយ៉ាងងាយស្រួល។ ជាថ្មីម្តងទៀត EAS ឆ្លើយតបដោយផ្ទាល់ទៅស្នូលនៃយុទ្ធសាស្ត្រចតុកោណដែលផ្តោតលើអភិបាលកិច្ចល្អ។ ម្យ៉ាងវិញទៀតគេហទំព័ររបស់ រដ្ឋាភិបាល បានផ្តល់សេវាកម្មព័ត៌មានរបស់រដ្ឋាភិបាលដល់សាធារណជន ដែលនាំឱ្យមានរូបភាពកាន់តែប្រសើរ។ ជាថ្មីម្តងទៀតគេហទំព័ររបស់រដ្ឋាភិបាល និងមាតិការបស់វាឆ្លើយតបដោយផ្ទាល់ទៅនឹងស្នូលនៃ យុទ្ធសាស្ត្រចតុកោណ ដែលផ្តោតលើអភិបាលកិច្ចល្អនេះផងដែរ។[23]

ការអនុវត្តតាម ប្រព័ន្ធអេឡិចត្រូនិច នេះគួរអង្គសំខាន់បន្ថែមទៀតនោះគឺសេវាអ៊ីនធឺណិត និងអ៊ីម៉ែល ដែលវាបានផ្តល់ជូនបុគ្គលិករដ្ឋាភិបាលនូវឧបករណ៍ចាំបាច់ ដើម្បីធ្វើការស្រាវជ្រាវ និងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពជាមួយសមភាគីរបស់ពួកគេ ដែលនាំឱ្យមានសេវាសាធារណៈកាន់តែប្រសើរឡើង។ ជាថ្មីម្តងទៀតសេវាអ៊ីធឺណិតឆ្លើយតបដោយផ្ទាល់ទៅស្នូលនៃយុទ្ធសាស្ត្រចតុកោណ ដែលផ្តោតលើអភិបាលកិច្ចល្អ។ លើសពីនេះសេវាអ៊ិនធឺណិត ឆ្លើយតបដោយផ្ទាល់ទៅផ្នែកទីពីរនៃយុទ្ធសាស្ត្រចតុកោណ ដែលរួមបញ្ចូលទាំងសមាហរណកម្មក្នុងតំបន់ និងអន្តរជាតិ ផ្នែកទីបីនៃយុទ្ធសាស្ត្រចតុកោណ ដែលរួមមានការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធាន

[23] http://www.adb.org

មនុស្ស និងផ្នែកទីបួននៃយុទ្ធសាស្ត្រចតុកោណ ដែលរួមមានការបង្កើនផលិតភាព និងការធ្វើពិពិធកម្មការបង្កើតការងារ និងលក្ខខណ្ឌការងារប្រសើរឡើងតាមរយៈបច្ចេកវិទ្យាព័ត៌មាន ការបង្កើនគុណភាពអប់រំ និងសមភាពយេនឌ័រកាន់តែច្រើន។[24]

វត្តមានរបស់រដ្ឋាភិបាលនៅលើគេហទំព័រវែបសាយ នឹងពង្រឹងការផ្សព្វផ្សាយជាសាធារណៈរបស់ជាតិទៅកាន់ពិភពខាងក្រៅ និងពង្រឹងសេវាព័ត៌មានសាធារណៈសម្រាប់ប្រជាជនកម្ពុជា ដែលនឹងនាំឱ្យមានរូបភាព និងសេវាកម្មរបស់រដ្ឋាភិបាលកាន់តែប្រសើរឡើង។ ជាមួយគ្នានេះយើងបានឃើញរួចមកហើយនូវការអនុវត្តនានា ដែលនាំឱ្យមានភាពងាយស្រួល និងទទួលបានផលប្រយោជន៍ជាច្រើនដូចជា៖ ការចុះបញ្ជីឱ្យបានត្រឹមត្រូវអំពីអចលនទ្រព្យអ្នករស់នៅ និងយានយន្តនឹងធានាថារដ្ឋាភិបាលនឹងអាចប្រមូលពន្ធអចលនទ្រព្យពន្ធលើប្រាក់ចំណូល និងពន្ធរថយន្តដោយយុត្តិធម៌ និងត្រឹមត្រូវ ហើយការចុះបញ្ជីយានយន្តដែលរួមមានការចុះបញ្ជីរថយន្តនិងម៉ូតូកំពុងដំណើរការ និងត្រូវបានគេប្រើយ៉ាងទូលំទូលាយ ជាមួយគ្នានេះកិច្ចការការចុះបញ្ជីអចលនទ្រព្យអ្នករស់នៅ និងយានយន្តគឺជាការងារធម្មតាដែលបុគ្គលម្នាក់ៗរស់នៅក្នុងទីក្រុងត្រូវតែឆ្លងកាត់រាល់ពេលមានការផ្លាស់ប្តូរស្ថានភាពបច្ចុប្បន្ន។ ការចុះបញ្ជីតាមប្រព័ន្ធកុំព្យូទ័រជួយសម្របសម្រួលដំណើរការចុះបញ្ជី និងធ្វើឱ្យជីវិតរបស់ពួកគេកាន់តែងាយស្រួលដោយមិនចាំបាច់ឈរ និងរង់ចាំក្នុងខ្សែ ដែលចំណាយពេលវេលាដ៏មានតម្លៃរបស់ពួកគេ ហើយអាចយកពេលវេលាទៅធ្វើសកម្មភាព ដែលរកប្រាក់ចំណេញបានច្រើនផ្សេងពីនេះថែមទៀត។

- ការចុះបញ្ជីអចលនទ្រព្យ និងការចុះបញ្ជីយានយន្តមានសារៈសំខាន់សំរាប់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។
  - ទី១៖ វាផ្តល់នូវសន្តិភាពដល់ប្រជាជន ដែលពួកគេត្រូវបានចុះឈ្មោះហើយត្រៀមខ្លួនទទួលសេវាសាធារណៈនៅពេលដែលមានតម្រូវការ ហើយទ្រព្យសម្បត្តិរបស់ពួកគេរួមទាំងអចលនទ្រព្យ និងយានយន្តត្រូវបានចុះបញ្ជីស្របច្បាប់ និងត្រូវបានការទទួលស្គាល់និងការពារដោយច្បាប់ផងដែរ។ ប្រព័ន្ធនេះក៏ជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយសម្រាប់អាជ្ញាធរមូលដ្ឋានក្នុងការប្រយុទ្ធ និងទប់ស្កាត់ឧក្រិដ្ឋកម្មទាក់ទងនឹងអចលនទ្រព្យ។
  - ទី២៖ ភស្តុតាងបានបង្ហាញថាការចុះបញ្ជីត្រឹមត្រូវនៃអចលនទ្រព្យ លំនៅដ្ឋាន និងរថយន្តបានកើនឡើងនៅក្នុងប្រាក់ចំណូលរបស់រដ្ឋាភិបាល។
- ការផ្លាស់ប្តូរឯកសារអេឡិចត្រូនិចរវាងនាយកដ្ឋានរដ្ឋ និងក្រសួងនឹងកាត់បន្ថយការពន្យារពេលដែលមិនចាំបាច់ និងផ្តល់លទ្ធផលល្អដល់សេវាសាធារណៈកម្ពុជា។

[24] http://www.undg.org

- រដ្ឋាភិបាលនៅលើវែបសាយ អនុញ្ញាតឱ្យពួកគេទទួលបានសេវាព័ត៌មានសាធារណៈនៅពេលវេលាដ៏ងាយស្រួលរបស់ពួកគេដោយមិនចាំបាច់ខ្ជះខ្ជាយពេលវេលារបស់ពួកគេ ដើម្បីទៅកាន់ការិយាល័យរដ្ឋាភិបាលនីមួយៗ។
- ការតភ្ជាប់នេះអនុញ្ញាតឱ្យការិយាល័យរដ្ឋាភិបាលទាំងអស់ ទាក់ទងតាមអេឡិចត្រូនិចនិងដើម្បីចូលប្រើអ៊ិនធឺណេត(Internet) និងអ៊ីម៉ែល(Email) ក្នុងភាពងាយស្រួលរបស់ពួកគេ។

ជាក់ស្តែងបើយើងក្រឡេកមកមើលការដាក់ឱ្យអនុវត្តបច្ចុប្បន្ន ក្នុងកិច្ចការងារបម្រើសេវានានាជាពិសេសសេវាសាធារណៈរបស់រាជរដ្ឋាភិបាល ដែលមានក្រសួង ស្ថាប័ន និងអង្គភាពចំណុះនានាជាសេនាធិការនោះ បានមានប្រតិបត្តិការយ៉ាងល្អប្រសើរ និងរីកចម្រើនជាបន្តបន្ទាប់ក្នុងការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចនេះ និងបានឆ្លើយតបបានទាន់ពេលវេលានូវតម្រូវការជាមូលដ្ឋាន និងចាំបាច់របស់ប្រជាពលរដ្ឋគ្រប់ៗរូប។

ការប្រតិបត្តិតាមប្រព័ន្ធអេឡិចត្រូនិច ខាងក្រោមជាការអនុវត្តមួយចំនួនដោយក្រសួង ស្ថាប័ន អង្គភាព នានានៅកម្ពុជា៖

- ក្រសួងមុខងារសាធារណៈ៖ បានដាក់ចេញនូវប្រព័ន្ធនៃការដាក់ពាក្យ និងចុះឈ្មោះចូលរៀនសាកល្បងតាមប្រព័ន្ធអនឡាញនៅសាលាភូមិន្ទរដ្ឋបាល(SMS:School Management System)[25], ប្រព័ន្ធនៃការគ្រប់គ្រងចរន្តឯកសារ, ការធ្វើលំហាត់អនុវត្តតាមអនឡាញ និងស្វែងរកឯកសារ (LMS: Learning Management System)[26] របស់សាលាភូមិន្ទរដ្ឋបាល
- ក្រសួងអប់រំ យុវជន និងកីឡា៖ បានដាក់ចេញនូវកម្មវិធីឆ្លើយសំណួរ និងតេស្ដ៍សមត្ថភាពសម្រាប់សិស្សត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ[27]
- ក្រសួងពាណិជ្ជកម្ម៖ ការចុះបញ្ជីពាណិជ្ជកម្មកាន់តែងាយស្រួលជាមួយការប្រើប្រាស់តាមប្រព័ន្ធអនឡាញ និងឆាប់រហ័ស ឆ្លើយតបបានទាន់ពេលវេលា និងកាន់តែប្រសើរជាងមុនដល់ប្រជាពលរដ្ឋ។[28]
- ក្រសួងសេដ្ឋកិច្ច៖ ការបង់ពន្ធនានា តាមរយៈធនាគារអេស៊ីលីដា ឬតាមរយៈទូរសព្ទដៃដែលបានផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋយ៉ាងច្រើន, ក្រសួងបាន បង្កើតកម្មវិធីស្វែងរកសម្រាប់មាតិកាថវិកា (ចំណាត់ថ្នាក់សេដ្ឋកិច្ច ចំណាត់ថ្នាក់ភូមិសាស្រ្ត ចំណាត់ថ្នាក់អង្គភាពប្រតិបត្តិ និងចំណាត់ថ្នាក់កម្មវិធី[29]។

[25] http://sms.era.gov.kh/
[26] http://lms.era.gov.kh/moodle/
[27] http://lms.moeys.org/
[28] http://www.businessregistration.moc.gov.kh/
[29] https://itunes.apple.com/kh/app/mef-bc-and-coa/id1144759706?mt=8

- ក្រសួងសាធារណៈការ និងដឹកជញ្ជូន៖ ក្រសួងបានដាក់ឱ្យអនុវត្តការប្តូរប័ណ្ណបើកបរដែលផុតកំណត់តាមរយៈប្រព័ន្ធអេឡិចត្រូនិច គឺបានផ្តល់ភាពងាយស្រួល និងរហ័សបំផុត ជូនដល់ប្រជាពលរដ្ឋគ្រប់រូប។
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)៖ សម្រាប់អាណត្តិទី៥ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ បានរៀបចំឱ្យមានការចុះឈ្មោះតាមប្រព័ន្ធកុំព្យូទ័រ នៃអង្គបោះឆ្នោតគ្រប់រូបនៅទូទាំងប្រទេស ដែលជាសញ្ញាណបង្ហាញពីការវិវត្តន៍ទៅភាពល្អប្រសើរ និងពង្រឹងលទ្ធិប្រជាធិបតេយ្យកាន់តែខ្លាំងបន្ថែមទៀតនៅកម្ពុជា ហើយជួយឱ្យមានការបោះឆ្នោត និងសម្រេចចិត្តពីប្រជាពលរដ្ឋដោយតម្លាភាព យុត្តិធម៌ សេរី និងត្រឹមត្រូវផងដែរ។

ការអនុវត្តដែលបានលើកឡើងខាងលើ នៃការអនុវត្តប្រព័ន្ធអេឡិចត្រូនិចនេះ ជាការអនុវត្តរបស់ក្រសួង ស្ថាប័ន មួយចំនួនប៉ុណ្ណោះក្នុងចំណោមការអនុវត្តយ៉ាងទូលំទូលាយនានានៅកម្ពុជា។ ជាមួយគ្នានេះដែរកម្ពុជាក៏បានអនុម័តច្បាប់មួយចំនួនផងដែរ ក្នុងរួមមានច្បាប់ស្តីពី ទូរគមនាគមន៍ ដែលមានគោលបំណងច្បាស់លាស់ក្នុងការចូលរួមអនុវត្ត និងពង្រឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានៅកម្ពុជា គឺធានាការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញ និងការផ្តល់សេវាទូរគមនាគមន៍ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព គុណភាព ភាពអាចទុកចិត្តបាន និងថ្លៃសមរម្យ ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍ សង្គម និងសេដ្ឋកិច្ច។ ច្បាប់នេះផងដែរក៏បានធានាការចូលរួម និងលើកទឹកចិត្តដល់វិស័យឯកជន ក្នុងការអភិវឌ្ឍវិស័យទូរគមនាគមន៍ និងការប្រកួតប្រជែងស្របច្បាប់ និងប្រកបដោយប្រសិទ្ធភាព និងធានាការការពារអ្នកប្រើប្រាស់ និងជំរុញការគៀរគរចំណូលថវិកាជាតិផងដែរ។ ច្បាប់នេះមានគោលដៅកំណត់សំខាន់ៗមួយចំនួន ដែលក្នុងនោះបានកំណត់អំពីសមត្ថកិច្ចរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ហើយមានវិសាលភាពអនុវត្តចំពោះគ្រប់ប្រតិបត្តិការទូរគមនាគមន៍ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែវិស័យសន្តិសុខ និងការពារជាតិ។[30]

ក្នុងគោលដៅធ្វើកំណែទម្រង់សេវាអប់រំនៅកម្ពុជាឱ្យមានប្រសិទ្ធភាពខ្ពស់ និងឈានចូលទៅរកបរិបទថ្មីនៃសាកលភាវូបនីយកម្ម ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំវេទិកាពិគ្រោះយោបល់ជាមួយអាជ្ញាធរជាតិអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានវិទ្យា ក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អង្គការអន្តរជាតិនានាជាបន្តបន្ទាប់ទាំងនៅក្នុងប្រទេស និងក្នុងតំបន់ ព្រមទាំង ឆន្ទៈ

[30] ច្បាប់ស្តីពីទូរគមនាគមន៍កម្ពុជា ទំព័រទី៣

និងការខិតខំប្រឹងប្រែងរបស់មន្ត្រីបច្ចេកទេសជាន់ខ្ពស់នៃក្រសួងអប់រំ យុវជន និងកីឡា សម្រេចបានគោលនយោបាយយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ក្នុងវិស័យអប់រំនៅកម្ពុជា។ គោលនយោបាយនេះសំដៅសង្កត់ធ្ងន់ផងដែរលើការពង្រឹងការងារអប់រំក្រៅប្រព័ន្ធ ការសិក្សាពីចម្ងាយ ការបណ្តុះបណ្តាលជំនាញ ការបង្កើនគុណភាពអប់រំនៅមធ្យមសិក្សាទុតិយភូមិ និងក្រោយមធ្យមសិក្សាតាមរយៈបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ដែលជាតម្រូវការក្នុងការ បំពេញអាជីពនៅក្នុងសង្គមផ្អែកលើពុទ្ធិ និងការកសាងភាពជាដៃគូឱ្យបានល្អរវាងស្ថាប័នរាជរដ្ឋាភិបាល សហគមន៍ វិស័យឯកជន អង្គការជាតិ និងអន្តរជាតិដែលពាក់ព័ន្ធ។ គោលនយោបាយ យុទ្ធសាស្ត្របច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍នេះ បានបញ្ជាក់ច្បាស់អំពីការជួយគាំទ្រ និង លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន សម្រាប់ជនជួបការលំបាក។

គោលបំណង ៣ចំណុចសំខាន់ធំៗ របស់ គោលនយោបាយ យុទ្ធសាស្ត្របច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍នេះគឺទី១៖ លើកកម្ពស់ការចូលសិក្សានៅកម្រិតអប់រំមូលដ្ឋាន សម្រាប់ទាំងអស់ គ្នាទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធដោយប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ជាឧបករណ៍មួយនៅក្នុងចំណោមឧបករណ៍សំខាន់ៗសម្រាប់រៀន សម្រាប់ការបង្រៀន សម្រាប់ការសិក្សាស្រាវជ្រាវ និងសម្រាប់ចែករំលែកព័ត៌មាន។ ទី២៖លើកកម្ពស់គុណភាពអប់រំមូលដ្ឋានឱ្យបានប្រសើរជាងមុន ដោយជំរុញការរៀនដោយខ្លួនឯងពេញមួយជីវិត ជាពិសេសនៅកម្រិតក្រោយបឋមសិក្សា។ ទី៣៖ បង្កើនសមត្ថភាពភ្ជាប់ទំនាក់ទំនងជាមួយពិភពលោក ដោយមានកម្លាំងពលករដែលមានជំនាញបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ សម្រាប់ឆ្លើយតបចំពោះតម្រូវការការងារ ចេះប្រើប្រាស់ជំនាញទាំងនោះនៅក្នុងសង្គមផ្អែកលើពុទ្ធិ។ ប្រការទាំងនេះនឹងធានាថាកម្ពុជាពិតជាអាចប្រជែងបានទាំងថ្នាក់តំបន់ និងសកល។[31]

ជាមួយគ្នានេះកម្ពុជាបានដាក់ចេញបន្ថែមនូវគោលនយោបាយជាតិ ICT របស់កម្ពុជា ដែលចក្ខុវិស័យជាតិរបស់ ICT នៅកម្ពុជាត្រូវបានដាក់ដើម្បីមានមូលដ្ឋានលើចំណេះដឹង និងព័ត៌មានមួយដែលមានការប្រកួតប្រជែងទូទាំងពិភពលោក។ សង្គមដែលមានសមត្ថភាពក្នុងការផ្តល់នូវដំណោះស្រាយដែលមានមូលដ្ឋានលើ ICT ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព រួមបញ្ចូលសកម្មភាពបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យានៅក្នុងរដ្ឋាភិបាល (សាធារណៈ) និងវិស័យឯកជន នោះនឹងធានាបាននូវជម្រើសសេដ្ឋកិច្ច និងសង្គមតាមរយៈការសម្រេចបាននូវកិច្ចព្រមព្រៀងក្របខ័ណ្ឌសហគមន៍ ដែលអាចជួយលើកកម្ពស់ការយល់ដឹងអំពីការឡើងកំដៅនៃ

[31] គោលនយោបាយ និងយុទ្ធសាស្ត្រប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ក្នុងការអប់រំនៅកម្ពុជា

ភព ផែនដី ដើម្បីផ្តល់នូវក្របខ័ណ្ឌអំណោយផល (ច្បាប់ និងបទប្បញ្ញត្តិ) សម្រាប់សាធារណៈជន និងការ វិនិយោគហេដ្ឋារចនាសម្ព័ន្ធអេឡិចត្រូនិកគួរតែត្រូវបានបង្កើតឡើងដោយការជំរុញកំណើន ជាតិ ICT និងការបង្កើតអ្នកជំនាញការផ្នែកបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាក្នុងតំបន់។

យើងអាចសម្រេចបាននូវគោលបំណងរបស់ ICT ដោយការអភិវឌ្ឍន៍ដូចជា៖

(1) ការបង្កើត និងការផ្តល់នូវក្របខ័ណ្ឌនិងគោលនយោបាយជាតិ ដែលនឹងផ្តល់លទ្ធភាព ដល់វិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានវិទ្យាឆ្ពោះទៅរកការសម្រេចបានគោលដៅអភិវឌ្ឍន៍ ជាតិ។

(2) ការផ្តល់សេវា និងលទ្ធភាពប្រើប្រាស់ជាសកលនូវមធ្យោបាយព័ត៌មាន និងទំនាក់ទំនង នៅក្នុងប្រទេស ដែលនឹងជៀសមិនរួចនាំឆ្ពោះទៅរកពិភពលោកនៃការប្រកួតប្រជែងក្នុងផលិតកម្ម និងផលិតភាព។

(3) ប្រែក្លាយកម្ពុជាទៅជាសង្គម ដែលផ្អែកលើចំណេះដឹងការអនុវត្ត បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាត្រឹមត្រូវទៅតាមគោលនយោបាយជាតិស្តីពីបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាននៃ ប្រទេសកម្ពុជាឱ្យបានឈានដល់កម្រិត៖ (ក) ក្របខ័ណ្ឌច្បាប់ និងបទបញ្ញានឹងលើកកម្ពស់ការប្រើ ប្រាស់ ICT ដើម្បីលើកកម្ពស់តម្លាភាព ការប្រកួតប្រជែង និងប្រសិទ្ធភាពក្នុងវិស័យសាធារណៈ និង ឯកជន។ អាជ្ញាធរអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ជាតិ (NiDA) នឹងធ្វើជាអ្នកផ្សព្វផ្សាយ និងជា និយ័តករនៃសេវាកម្ម ICT តែម្តង។ NiDA[32]បានលើកទឹកចិត្តឱ្យភ្នាក់ងារទាំងអស់ចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ផែនការលើកកម្ពស់ឥតឈប់ឈរ នៃវិស័យ ទូរគមនាគមន៍ និងវិស័យ ICT ដែលពាក់ព័ន្ធដទៃទៀត និងគាំទ្រដល់ការប្រើប្រាស់អ៊ីនធឺណិត និង សេវាកម្មតម្លៃបន្ថែម។ (ខ) ការអភិវឌ្ឍសមត្ថភាពរបស់មនុស្ស និងគាំទ្រដល់ការប្រើប្រាស់បច្ចេក វិទ្យាគមនាគមន៍ ព័ត៌មានវិទ្យាសម្រាប់ការអប់រំផ្លូវការ និងក្រៅផ្លូវការ រួមបញ្ចូលទាំងការអភិវឌ្ឍ ជំនាញ និងការរៀនសូត្រសម្រាប់មនុស្សពេញវ័យមិនគិតពីភេទ អាយុ ពណ៌សម្បុរ ជនពិការ ឬទី តាំងនៅកម្ពុជាឡើយ។ វានឹងមិនត្រឹមតែប្រគល់សិទ្ធិដល់ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ដើម្បីផ្តល់នូវបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាជាមូលដ្ឋាននោះទេ តែការបណ្តុះបណ្តាលដល់គ្រូ ទាំងអស់ក៏ត្រូវលើកកម្ពស់ និងគាំទ្រមជ្ឈមណ្ឌលព័ត៌មានសហគមន៍បន្ថែមទៀតនៅក្នុងប្រទេស។ លើសពីនេះទៅទៀតវិទ្យុ និងទូរទស្សន៍ ដែលជាឧបករណ៍បង្រៀន និងរៀននឹងត្រូវបានតម្លើងឋានៈ សំរាប់ប្រជាពលរដ្ឋទាំងអស់ និងបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា កម្មវិធីសិក្សានៅក្នុងប្រព័ន្ធ

[32] អាជ្ញាធរអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ជាតិ

អប់រំត្រូវបានដាក់ឱ្យប្រើប្រាស់ទូទាំងប្រទេស។ (គ) ការអភិវឌ្ឍមាតិកានឹងគាំទ្រដល់ប្រព័ន្ធអេឡិចត្រូនិចអេឡិចត្រូនិច នឹងប្រមូលធនធានសម្រាប់ការពង្រីកដល់គ្រប់ខេត្តក្នុងប្រទេស។ ការណែនាំគោលនយោបាយសមស្របនឹងត្រូវបានបង្កើតឡើងដើម្បីលើកទឹកចិត្តដល់ភ្នាក់ងារនីមួយៗ លើកកម្ពស់គុណភាពមាតិកានៅលើប្រព័ន្ធ ICT ។ រដ្ឋាភិបាលនឹងគាំទ្រ និងលើកទឹកចិត្តទីភ្នាក់ងាររបស់ខ្លួនឱ្យអភិវឌ្ឍប្រព័ន្ធកម្មវិធីបណ្តាញនីមួយៗ។ NiDA នឹងត្រួតពិនិត្យលើស្តង់ដារនៃប្រព័ន្ធកម្មវិធីទាំងនេះដោយបញ្ជាឱ្យដាក់បញ្ចូលក្នុងឆ័ត្ររបស់ប្រព័ន្ធអេឡិចត្រូនិចអេឡិចត្រូនិច (E-Government)។ រាជរដាភិបាលកម្ពុជានឹងបន្តតាមដាន និងធានាថាព័ត៌មានផ្លូវការ និងមាតិកាអំពីប្រទេសគឺដូចគ្នា និងត្រឹមត្រូវ។ រាជរដ្ឋាភិបាលកម្ពុជាគួរតែអភិវឌ្ឍ និងគាំទ្រដល់ប្រព័ន្ធតួអក្សរដែលមានមូលដ្ឋានលើខ្មែរយូនីកូដដែលត្រូវបានអនុម័តកម្មវិធី ICT។ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តដើម្បីពង្រីកសមត្ថភាពរបស់តំបន់ជនបទក្នុងការអភិវឌ្ឍ និងគ្រប់គ្រងមាតិកានៃប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាហើយរដ្ឋាភិបាលនឹងបង្កើតឧបករណ៍សមស្រប និងច្បាប់ដើម្បីត្រួតពិនិត្យ គ្រប់គ្រងរាល់ការប្រើប្រាស់ ICT មិនសមរម្យដូចជាវីរុសឥតបានការ ការលួចបន្លំលើអ៊ិនធឺណិត ការបន្លំចម្លងការរំលោភបំពានសិទ្ធិ ការចូលដោយគ្មានការអនុញ្ញាត ការបដិសេធសេវាកម្ម ការបំពានសិទ្ធិឯកជន ការបំពានមាតិកាប្រព័ន្ធផ្សព្វផ្សាយ និងប្រការមិនសមរម្យនានា។

រាជរដ្ឋាភិបាលកម្ពុជានឹងរៀបចំប្រព័ន្ធរាយការណ៍ស្តង់ដារសម្រាប់សកម្មភាពសេវាសាធារណៈទាំងអស់។ (ឃ) ហេដ្ឋារចនាសម្ព័ន្ធ ICT រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តដំឡើង និងធ្វើឱ្យប្រសើរឡើងនូវ ICT ដែលអាចទុកចិត្តបាន និងសមស្របហេដ្ឋារចនាសម្ព័ន្ធនៅទូទាំងប្រទេស ដែលវានឹងជំរុញយ៉ាងសកម្មដល់វិស័យឯកជន និងការវិនិយោគបរទេសនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ICT និងបង្កើតមជ្ឈមណ្ឌលព័ត៌មានបណ្តាញរបស់កម្ពុជា។ NiDA នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា ក្រុមហ៊ុនខេនណេត និងការិយាល័យមជ្ឈមណ្ឌលព័ត៌មានបណ្តាញអាស៊ីប៉ាស៊ីភិច (APNIC) ដើម្បីអនុវត្ត និងគ្រប់គ្រងសកម្មភាពនេះ។ រាជរដ្ឋាភិបាលនឹងបង្កើតគោលនយោបាយគាំទ្រលើផលិតកម្មក្នុងស្រុកផ្នែករឹង ICT។

## ២.២. ចក្ខុវិស័យរបស់កម្ពុជា

ការអនុវត្តគម្រោងនៃប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋាភិបាល(GAIS) ការផ្តល់អ៊ិនធឺណិត និងការប្រើអ៊ីម៉ែលគឺជាជំហានដ៏ធំមួយឆ្ពោះទៅរកកំណែទម្រង់របស់រដ្ឋាភិបាល។ ប្រទេសម្ចាស់ជំនួយ និងស្ថាប័ននានាបានរៀបចំសិក្ខាសាលាបន្ទាប់ពីសិក្ខាសាលាកំណែទម្រង់រដ្ឋបាល នៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំ ប៉ុន្តែពួកគេមិនបានកត់សម្គាល់ពីជំហានដែលរដ្ឋាភិបាលបាន

អនុវត្តនៅក្នុងកិច្ចប្រឹងប្រែងកំណែទម្រង់នេះ។ ការអភិវឌ្ឍ ការផ្គត់ផ្គង់ និងការបណ្តុះបណ្តាលជាទូទៅសម្រាប់គម្រោង GAIS បានបង្កើន និងអភិវឌ្ឍសមត្ថភាពរបស់រដ្ឋាភិបាល និងបានក្លាយជាកត្តាជំរុញដល់ការបង្កើតឧស្សាហកម្មបច្ចេកវិទ្យាព័ត៌មានថ្មីស្របទៅ នឹងយុទ្ធសាស្ត្រចតុកោណទីបួននៃរាជរដ្ឋាភិបាលកម្ពុជា ដែលរួមមានការបង្កើនផលិតភាព និងការធ្វើពិពិធកម្ម ការបង្កើតការងារនិងការកែលំអលើលក្ខខណ្ឌការងារផ្សេងទៀត លើសពីនេះទៅទៀតគម្រោង GAIS បាននាំឱ្យមានការកែសម្រួល និងការអនុម័ត Unicode standard Unicode 1 និងការធ្វើឱ្យទាន់សម័យនៃក្តារចុចខ្មែរផងដែរ។

ចក្ខុវិស័យបន្ទាប់របស់កម្ពុជា គឺគោលនយោបាយជាតិបច្ចេកវិទ្យាគមនាគមន៍ជាតិឆ្នាំ២០១៥ (ឆ្នាំនៃសមាហរណកម្មអាស៊ាន) មានគោលបំណងសម្រេចឱ្យបាននូវចំណុចដូចខាងក្រោម[33]

- ផ្តល់ក្របខណ្ឌក្នុងសហគមន៍ដល់ពលរដ្ឋ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីលើកទឹកចិត្តក្នុងការចូលរួមអភិវឌ្ឍសមត្ថភាពបន្ថែម។
- លើកកម្ពស់កម្រិតយល់ដឹងថ្នាក់ជាតិអំពី ICT ទាក់ទងនឹងតួនាទី និងសក្តានុពលនេះ។
- សង្កត់ធ្ងន់ទៅលើការអភិវឌ្ឍប្រកបដោយនិរន្តរភាពក្នុងការផ្តល់អំណាចដល់ប្រជាជន និងក្នុងការពង្រឹងអភិបាលកិច្ច។
- បង្កើតវប្បធម៌នៃការរៀនពេញមួយជីវិតដើម្បីបង្កើនសក្តានុពលដែលមានស្រាប់របស់ប្រជាជនកម្ពុជា និងពន្លឿនការបង្កើតថ្មីដើម្បីអភិវឌ្ឍប្រព័ន្ធផ្អែកលើចំណេះដឹង។
- កាត់បន្ថយគម្លាតយ៉ាងទូលំទូលាយនៅក្នុងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា រវាងប្រជាជនដែលរស់នៅក្នុងរាជធានី និងអ្នកដែលនៅតាមបណ្តាខេត្ត តំបន់ជនបទ ដែលជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងការបែងចែកឌីជីថលដែលមានស្រាប់ លទ្ធភាពទទួលបានព័ត៌មាន (ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាននៅទូទាំងប្រទេស)។
- បង្កើនការប្រកួតប្រជែងនៃឧស្សាហកម្មជាតិរបស់កម្ពុជា ជាមួយនឹងការបង្កើតឱ្យបានគ្រប់គ្រាន់នូវបរិយាកាសធុរកិច្ច និងលើកកម្ពស់គុណភាពជីវិត និងលទ្ធភាពទទួលបានរបស់ប្រជាជនកម្ពុជា សេវាកម្មងាយស្រួលតាមរយៈការផ្សព្វផ្សាយកម្មវិធី និងការអនុវត្តបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាសមស្រប។
- លើកទឹកចិត្តដល់ការអភិវឌ្ឍន៍ឧស្សាហកម្មបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាជាតិ ដោយសម្របសម្រួលការអនុម័តជាទូទៅ ការអនុវត្តន៍បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា។

[33] NiDA, អាជ្ញាធរជាតិទទួលបន្ទុកការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាឆ្នាំ២០១៤

- ផ្តល់នូវចំណុចទទួលបាន ICTs នៅគ្រប់វិស័យ និងអនុវត្ត ICTs ដែលមានភាពសមស្រប ជាមួយនឹងប្រសិទ្ធិភាពចំណាយ។
- កាត់បន្ថយចំណាយរដ្ឋបាលសាធារណៈ និងបង្កើនគុណភាពសេវាសាធារណៈនៃអភិបាលកិច្ចកម្ពុជាតាមរយៈការអនុវត្ត ICT។
- បញ្ចូលការអភិវឌ្ឍធនធានមនុស្សក្នុងមូលដ្ឋានចាំបាច់ សម្រាប់ការទទួលយក ICT និងឧស្សាហកម្មជាតិ ICT ។
- អនុវត្តកម្មវិធី ស្ត្រីក្នុងការអភិវឌ្ឍន៍ នៅក្នុងវិសាលភាពនៃ ICT។
- ពង្រឹងការយល់ដឹងអំពីតួនាទី ICT នៅក្នុងបរិបទនៃការឡើងកំដៅផែនដីសកលលោក ដែលជំហរថ្នាក់ជាតិដ៏ខ្លាំងក្លានៃការអនុវត្តវិធានការនេះ គឺចាំបាច់បំផុតដើម្បីបញ្ឈប់ការឡើងកំដៅផែនដីជាលើកដំបូង AMS (រដ្ឋជាសមាជិកអាស៊ី) ដើម្បីផ្តួចផ្តើមនូវការប្តេជ្ញាចិត្តបែបនេះនៅក្នុងគោលនយោបាយ ICT របស់ជាតិ។

ដំណើរទៅមុខនៃការអនុវត្តប្រព័ន្ធអេឡិចត្រូនិច បន្ថែមទៀតនោះ នៅតែមាន និងមានជាបន្តបន្ទាប់ ដើម្បីធ្វើយ៉ាងឱ្យកម្ពុជាក្លាយជាប្រទេសមួយដែលជឿនលឿន និងស្មើមុខស្មើមាត់បន្ថែមទៀតនៅលើឆាកអន្តរជាតិ។ ប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិចបាននឹងកំពុងធ្វើដំណើរ និងកែសម្រួលជាបន្តបន្ទាប់ហើយ ប្រព័ន្ធសេវាសាធារណៈអេឡិចត្រូនិចក៏បាននឹងវិវឌ្ឍន៍ខ្លួនដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋបានមួយជំហានធំហើយផងដែរ ហើយរឿងបន្ទាប់ដែលយើងអាចសន្និដ្ឋានបានថាបើកម្ពុជាអនុវត្តបានបន្ថែមទៀតនោះ យើងនឹងក្លាយជាប្រទេសដែលជោគជ័យមួយផ្នែកធំក្នុងការដាក់ឱ្យអនុវត្ត និងប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចនេះហើយ។ ចំណុចដែលយើងចង់ឈានបន្ទាប់ទៀតនោះគឺ E-Democracy (ប្រព័ន្ធប្រជាធិបតេយ្យអេឡិចត្រូនិច)។ ប្រព័ន្ធនេះសំដៅទៅសកម្មភាពរបស់រដ្ឋាភិបាល អ្នកតំណាងជាប់ឆ្នោត គណបក្សនយោបាយ និងប្រជាពលរដ្ឋសម្រាប់ដំណើរការប្រជាធិបតេយ្យនៅក្នុងប្រទេសរបស់ខ្លួន។ នេះរាប់បញ្ចូលទាំងការពិភាក្សានយោបាយ ឬពិគ្រោះយោបល់រវាងអ្នកតំណាងរបស់ពួកគេ។ ខាងក្រោមជាឧទាហរណ៍មួយចំនួន នៃការអនុវត្តប្រព័ន្ធនេះនៅលើប្រទេសធំៗនាពេលបច្ចុប្បន្នះ អំឡុងពេលនៃការបោះឆ្នោតប្រធានាធិបតីអាមេរិកឆ្នាំ២០០៤ និងនៅក្នុងការបោះឆ្នោតពាក់កណ្តាលអាណត្តិឆ្នាំ២០០៦ បេក្ខជនគណបក្សធំៗ ទាំងអស់ សុទ្ធតែមានគេហទំព័រព័ត៌មានផ្ទាល់ខ្លួនហើយក៏បានផ្ញើអ៊ីម៉េលដែលជាសារនយោបាយទៅអ្នកបោះឆ្នោតដែលមានសក្តានុពលនៅក្នុងប្រទេសរបស់ខ្លួន។ យើងងាកមកមើលនៅក្នុងប្រទេសកូរ៉េខាងត្បូងវិញ ចាប់តាំងពីអ្នកប្រើអ៊ិនធឺណេត កម្រអានកាសែត ឬមើលទូរទស្សន៍មក អ្នកនយោបាយត្រូវតែពឹងផ្អែកលើអ៊ីនធឺណេតដូចគ្នាដើម្បីជ្រើសរើសអ្នកបោះឆ្នោត។

ការបោះឆ្នោតអេឡិចត្រូនិកគឺជាកម្មវិធីសំខាន់មួយទៀតនៅក្នុង ដែនប្រជាធិបតេយ្យអេឡិចត្រូនិច។ ដំណើរការបោះឆ្នោតដោយខ្លួនឯង គឺអាចមានកំហុសឆ្គងតាមរយៈការរៀបចំ ការលួចបន្លំ និងការក្លែងបន្លំសន្លឹកឆ្នោត ដែលនាំទៅដល់អ្នកចាញ់ធ្វើការហៅឱ្យរាប់ឡើងវិញ។ ការបោះឆ្នោតប្រឈមនឹងវិសាលភាពទូលំទូលាយនៃបញ្ហាបច្ចេកវិទ្យា និងសង្គម ដែលត្រូវតែដោះស្រាយដោយប្រព័ន្ធអ្នកបោះឆ្នោត បានធ្វើការចុះឈ្មោះ ទៅជាការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវរបស់អ្នកបោះឆ្នោត ខ្លួនឯងវិញ ចំពោះការបោះឆ្នោតគឺដើម្បីរាប់និងរកពិន្ទុលទ្ធផល។ ម៉ាស៊ីនបោះឆ្នោតអេឡិចត្រូនិកត្រូវបានប្រើដោយជោគជ័យនៅក្នុងការបោះឆ្នោតជាតិឥណ្ឌានៅឆ្នាំ២០០៤ ដែលជាការបោះឆ្នោតសភា។ ហើយវាត្រូវបានប្រើប្រាស់ជាង ៦០០.០០០គ្រឿង សម្រាប់ការបោះឆ្នោត។ ម៉ាស៊ីនទាំងនេះគឺជាម៉ាស៊ីនដែលដំណើរការដោយថាមពលថ្មដែលអាចចល័តបាន ងាយស្រួលក្នុងការប្រតិបត្តិការ ហើយម៉ាស៊ីនទាំងនោះត្រូវបានដំណើរការដោយមន្ត្រីត្រួតពិនិត្យនៅកន្លែងបោះឆ្នោត។ អ្នកបោះឆ្នោត អនក្ខរជនអាចបោះឆ្នោតតាមរូបភាព និងឡូហ្គោរបស់បេក្ខជន និងគណបក្សដែលពួកគេតំណាង។ វាមិនត្រឹមតែជួយកាត់បន្ថយពេលវេលារាប់តែប៉ុណ្ណោះទេ តែថែមទាំងជួយរក្សាទុកសន្លឹកឆ្នោត ផងដែរ ហើយការធ្វើដូចនេះមានពាក្យបណ្ដឹងតិចតួចបំផុតប្រឆាំងនឹងការប្រើប្រាស់ប្រព័ន្ធនេះនៅក្នុងប្រទេសឥណ្ឌា។

E-Democracy ប្រព័ន្ធប្រជាធិបតេយ្យអេឡិចត្រូនិច គឺពាក់ព័ន្ធនឹងការចូលរួមអេឡិចត្រូនិច និងចូលរួមជាសាធារណៈនៅក្នុងដំណើរការគោលនយោបាយតាមបណ្ដាញអេឡិចត្រូនិក ការប្រឹក្សាតាមអេឡិចត្រូនិក (ការពិគ្រោះយោបល់តាមអេឡិចត្រូនិច) ហើយសំដៅលើទំនាក់ទំនងរវាងមន្ត្រីរាជការជាមួយក្រុមប្រជាពលរដ្ឋ។

ចក្ខុវិស័យសំខាន់ទាំងនេះបាននឹងកំពុងយកចិត្តទុកដាក់ជាខ្លាំងក្នុងការពង្រឹងសមត្ថភាពរបស់ខ្លួនដើម្បីក្លាយជាប្រទេសអភិវឌ្ឍជឿនលឿនលើគ្រប់វិស័យ តាមរយៈការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច។

# ជំពូកទី៣

# ការវិភាគលើរបកគំហើញនៃការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច

## ៣.១. លទ្ធផលនៃការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច

ការដាក់ឱ្យអនុវត្តតាមប្រព័ន្ធអេឡិចត្រូនិច កន្លងមកយើងសង្កេតឃើញថា មានភាពវិជ្ជមានដែលជាកត្តាជោគជ័យមួយចំនួនធំក្នុងការសម្រេចគោលដៅនានាដែលបានដាក់ចេញគម្រោងនានា។ ជាក់ស្តែងគម្រោងប្រព័ន្ធគ្រប់គ្រងព័ត៌មានរដ្ឋបាលរបស់រដ្ឋាភិបាល(GAIS) បានសម្រេចគោលដៅដំបូងនៃការបង្កើតប្រាក់ចំណូលរូបភាព និងសេវាកម្មរបស់រដ្ឋាភិបាលឱ្យកាន់តែប្រសើរឡើង។ ក្នុងនោះរួមមាន ការចុះបញ្ជីអចលនទ្រព្យ ការចុះបញ្ជីនិវាសនជន និងការចុះបញ្ជីយានយន្តបានបង្កើតចំណូលសម្រាប់រដ្ឋាភិបាលតាមរយៈសេវាកម្មរបស់ពួកគេ។ នៅលើកម្មវិធីទាំងបីនេះគេហទំព័រប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិច(EAS) និងគេហទំព័ររបស់រដ្ឋាភិបាលបានរួមចំណែកបង្កើតរូបភាព និងសេវាកម្មរបស់រដ្ឋាភិបាលឱ្យកាន់តែប្រសើរឡើង ក្រៅពីការបង្កើតប្រាក់ចំណូលសម្រាប់រដ្ឋាភិបាលក្នុងទម្រង់ជាពន្ធ និងតំលៃប្រព័ន្ធចុះឈ្មោះថ្មីនេះ ក៏បានអនុញ្ញាតឱ្យរក្សាទុក និងបោះពុម្ពព័ត៌មានអចលនទ្រព្យទាំងអស់ដោយលុបបំបាត់ ឬកាត់បន្ថយសក្តានុពលនៃការដណ្តើមយកដីធ្លីនៅក្នុងរាជធានីភ្នំពេញ។ ជាមួយគ្នានេះដែរផ្នែករដ្ឋបាល គឺការផ្លាស់ប្តូរឯកសារតាមរយៈអេឡិចត្រូនិចរវាងនាយកដ្ឋានរដ្ឋ និងក្រសួងកាត់បន្ថយការពន្យារពេល ដែលមិនចាំបាច់រងចាំនានា ហើយវាបាននាំមកនូវលទ្ធផលនៅក្នុងសេវាកម្មសាធារណៈកាន់តែប្រសើរ។ EAS បានដំណើរការមកហើយ ប៉ុន្តែមិនត្រូវបានគេប្រើយ៉ាងទូលំទូលាយទេ ដោយមានតែឯកសារ ឬរបាយការណ៍បច្ចេកទេសប៉ុណ្ណោះដែលត្រូវបានផ្ញើដោយប្រើប្រាស់ EAS ។ ឯកសាររដ្ឋបាលផ្សេងទៀតនៅតែចូលចិត្តដំណើរការបែបប្រពៃណី។ ប្រព័ន្ធថ្មីនេះអនុញ្ញាតឱ្យរៀបចំឯកសារការផ្ញើការរក្សាទុកបណ្ណសារការស្វែងរកនិងការបោះពុម្ពឯកសារទាំងអស់នៅក្នុងប្រព័ន្ធដោយចុចក្តារចុច។ ស្ថានភាពនៃឯកសារដែលបានផ្ញើគឺអាចរកបានគ្រប់គ្នានៅក្នុងបណ្តាញអ៊ីនធឺណេត។[34]

វត្តមានរបស់រដ្ឋាភិបាលនៅលើគេហទំព័រ(World Wide Wep) បានពង្រឹងការផ្សព្វផ្សាយជាសាធារណៈដល់ពិភពលោកខាងក្រៅ និងធ្វើអោយប្រសើរឡើងនូវសេវាកម្មព័ត៌មានសាធារណៈសម្រាប់ប្រជាជនកម្ពុជា និងអ្នកស្រាវជ្រាវនៅជុំវិញពិភពលោក។ កាលពីមុនក្រសួងនីមួយៗត្រូវមានបុគ្គលិកយ៉ាងតិចម្នាក់ដើម្បីឆ្លើយសំណួរអំពីក្រសួង ជូនកាលចម្លើយខុសគ្នា ដែលនាំឱ្យមានការយល់ច្រឡំជាសាធារណៈអំពីរដ្ឋាភិបាល។ បច្ចុប្បន្នគេហទំព័រនេះផ្តល់ព័ត៌មានអំពីរដ្ឋាភិបាល

[34] http://www.unicode.org/Public/UNIDATA/Index.txt

ដល់សាធារណជនទូទៅ ដែលបណ្តាលឱ្យមានការកាត់បន្ថយការងារសម្រាប់បុគ្គលិករដ្ឋាភិបាល និងព័ត៌មានសាធារណៈត្រឹមត្រូវ និងគ្មានការយល់ច្រឡំ។

គោលដៅចម្បងៗនៃ ប្រព័ន្ធរដ្ឋបាល (EAS) ដែលបានដាក់ចេញឱ្យអនុវត្តរួមមានសារៈប្រយោជន៍សំខាន់ៗជាច្រើនដែលជួយដល់ការបង្កើនប្រសិទ្ធភាពនិងសេវាក្នុងការបម្រើជាសាធារណៈ ហើយក្នុងនោះរួមមានការបង្កើនប្រសិទ្ធភាពការងាររបស់រដ្ឋាភិបាលតាមរយៈ Office Paperless អនុវត្តប្រព័ន្ធគ្រប់គ្រងកិច្ចការរដ្ឋបាលដែលមានល្បឿនលឿន និងងាយស្រួលក្នុងការប្រើប្រាស់ ដាក់ពាក្យសុំអនុវត្តច្បាប់គ្រប់គ្រងអាជីវកម្មបានច្បាស់លាស់ក្នុងរយៈពេលខ្លី បង្កើតប្រព័ន្ធរដ្ឋបាលរបស់រាជរដ្ឋាភិបាលដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលបច្ចេកវិទ្យាទាន់សម័យ កសាងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានសម្រាប់បណ្តាញអ៊ិនធឺណេតជាតិ ប្រព័ន្ធព័ត៌មានផ្តល់ឱកាសដល់វិស្វករបច្ចេកវិទ្យាកម្ពុជា។ ជាមួយគ្នានេះដែរប្រព័ន្ធរដ្ឋបាល (EAS) នេះក៏មានមុខងារជាច្រើន ផងដែររួមមានការយល់ព្រមអនុញ្ញាតឱ្យមានការផ្លាស់ប្តូរឯកសារតាមអេឡិចត្រូនិក រវាងក្រសួង សំបុត្រអនុញ្ញាតឱ្យមានការផ្លាស់ប្តូរអ៊ីម៉ែលរវាងអ្នកប្រើប្រាស់ ព្រឹត្តិប័ត្រក្រុមប្រឹក្សាភិបាល អនុញ្ញាតឱ្យប្រកាសលើបណ្តាញព័ត៌មានពាក់ព័ន្ធ អ្នកប្រើ និងអង្គការផ្តល់ព័ត៌មានដល់ក្រសួង និងអ្នកប្រើប្រាស់។ វាមានមុខងារជា ឧបករណ៍រដ្ឋបាល គ្រប់គ្រងឯកសារ អនុញ្ញាតឱ្យរក្សាទុក និងគ្រប់គ្រងការអនុម័ត។

ក្រៅអំពីការគ្រប់គ្រងរដ្ឋបាល ប្រព័ន្ធចុះបញ្ជីដែលជាគោលដៅរបស់ ប្រព័ន្ធអេឡិចត្រូនិចក្នុងមុខងារសាធារណៈ មានគោលបំណងសំខាន់ៗ ដែលត្រូវតាមដានប្រតិបត្តិការអចលនទ្រព្យរួមទាំងតម្លៃ និងពន្ធ ដែលបានបង់ហើយមានលក្ខណៈពិសេស ដែលអនុញ្ញាតនៅក្នុងប្រព័ន្ធចុះឈ្មោះអចលនទ្រព្យរួមមានគ្រប់ គ្រងទិន្នន័យមូលដ្ឋានអំពីទ្រព្យសម្បត្តិដូចជាអាសយដ្ឋាន ឬទីតាំង ធ្វើការគ្រប់គ្រងការផ្លាស់ប្តូរលើអចលនទ្រព្យដូចជាអគារថ្មី ឬអគាររង គ្រប់គ្រងការផ្ទេរសិទ្ធិ គ្រប់គ្រងពន្ធលើអចលនទ្រព្យ ការគ្រប់គ្រងស្ថិតិនៃទ្រព្យសម្បត្តិ។

ជាលទ្ធផលនៃប្រព័ន្ធចុះបញ្ជីអ្នកស្នាក់នៅ គឺបានផ្តល់ការតាមដានលំនៅដ្ឋានសមាសភាពគ្រួសាររបស់ពួកគេ និងការងាររបស់ពួកគេសម្រាប់គោលបំណងពង្រឹងការអប់រំជាកំហិតសម្រាប់កុមារអាយុចូលសាលារៀន និងសម្រាប់ប្រមូលពន្ធលើប្រាក់ចំណូល។ លក្ខណៈពិសេសដែលអនុញ្ញាតនៅក្នុងប្រព័ន្ធចុះឈ្មោះលំនៅដ្ឋានរួមមាន៖ ការគ្រប់គ្រងទិន្នន័យមូលដ្ឋាន ដែលក្នុងនោះរួមមានអាសយដ្ឋាន សមាសភាពគ្រួសារកុមារ ដែលឈានដល់អាយុចូលរៀន ការគ្រប់គ្រងការផ្លាស់ប្តូរក្នុងស្ថានភាពគ្រួសារដូចជាកំណើត ឬស្លាប់ ការគ្រប់គ្រងការផ្លាស់ប្តូរក្នុងស្ថានភាពគ្រួសារដូចជាការរៀបការនិងការលែងលះ ការគ្រប់គ្រងពន្ធដែលជំពាក់ឬបង់ គ្រប់គ្រងស្ថិតិរបស់អ្នកស្រុក។

មួយវិញទៀតអំពីគោលបំណងនៃ ប្រព័ន្ធចុះបញ្ជីយានយន្ត គឺរក្សានូវភាពជាម្ចាស់រថយន្ត ការបង់ពន្ធ និងការត្រួតពិនិត្យសុវត្ថិភាព។ ប្រព័ន្ធនេះត្រូវបានបែងចែកទៅជាអនុប្រព័ន្ធនានា លក្ខណៈពិសេសដែលអនុញ្ញាតនៅក្នុងប្រព័ន្ធចុះបញ្ជីយានយន្តរួមមាន ការគ្រប់គ្រងទិន្នន័យជាមូលដ្ឋានរួមទាំងព័ត៌មានភាពជាម្ចាស់ ប្រភេទឆ្នាំលេខយានយន្ត និងលេខអត្តសញ្ញាណយានយន្ត ការគ្រប់គ្រងការចុះបញ្ជី ការគ្រប់គ្រងការផ្ទេរកម្មសិទ្ធិ គ្រប់គ្រងព័ត៌មានអធិការកិច្ចដូចជាពេលណាត្រូវឱ្យយានយន្តបញ្ជូនមកដើម្បីត្រួតពិនិត្យសុវត្ថិភាព ការគ្រប់គ្រងពន្ធ ដែលបានបង់រួមបញ្ចូលពន្ធលើការនាំចូល និងអាករ (ផ្លូវថ្នល់) ការគ្រប់គ្រងស្ថិតិនៃយានយន្ត។

សេចក្ដីសង្ខេបនៃចំណុចសំខាន់ៗ ដែលទាក់ទងទៅនឹងកត្តាជោគជ័យនោះរួមមានកត្តាឆន្ទៈនយោបាយ ដោយមានការចូលរួមរបស់នាយករដ្ឋមន្ត្រីតាំងពីដំបូងក្នុងអំឡុងគម្រោងចាប់ផ្ដើម និងសម្ពោធប្រព័ន្ធនៃការគ្រប់គ្រងក្នុងបរិយាកាសស្មុគស្មាញ និងផុយស្រួយ, មានការវិនិច្ឆ័យត្រូវយកទៅពិនិត្យមើលសាវតារនៃអ្នកពាក់ព័ន្ធទាំងអស់ និងប្រវត្តិនៃការសិក្សា និងសេដ្ឋកិច្ចចម្រុះនៃអ្នកចូលរួមទាំងអស់ ហើយរួមផ្សំនឹងសមត្ថភាពបច្ចេកទេស ដែលយល់អំពីរបៀប ដែលប្រព័ន្ធនេះនឹងត្រូវធ្វើ ភារកិច្ចការងារសមស្រប ការចូលរួមមានជាអតិបរមានៅស្ទើរលើគ្រប់វិស័យ ការចូលរួមរបស់ប្រជាពលរដ្ឋ ដែលមានចំណាប់អារម្មណ៍ អ្នកពាក់ព័ន្ធទាំងអស់ អ្នកផ្ដល់សេវា និងអ្នកទទួលសេវាកម្មមានការផុសផុលច្រើនដែលបង្ហាញពីចំណុចវិជ្ជមានតាំងពីពេលចាប់ផ្ដើមអនុវត្ត ការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធទាំងអស់ដោយការធ្វើមូលដ្ឋានីយកម្ម ហើយអនុវត្តវិស្វករកម្មវិធីកុំព្យូទ័រកម្ពុជា ឬអ្នកសរសេរកម្មវិធីដោយប្រើប្រាស់ភាសាខ្មែរ និងក្ដារចុច។

## ៣.២. ឧបសគ្គនៃការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច

ប្រព័ន្ធអេឡិចត្រូនិច ក្នុងមុខងារបច្ចុប្បន្នកំពុងត្រូវបានធ្វើឱ្យប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយនៅតែមានឧបសគ្គមួយចំនួនក្នុងការអនុវត្តការឱ្យរីកចម្រើនលើការគ្រប់គ្រងអេឡិចត្រូនិចនៅក្នុងប្រទេសកម្ពុជា លើការគ្រប់គ្រងរណសិរ្សនៅកម្ពុជា ដោយទាក់ទងនឹងការដាក់ពាក្យសុំ ICT។[35]

កត្តាមួយចំនួនត្រូវបានរកឃើញ ជាក់ស្ដែងដូចជា សមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងរដ្ឋបាលសាធារណៈដោយការអនុវត្តបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាគឺជួបជានិច្ចនូវបញ្ហានៃការប្រើប្រាស់បច្ចេកទេសថ្មី ដែលតម្រូវការបំលាស់ប្ដូរសមត្ថភាពទទួលយករបស់ប្រជាជន និងការប្រកួតប្រជែងអន្តរជាតិ ការផ្លាស់ប្ដូរអាកប្បកិរិយារបស់អ្នកផ្ដល់សេវា និងអ្នក

[35] NiDA អាជ្ញាធរអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍នៅកម្ពុជាឆ្នាំ២០១៣

ទទួលសេវាកម្ម។ ការអនុវត្តនីតិរដ្ឋក្នុងក្របខណ្ឌនៃអ្នកផ្តល់សេវាកម្មសាធារណៈប្រកបដោយតម្លាភាព និងគណនេយ្យភាពមិនទាន់ពេញលេញ ហើយកំពុងធ្វើការសម្របសម្រួលកំណែទម្រង់តាមវិស័យជាមួយកំណែទម្រង់ជាតិ។ ជាមួយគ្នានេះដែរការធ្វើសមាហរណកម្ម និងសម្របសម្រួលការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ ការកៀរគរធនធានហិរញ្ញវត្ថុ និងការគ្រប់គ្រងការអភិវឌ្ឍ ដាក់ពង្រាយធនធានមនុស្សដើម្បីទ្រទ្រង់ការអនុវត្ត នៅតែជាបញ្ហាប្រឈមរបស់ប្រទេសកម្ពុជាក្នុងការអនុវត្តតាមប្រព័ន្ធអេឡិចត្រូនិច។

យោងតាមរបាយការណ៍ស្ទង់មតិរបស់ JICA[36] និង NiDA ឆ្នាំ២០០៩ ការស្ទង់មតិស្តីពីការអភិវឌ្ឍន៍វិស័យ ICT នៅក្នុងក្រសួងមួយចំនួនបានបង្ហាញលទ្ធផលរួមគ្នា គឺមានគម្លាតធំទូលាយ។ អ្នកខ្លះស្ថិតនៅ ឬឈានដល់កម្រិតពិន្ទុនៃ "កម្រិតខ្ពស់" "មធ្យម" និង"នៅពីក្រោយ" ។ កំរិតពិន្ទុទាបគឺដោយសារតែមិនដឹងអំពីការប្រើប្រាស់ ICT ដោយគ្មានការតែងតាំងមន្ត្រីជាន់ខ្ពស់ដើម្បីធ្វើការទទួលខុសត្រូវ និងការបែងចែកថវិកាតិចសម្រាប់ការអភិវឌ្ឍ ICT។ ខាងក្រោមនេះគឺជាបញ្ហាប្រឈមមួយចំនួនដែលបានរកឃើញបន្ថែមក្នុងការអនុវត្តៈ (1) អង្គភាព/បុគ្គលិក នៃការគ្រប់គ្រងបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាមិនទាន់យល់ដឹង (concept understanding), ដែលជារួមយើងត្រូវរក្សាបុគ្គលិក ICT ដែលមានជំនាញ ដោយផ្តល់ប្រាក់ខែ ការលើកទឹកចិត្ត និងមានការចូលរួមរបស់ស្ត្រី។ (2) ភាពជាអ្នកដឹកនាំក្នុងការលើកកម្ពស់ ICT ៖ ការប្តេជ្ញាចិត្តយូរអង្វែង និងកិច្ចសហប្រតិបត្តិការ (អាកប្បកិរិយាអវិជ្ជមានឆ្ពោះទៅរកការប្រើ ICTs, អំណាចមិនគ្រប់គ្រាន់នៃបុគ្គលិក ICT (ការពង្រឹងអំណាច), ការខ្វះការសហការនៅទូទាំងភ្នាក់ងាររដ្ឋាភិបាល (ការថតចំលង) និងការចែករំលែកព័ត៌មានអំពីទំនាក់ទំនងផ្ទាល់ខ្លួន។ (3) អក្ខរកម្មរបស់ ICT៖ ពាក់កណ្តាលនៃបុគ្គលិករដ្ឋាភិបាល មានជំនាញមូលដ្ឋានតែប៉ុណ្ណោះហើយមិនមានបំណងធ្វើការ។ (4) កង្វះហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានថ្នាក់ជាតិចាំបាច់សម្រាប់សុវត្ថិភាព និងអត្ថប្រយោជន៍ចំណាយ។ (5) ខ្វះជំនាញសម្រាប់បណ្តាញមូលដ្ឋាន និងបណ្តាញតំបន់ធំសម្រាប់អន្តរក្រសួង,ការផ្គត់ផ្គង់ឧបករណ៍អេឡិចត្រូនិកដើម្បីធានាការត្រួតពិនិត្យគុណភាព និងស្តង់ដារនៅមានការខ្វះខាត។ (6) ការឧបត្ថម្ភធនធានផ្នែក ICT នៅមានកម្រិត និងជួបការលំបាកផ្នែកខាងក្នុង និងក្រៅប្រទេសក្នុងការសហការបង្កើត ICT តាមសំណើ។

ឧបសគ្គនានាបានកើតមានផងដែរក្នុងការអនុវត្ត ដែលវាបានផ្តល់ផលប៉ះពាល់ជារួមដល់សង្គម សុខភាព និងការអប់រំជាដើម។ ក្នុងនេះរាជរដ្ឋាភិបាលកម្ពុជាកំពុងប្រឈមមុខនឹងការប្រយុទ្ធ

[36] JICA: Japan International Cooperation Agency

ដ៏លំបាកមួយនៃការផ្លាស់ប្តូរផ្នត់គំនិតរបស់ប្រជាជន ដោយបានចោទសួរប្រជាជនជាពិសេសអ្នកសម្រេចចិត្តភាគច្រើនដើម្បីបោះបង់កាំភ្លើង ហើយមកយកកុំព្យូទ័រ និងសៀវភៅកត់ត្រាជំនួសវិញ។ ដោយមានការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្ត ICT នេះគម្រោងនេះគឺជាគម្រោងដ៏សំខាន់មួយសម្រាប់សង្គមកម្ពុជា និងអាចផ្តល់ភាពជោគជ័យរបស់រដ្ឋាភិបាលក្នុងការផ្លាស់ប្តូរផ្នត់គំនិតរបស់ប្រជាជន។

ផលអវិជ្ជមានផ្សេងទៀតផងដែរគឺផលប៉ះពាល់វប្បធម៌ ដែលប្រព័ន្ធអេឡិចត្រូនិច បានណែនាំអំពីការផ្លាស់ប្តូររបៀប ដែលប្រជាជនកម្ពុជាធ្វើការទំនាក់ទំនង និងមើលពិភពខាងក្រៅពីការិយាល័យរបស់ពួកគេ ដោយកាលពីមុនមន្ត្រីរដ្ឋាភិបាលអង្គុយ និងរង់ចាំឯកសារ ពេលខ្លះការរង់ចាំអាចជាងមួយសប្តាហ៍ ឬសូម្បីតែមួយខែក៏មាន គឺអាស្រ័យលើចម្ងាយ។ ខណៈសាធារណជន ឬអ្នកទទួលសេវាកម្ម ដាច់ខាតត្រូវតែអត់ធ្មត់រង់ចាំ ហើយទទួលយកវាដែលជាសេវាកម្មស្តង់ដារផ្តល់ដោយរដ្ឋាភិបាល។ សព្វថ្ងៃនេះមន្ត្រីរដ្ឋាភិបាលបានទទួលឧបករណ៍ដ៏ល្អបំផុតដើម្បីសម្រេចបាននូវភារកិច្ចរបស់ខ្លួនក្នុងការបម្រើដល់សាធារណជន ពួកគេអាចទៅ អ៊ីនធឺណេត ឬអ៊ីម៉ែលដើម្បីធ្វើការទំនាក់ទំនង ឬស្រាវជ្រាវឯកសារចាំបាច់។ ខណៈពេល ដែលសាធារណជននឹងមិនស៊ៀមស្ងាត់ចំពោះសេវាសាធារណៈដែលគ្មានការឆ្លើយតប ហើយបន្ថែមពីលើសេវាល្អរបស់រដ្ឋាភិបាល ការដាក់ឱ្យប្រើប្រាស់អ៊ីធឺណិត និងអ៊ីម៉ែលនេះបានបង្ហាញរូបភាពអាសអាភាស និងឧក្រិដ្ឋកម្មពាក់ព័ន្ធដល់សង្គមកម្ពុជាជាខ្លាំងផងដែរ។

ជារួមតាមរយៈឧបសគ្គនានាខាងលើជុំវិញការដាក់ឱ្យអនុវត្តប្រព័ន្ធអេឡិចត្រូនិចនៅកម្ពុជានេះក៏វានៅមានបញ្ហាប្រឈមសំខាន់ៗបន្ថែមទៀតដែរ ដែលជាចាំបាច់ត្រូវដោះស្រាយ និងស្វែងរកវិធានការផ្សេងទៀតដើម្បីគ្រប់គ្រងការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាព។ កត្តាប្រឈមទាំងនោះមានរួមបញ្ចូលទាំងវិមជ្ឈការដែនដីដែលការធ្វើប្រតិភូកម្មអំណាចទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលពុំទាន់មាននីតិវិធីអនុវត្តនៅឡើយតាមប្រព័ន្ធអេឡិចត្រូនិច ឯកសារ ជីវប្រវត្តិ ផ្នែកអប់រំ និងសេដ្ឋកិច្ច ផ្តល់ជូននូវភាពតានតឹងដែលជាកេរដំណែលនៃរបបខ្មែរក្រហម (ធនធានមនុស្ស, ហេដ្ឋារចនាសម្ព័ន្ធ រស់នៅ និងអប់រំខ្វះខាត) ការអប់រំបណ្តោះអាសន្នលើការប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈនៅមាន កម្រិត និងមិនទាន់បានទូលំទូលាយនៅឡើយ។ គម្លាតសមត្ថភាពនៃការអនុវត្តជាក់ស្តែងនៃការជ្រើសរើសមន្ត្រីស្រុក និងឃុំនឹងបណ្តាលឱ្យមានកង្វះសមត្ថភាពបន្ថែមទៀត។

### ៣.៣. ដំណោះស្រាយនៃការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច

ការអនុវត្តប្រព័ន្ធមួយ ដែលបានជោគជ័យ គឺតែងដើរទន្ទឹមគ្នាជាមួយនឹងយុទ្ធសាស្ត្រសម្រាប់ដោះស្រាយបញ្ហាដែលកើតឡើងនានាពេលកំពុងអនុវត្ត។ ជាមួយគ្នានេះដែរដើម្បីសម្រេចបានតាម

គោលបំណងខាងលើ និងដោះស្រាយបានលទ្ធផលល្អប្រសើរលើបញ្ហាប្រឈម ដែលជួបប្រទេះ គោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា(ឆ្នាំ២០១៥) រួមបញ្ចូលនូវវិធានការមួយចំនួនដូចជា៖

(ក) នៅក្នុងក្របខ័ណ្ឌ ICTs៖ ត្រូវបង្កើតក្របខ័ណ្ឌច្បាប់ និងបទបញ្ញា ច្បាប់ជាតិដើម្បីធានាឱ្យបាននូវសេដ្ឋកិច្ចជាតិនិងសង្គមដោយពង្រឹងសកម្មភាពជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាតាមរយៈយុទ្ធសាស្ត្រជាតិ ហើយការអនុម័ត ICT ដែលសម្រេចបានដោយការពង្រឹងប្រព័ន្ធមួយគឺដើម្បីសម្របសម្រួលចំណុចនេះ ដែលសរុបមកវាក៏ត្រូវបែងចែក ICT ផងដែរក្នុងវិស័យពាក់ព័ន្ធសំខាន់ៗ និងលើកទឹកចិត្តឱ្យបង្កើតយុទ្ធសាស្ត្រ ICTs ។ ក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់វិស័យនីមួយៗដូចជា E-Government, E-Commerce, E-Industry, E-Society, និងការអប់រំអេឡិចត្រូនិចសម្រាប់ការអនុវត្តន៍បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ហើយអាចអនុវត្តបាននៅប្រទេសកម្ពុជា ដែលបរិយាកាសនីតិប្បញ្ញត្តិច្បាប់ និងបទប្បញ្ញត្តិតាមរដ្ឋធម្មនុញ្ញហើយស្របជាមួយតំបន់ និងការអនុវត្តល្អបំផុតនៅលើពិភពលោក វាចាំបាច់ក្នុងការបង្កើតនិងរក្សានូវច្បាប់ និងនិយតកម្មដែលអាចធ្វើទៅបានតាមក្របខ័ណ្ឌ។[37]

ចំណុចគន្លឹះដើម្បីធ្វើឱ្យមានសមិទ្ធិផលមុនគោលនយោបាយ ICT ឆ្នាំ២០១៥ គឺត្រូវបានកំណត់អត្តសញ្ញាណរបស់ NiDA ដែលជាអង្គការទទួលបន្ទុកក្នុងការលើកកម្ពស់គោលនយោបាយ ICT ហើយត្រូវបានទទួលស្គាល់ និងមានភាពជាដៃគូរវាង NiDA និងក្រសួងពាក់ព័ន្ធផ្សេងៗទៀតដែលបានអនុវត្ត។ ផែនការក្នុងរយៈពេលខ្លី និងរយៈពេលវែងត្រូវបានបង្កើតឡើង ហើយបញ្ហាប្រឈមទាំងនោះត្រូវបានរួមបញ្ចូលនៅក្នុងច្បាប់ ICT និងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនានា។

(ខ) បង្កើតវិធានការនានា ដើម្បីសម្រេចបាននូវកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានក៏ដូចជា ដើម្បីធានានូវការខិត ខំប្រឹងប្រែងរក្សាល្បឿនជាមួយបច្ចេកវិទ្យាព័ត៌មានវិទ្យានៅអាស៊ាន តាមរយៈការជំរុញបច្ចេកវិទ្យា ICT ជាតិ។ ICT ប្តេជ្ញាថារាជរដ្ឋាភិបាលកម្ពុជាបានបំពេញការងាររបស់ខ្លួន សម្រាប់អន្តរជាតិ និងសហគមន៍ ជាពិសេសនៅក្នុងតំបន់អាស៊ាន។ ការអនុលោមទៅតាមក្របខ័ណ្ឌអន្តរជាតិ (ដូចជាWTO និង WIPO) ត្រូវបានបន្តស្របពេល ដែលបានផ្តល់អាទិភាពលើក្របខ័ណ្ឌអាស៊ាន អឺរ៉ុបដើម្បីធានានូវការប្តេជ្ញាចិត្តថ្នាក់តំបន់។ រយៈពេលកំណត់សម្រាប់យុទ្ធសាស្ត្រថ្នាក់ជាតិ ត្រូវបានអនុវត្តស្របតាមគោលការណ៍កំណត់សម្រាប់ការលើកកម្ពស់គោលនយោបាយបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា។ លើសពីនេះទៀតការ

[37] NiDA អាជ្ញាធរអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍នៅកម្ពុជា

វិនិយោគក្នុងការអភិវឌ្ឍធនធានមនុស្សចាំបាច់ត្រូវបានសង្កត់ធ្ងន់ និងយកចិត្តទុកដាក់បំផុត។ នៅពេលនេះការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន (គោលដៅកំណត់សម្រាប់ខែធ្នូ សមាហរណកម្មអាស៊ានឆ្នាំ២០១៥) បានកើតមានឡើង ហើយការជឿនលឿនថ្មីៗនៅក្នុងបច្ចេកវិទ្យា និងការច្នៃប្រឌិតមានលក្ខណៈថេរ ដោយមិនមានតំបន់ណាមួយ ដែលប្រទេសកម្ពុជាហាក់ដូចជាដើរយឺតក្នុងកម្រិតនៃបច្ចេកវិទ្យារបស់ខ្លួននោះទេ សម្រាប់ហេតុផលនេះការប្រមូលព័ត៌មានអំពីបច្ចេកវិទ្យាថ្មីក៏ដូចជាការអភិវឌ្ឍន៍មនុស្ស ដូចជាវិស្វកម្មICTត្រូវបានតម្លើងឋានៈ។ វឌ្ឍនភាពទាំងនេះអាចជាការពន្លឿនតែតាមរយៈការអនុវត្តការកសាងសមត្ថភាព ICT ទាំងធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធ។ វាចាំបាច់ក្នុងការបង្កើនចំនួន និងសមត្ថភាពរបស់ ICT ដែលមានជំនាញមូលដ្ឋានដែលធនធានមនុស្សសម្រាប់ប្រទេសកម្ពុជា។ ក្នុងករណីហេដ្ឋារចនាសម្ព័ន្ធ ICT ជាតិបានប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាពហើយនោះ ហេដ្ឋារចនាសម្ព័ន្ធត្រូវបានតម្លើងឋានៈ ដែលសមស្របទៅតាមតម្រូវការភាគច្រើន និងមានស្តង់ដារថ្នាក់តំបន់ និងអន្តរជាតិ ដែលគួរតែត្រូវបានគេយកទៅពិចារណាក្នុងលក្ខខណ្ឌនៃលទ្ធភាពទទួលបានគ្រប់គ្រាន់ និងការកាត់បន្ថយការចំណាយដែលជាគោលដៅចម្បង។

ចំណុចគន្លឹះនោះគឺថា គោលដៅចម្បងសំខាន់បំផុតរបស់ប្រទេសកម្ពុជា គឺមិនស្ថិតនៅពីក្រោយកម្រិតអាស៊ានទេក្នុងការអភិវឌ្ឍន៍ ICT នេះ។ ជាមួយនឹងការគោរពចំពោះធនធានមនុស្សចាំបាច់សម្រាប់ពេលបច្ចុប្បន្នប្រទេសកម្ពុជាត្រូវការការពឹងពាក់ភាគច្រើននៅលើការគាំទ្រអន្តរជាតិ (ឯកជន និងសាធារណៈ)ដែលចំណុចនេះនឹងត្រូវបានអភិវឌ្ឍយ៉ាងល្អិតល្អន់ជាមួយយុទ្ធសាស្ត្រ ICTរបស់ប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយការជ្រើសរើសយកបច្ចេកវិទ្យា គមនាគមន៍ព័ត៌មានវិទ្យាសមស្រប គឺជាគន្លឹះសំខាន់មួយ ដែលនាំមកនូវភាពជោគជ័យក្នុងការពន្លឿនការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យានៅកម្ពុជា។

(គ) សេវា ICT ៖ កែលម្អសេវារបស់រដ្ឋាភិបាលតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា (E-Government) ដែលជាប្រព័ន្ធសុវត្ថិភាពព័ត៌មានបានបង្កើតឡើងយ៉ាងល្អ។ តាមរយៈមធ្យោបាយនេះវាអាចផ្តល់ជូនបានចំនួនច្រើននៃព័ត៌មានអំពីប្រទេស និងរដ្ឋាភិបាលរបស់ខ្លួន។ ដូច្នេះការសម្របសម្រួលផ្លូវពីរគឺការទំនាក់ទំនងរវាងរដ្ឋាភិបាល និងប្រជាជនឬផ្ទុយមកវិញ នឹងមិនមែនជាបញ្ហាទៀតទេ។ តាមរយៈ ការអនុវត្តន៍ ICT រដ្ឋបាលសាធារណៈគ្រប់គ្រងសកម្មភាពរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធិភាពថែមទាំងផ្តល់ផងដែរ នូវសេវាកម្មសម្រាប់សាធារណជនកាន់តែងាយស្រួល។ រាជរដ្ឋាភិបាលកម្ពុជាទទួលខុសត្រូវចំពោះការ

អនុវត្តវិធានការទាំងនេះ ដោយធានាថាគោលនយោបាយគ្រប់បែបយ៉ាងត្រូវបានបង្កើតឡើង ដើម្បីរក្សាប្រព័ន្ធសន្តិសុខព័ត៌មានជាតិ។ ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច ដែលគាំទ្រដោយប្រព័ន្ធសុវត្ថិភាពព័ត៌មាន ដែលអាចទុកចិត្តបានក៏នឹងបង្កើតផងដែរនូវ រាជរដ្ឋាភិបាលកម្ពុជា ដែលមានប្រសិទ្ធភាពគួរអោយជឿទុកចិត្ត និងមានតម្លាភាព។ វិស័យសាធារណៈដែលក្លាយទៅជាអ្នកប្រើដំបូងគេលើរដ្ឋាភិបាលអេឡិចត្រូនិចអាចទទួលបានព័ត៌មានទាក់ទងនឹងរដ្ឋបាលសាធារណៈ និងសកម្មភាពរបស់វា។ រដ្ឋាភិបាលត្រូវបានបង្កើតឡើងដើម្បីធានាឱ្យមានតម្លាភាពកាន់តែច្រើននៅក្នុងការងាររបស់ខ្លួននិងជាមធ្យោបាយផ្តល់សេវាកម្មទូទាំងប្រទេស។ តាមរយៈការអនុវត្តអេឡិចត្រូនិចរដ្ឋាភិបាលអាចចំណាយតិចតួចសម្រាប់អ្នកផ្តល់សេវា និងអ្នកប្រើ ដែលផលិតភាពនៃរដ្ឋបាលសាធារណៈនឹងកើនឡើងហើយជាពិសេសគឺអន្តរបុគ្គលក៏ដូចជាកិច្ចសហប្រតិបត្តិការអន្តរស្ថាប័នត្រូវបានពង្រឹង ដែលអនុញ្ញាតឱ្យមានទំនាក់ទំនងកាន់តែមានប្រសិទ្ធភាព ហើយការអភិវឌ្ឍ និងការលើកកម្ពស់រដ្ឋាភិបាលអេឡិចត្រូនិចនឹងអាចបង្កើនគណនេយ្យភាព តម្លាភាព និងមានការចូលរួមនៃការគ្រប់គ្រងរដ្ឋបាលវិស័យសាធារណៈ និងឯកជន។

(ឃ) គាំទ្រការប្រើប្រាស់ ICT ក្នុងវិស័យឯកជន និងការរីកចម្រើន នៃពាណិជ្ជកម្មអេឡិចត្រូនិច បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងចំណោមសហគ្រាសធុនតូច និងមធ្យម ដោយត្រូវបានលើកទឹកចិត្តហើយមូលដ្ឋានចាំបាច់ត្រូវបានបង្កើតឡើងសម្រាប់ភាពប្រសើរនៃបរិយាកាសពាណិជ្ជកម្មអេឡិចត្រូនិចសម្រាប់អាជីវកម្ម។ ដើម្បីទទួលបានជោគជ័យនេះច្បាប់និងនិយតកម្មចាំបាច់ត្រូវបានបង្កើតឡើង ហើយការផ្តួចផ្តើមសកម្មភាពនេះគឺធ្វើឡើងដើម្បីលើកកម្ពស់ការអនុម័តរបស់ ICT។

(ង) ជំរុញការរីកចម្រើននៃឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ជាតិ និងតំណភ្ជាប់នៅក្នុងតំបន់អាស៊ាន៖ ឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ជាតិ (ការផលិត និងការអភិវឌ្ឍនៃឧបករណ៍ទាក់ទងនឹង ICT និងកម្មវិធីកុំព្យូទ័រ) ត្រូវបានលើកកម្ពស់ និងអភិវឌ្ឍដើម្បីរក្សានូវបច្ចេកវិទ្យាកម្រិតខ្ពស់មួយក្នុងចំណោមបណ្តាតំបន់អាស៊ាន។ ដែនសមត្ថកិច្ចនៃការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ស្ថិតនៅជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម(MoIH)។ ភាពជាដៃគូជាមួយសហគ្រាសបរទេសនៅក្នុង គោលនយោបាយជាតិបច្ចេកវិទ្យាគមនាគមន៍ជាតិ មានចូលរួមក្នុងការផ្ទេរបច្ចេកវិទ្យា ដោយ ៥ឆ្នាំដំបូងនៃការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាត្រូវបានបង្កើតឡើង ដើម្បីទាក់ទាញសហគ្រាសបរទេសឱ្យមក

ប្រទេសកម្ពុជាសម្រាប់វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ហើយធ្វើការអភិវឌ្ឍដល់ការផ្ទេរបច្ចេកវិទ្យាសម្រាប់ប្រជាជនកម្ពុជា។ ការអភិវឌ្ឍទាំងនេះ នឹងធានានូវការផ្គត់ផ្គង់ធនធានមនុស្សដោយផ្អែកលើគោលការណ៍ណែនាំតឹងរ៉ឹង ហើយសន្តិសុខព័ត៌មានត្រូវចាត់ទុកជាអាទិភាព និងបន្ទាន់នៃ ICT របស់ប្រទេសកម្ពុជា។

(ច) ហេដ្ឋារចនាសម្ព័ន្ធ ICT៖ ត្រូវមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ICT ជាតិ ដែលអាចទុកចិត្តបាន ហើយមូលដ្ឋានត្រូវបានបង្កើតឡើងទូទាំងប្រទេសដើម្បីកាត់បន្ថយគម្លាតនៃការប្រើប្រាស់ព័ត៌មាន។ ជាពិសេសបច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជា ស្វែងរកការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធព័ត៌មាន (ការអភិវឌ្ឍបណ្តាញ) ក៏ដូចជាកម្មវិធី និងសេវាកម្ម ដែលត្រូវផ្តល់តាមរយៈហេដ្ឋារចនាសម្ព័ន្ធថ្មី។

(ឆ) ការអភិវឌ្ឍ ICT៖ (ក) បង្កើនកំរិតអក្ខរកម្មជនបង្គោលក្នុងចំនោមប្រជាជន ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍនៃភាពរំដើបរំជួលនៅទូទាំងប្រទេសកម្ពុជា ដែលជាអ្នកដើរតួសំខាន់ៗ ហើយផ្តល់ឱ្យនូវឱកាសស្មើៗគ្នាសម្រាប់ការទទួលបានការអប់រំ ICT។ ការអនុវត្តន៍បច្ចេកវិទ្យា ICT ក៏ពង្រីកដល់វិស័យអប់រំផងដែរដែលផ្តល់ផលប្រយោជន៍ដល់សាលារៀន និងស្ថាប័នអប់រំដទៃទៀត។សេចក្តីណែនាំពិសេសនៃបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ត្រូវបានលើកកម្ពស់ផងដែរ ដែលទី១៖ ការហ្វឹកហាត់អ្នកអប់រំ ដែលមានសមត្ថភាពផ្តោតលើវិស័យអប់រំពិតប្រាកដត្រូវបានអនុវត្តដើម្បីទទួលបាននូវការអប់រំ ICT សម្រាប់ប្រជាជនកម្ពុជា ដោយប្រជាជនកម្ពុជា។ ទី២៖ កន្លែងត្រូវបានផ្តល់ជូនដើម្បីពង្រីក និងការអភិវឌ្ឍការបង្រៀននៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យានៅគ្រប់កម្រិតទាំងអស់នៃការអប់រំផ្លូវការ និងក្រៅផ្លូវការនៅក្នុងប្រព័ន្ធរបស់ប្រទេស។ ទី៣៖ ការបណ្តុះបណ្តាល ICT ត្រូវបានលើកកម្ពស់ និងគាំទ្រសម្រាប់អ្នកធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយ សហគមន៍ និងអង្គការសង្គមស៊ីវិល អ្នកដឹកនាំសង្គមក៏ដូចជាមន្ត្រីផ្នែកឯកជន និងសាធារណៈ។ ទី៤៖ ការយកចិត្តទុកដាក់ជាពិសេសត្រូវបានផ្តល់ឱ្យដើម្បីសម្របសម្រួលប្រព័ន្ធសិក្សាថ្មី និងឱកាសប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ព័ត៌មានវិទ្យាសម្រាប់ស្ត្រី យុវវ័យ ជនពិការនិងអនក្ខរជនដើម្បីដោះស្រាយអតុល្យភាពសង្គម។ (ខ) បង្កើតអ្នកជំនាញការផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ដែលមានសមត្ថភាពប្រកួតប្រជែងក្នុងតំបន់ព្រោះវាមានសារៈសំខាន់ណាស់ ដែលទាមទារឱ្យមានការអភិវឌ្ឍក្រុមអ្នកជំនាញការផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា និងបុគ្គលិកផ្សេងទៀតសម្រាប់ឧស្សាហកម្មជាតិក៏ដូចជាសម្រាប់ក្រុមហ៊ុន និងវិស័យនានាដែលកម្មវិធី ICT ត្រូវបានអនុវត្ត។

ដើម្បីថែរក្សាកម្រិតបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ដែលគួរឱ្យគោរពក្នុងចំណោមបណ្តាប្រទេសក្នុងតំបន់អាស៊ានត្រូវចាំបាច់ធានាដល់ការផ្គត់ផ្គង់អ្នកជំនាញផ្នែកបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យាជាតិ។ កម្មវិធីបណ្តុះបណ្តាលតំរង់ទិសឆ្ពោះទៅរកការអភិវឌ្ឍនៃអ្នកជំនាញ ដែលមានជំនាញ និងចំណេះដឹងឯកទេសត្រូវបានតម្លើងឋានៈយ៉ាងខ្លាំង ជាមួយនឹងការបង្កើតអាងដ៏ធំនៃអ្នកជំនាញ ICT ដ៏អស្ចារ្យ ដើម្បីបន្តជាមួយកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍបច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធ និងឧស្សាហកម្មប្រកួតប្រជែងផ្នែកបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យានៅក្នុងប្រទេស ការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍អ្នកជំនាញការផ្នែកបច្ចេកវិទ្យា គមនាគមន៍និងព័ត៌មានវិទ្យា គឺជាបញ្ហាបន្ទាន់។ រាជរដ្ឋាភិបាលកម្ពុជាបានពង្រឹងការអនុវត្តផែនការសកម្មភាពពាក់ព័ន្ធនឹងការបណ្តុះបណ្តាលជំនាញទាំងរយៈពេលខ្លី និងរយៈពេលវែង។ ជំហាន ដំបូងសម្រាប់រដ្ឋាភិបាលកម្ពុជា គឺបង្កើតជំហារមួយសម្រាប់ មន្ត្រីព័ត៌មាន ប្រធានគ្រប់គ្រង ដើម្បីត្រួតពិនិត្យការអភិវឌ្ឍធនធានមនុស្សស្នូលនៃកម្មករ ICT ដែលមានជំនាញនៅក្នុងប្រទេស និងដើម្បីបង្កើនឋានៈរបស់ពួកគេតាមតម្រូវការ។ (គ) ការគាំទ្រស្ត្រីក្នុងការអភិវឌ្ឍនៅក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាៈ ដើម្បីអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានវិទ្យាអ្នកជំនាញសម្រាប់ឧស្សាហកម្មជាតិ និងវិស័យពាក់ព័ន្ធនានា មានសារៈសំខាន់ណាស់ក្នុងការចូលរួមក្នុងដំណើរការនេះជាមួយនឹងវត្តមានរបស់ស្ត្រី ជាពិសេសនៅក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា ស្ត្រីនៅតែមិនចូលរួមពាក់ព័ន្ធដូចដែលពួកគេគួរទទួលបាន។ "អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារី" បុរស និងស្ត្រីមានសិទ្ធិស្មើគ្នា ហេតុដូច្នេះហើយពួកគួរទទួលបានការយកចិត្តទុកដាក់ស្មើភាពគ្នានៅក្នុងកន្លែងធ្វើការ។ ដូចដែលបានបង្ហាញនៅក្នុងប្រទេសជាច្រើន ស្ត្រីមានសមត្ថភាពក្នុងការងារ

យ៉ាងសកម្ម។ ទ្រព្យសម្បត្តិដ៏ធំបំផុតរបស់ប្រទេសកម្ពុជា គឺស្ថិតនៅក្នុងប្រជាជនរបស់ខ្លួនដូច្នេះការធានានូវការអនុវត្តទាំងបុរស និងស្ត្រីគឺមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍប្រទេសទាំងមូល ដែលវានឹងក្លាយជាកាកសំណល់របស់មនុស្សល្អ។ លើសពីនេះទៀតការអភិវឌ្ឍបរិយាកាសដែលសមស្របសម្រាប់ស្ត្រីធ្វើការងារ គឺមានសារៈសំខាន់ដូចគ្នា។ រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងអភិវឌ្ឍធនធាននៃប្រព័ន្ធទូរគមនាគមន៍បច្ចេកវិទ្យាស្ត្រី និងបុគ្គលិកផ្សេងទៀត។ ជាមួយគ្នានេះផងដែរការបង្កើតផែនការសកម្មភាពពាក់ព័ន្ធនឹងការបណ្តុះបណ្តាលអ្នកឯកទេសផ្នែកស្ត្រីឱ្យបានខ្លី និងរយៈពេលវែងត្រូវបានលើកទឹកចិត្តខ្ពស់។

(ជ) ការប្តេជ្ញាចិត្តចំពោះបញ្ហាសកលៈ សំដៅជារួមដល់ការលើកទឹកចិត្តដល់ការយល់ដឹងអំពីបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា ជាឧបករណ៍មួយសម្រាប់ប្រយុទ្ធប្រឆាំងនឹងការកើនឡើងកម្តៅផែនដី។ រាជរដ្ឋាភិបាលកំពុងអនុវត្តយ៉ាងសកម្មគំនិតផ្តួចផ្តើមតាមរយៈការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ដើម្បីប្រយុទ្ធប្រឆាំងនឹងការឡើងកំដៅផែនដីដែលកំពុងស្ថិតក្នុងដំណាក់កាលដ៏សំខាន់។ ជាពិសេសនេះគឺជាការពង្រឹងការប្តេជ្ញាចិត្តដើម្បីធ្វើឱ្យវិស័យឯកជនស្ថាប័នសាធារណៈ និងសាធារណជនទូទៅបានដឹងពីទំនាក់ទំនងជិតស្និទ្ធរវាងបញ្ហាប្រឈមជាតិរបស់កម្មវិធី ICT និងវិធានការដើម្បីបញ្ឈប់ការឡើងកំដៅផែនដី។ រដ្ឋាភិបាលនៃប្រទេសកម្ពុជាបង្កើនទម្រង់ជាតិរបស់ខ្លួនមុនពេលសហគមន៍អន្តរជាតិតាមរយៈមធ្យោបាយ លើកស្ទួយការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ដែលជាផ្នែកមួយសំខាន់បំផុតរបស់ពួកគេហើយវិធានការនានាក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ គឺដើម្បីកាត់បន្ថយការឡើងកំដៅផែនដី។ លើសពីនេះទៅទៀតផលប៉ះពាល់នៃការកើនឡើងកំដៅភពផែនដីរួមទាំងគ្រោះរាំងស្ងួត ភ្លៀងធ្លាក់ខ្លាំង និងទឹកជំនន់ គឺជាបញ្ហាបន្ទាន់មួយចំពោះប្រជាជនកម្ពុជា។[38]

កត្តាចាំបាច់ខាងលើនេះហើយ ដែលជាយុទ្ធសាស្ត្របន្ថែមក្នុងការចូលរួមពង្រឹងការអនុវត្តការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចនៅកម្ពុជា។ ជាមួយគ្នានេះដែរបន្ទាប់អំពីការអនុវត្តមួយរយៈកាលកន្លងមកបញ្ហាប្រឈមដែលបានរកឃើញ ក៏ជាជំហានថ្មីមួយទៀតដែលជាស់តឿនដល់កម្ពុជាថានឹងត្រូវទទួលយក និងត្រៀមខ្លួនសិក្សានូវអ្វីដែលថ្មីសម្រាប់ការអភិវឌ្ឍខ្លួនលើវិថីបច្ចេកវិទ្យាឱ្យបានជឿនលឿនទៅមុនជាចីរភាព។

---

[38] NiDA, National អាជ្ញាធរអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាឆ្នាំ២០០៤

# សេចក្ដីសន្និដ្ឋាន

ការគ្រប់គ្រងរដ្ឋបាល តាមប្រព័ន្ធអេឡិចត្រូនិច នៅកម្ពុជា ដែលសំដៅដល់ការអនុវត្តតាមបែប រដ្ឋបាលទំនើបនេះ គឺជាការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗមកជំនួសការអនុវត្តតាមបែបប្រពៃណីពីមុនក្នុងកិច្ចការឆ្លើយតប និងបម្រើសេវាសាធារណៈជូនដល់ប្រជាជនគ្រប់រូប។ យុទ្ធសាស្ត្រនៃការដាក់ឱ្យអនុវត្តប្រព័ន្ធនេះនៅតាមក្រសួង ស្ថាប័ន អង្គភាពនានាកន្លងមក គឺបានចូលរួមយ៉ាងសកម្មជាមួយនឹងការផ្ដល់សេវាដ៏ល្អប្រសើរសម្រាប់ប្រជាពលរដ្ឋ ជាពិសេសនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលបច្ចេកវិទ្យាសម័យថ្មីត្រូវបានអ្នកទទួលសេវាកម្ម (ប្រជាពលរដ្ឋ) បានយល់ជ្រួតជ្រាប និងប្រើប្រាស់យ៉ាងច្រើនផងដែរនោះ។ ប្រការនៃការយល់ដឹងទាំងនេះបានធ្វើឱ្យអ្នកផ្ដល់សេវា (រដ្ឋ) កាន់តែមានភាពងាយស្រួលមួយកម្រិតបន្ថែមទៀត ព្រោះមានការសហការល្អក្នុងការប្រើប្រាស់ប្រព័ន្ធទំនើបនេះ។ ទោះជាយ៉ាងណាក៏ដោយ ដំណើរការនៃការអនុវត្តតាមប្រព័ន្ធនេះនៅមានកម្រិតនៅឡើយ ដែលនៅ មានឧបសគ្គនៃការរីកចម្រើនជាច្រើនបានរាំងស្ទះក្នុងការប្រតិបត្តិការមួយនេះ។

ការអនុវត្តនៅកម្ពុជា ដែលបាននឹងជួបបញ្ហាប្រឈមចម្បងៗនោះ គឺបានពន្យារដំណើរការគ្រប់គ្រងតាមរដ្ឋបាលទំនើបនេះដោយកត្តាធំៗជាច្រើន ដែលចាំបាច់ត្រូវស្វែងរក និងដាក់ចេញនូវយុទ្ធសាស្ត្រដោះស្រាយជាបន្ទាន់ដូចជា កត្តាសង្គម (ឆន្ទៈនយោបាយ, ប្រវត្តិសាស្ត្រ) កត្តាបច្ចេកទេស (ការអប់រំ, ការផ្សព្វផ្សាយ) និងកត្តាបុគ្គល (សមត្ថភាព, ការយល់ដឹង)។ កត្តាសង្គមដែលជាបញ្ហាមួយក្នុងការអនុវត្តប្រព័ន្ធរដ្ឋបាលទំនើបនោះគឺយើងសំដៅការទទួលផលដែលសល់ពីសង្គ្រាមរ៉ាំរ៉ៃជាង៣០ឆ្នាំកន្លងមកនេះ ទាំងហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងដែលទើបតែនឹងរឹងមាំនារយៈកាលប៉ុន្មានឆ្នាំចុងក្រោយនេះប៉ុណ្ណោះទើបបណ្ដាលឱ្យមានភាពយឺតយ៉ាវ នៅក្នុងការទទួលយកភាពថ្មីនៃបច្ចេកវិទ្យា។ ជាមួយគ្នានេះដែររដ្ឋាភិបាលត្រូវមានឆន្ទៈនយោបាយខ្ពស់ និងប្ដេជ្ញាចិត្តក្នុងការដាក់បញ្ចូល និងតាមដានការអនុវត្តប្រព័ន្ធអេឡិចត្រូនិចនៅក្នុងកិច្ចការងារសាធារណៈទាំងឡាយ និងដាក់ចេញនូវយុទ្ធសាស្ត្របន្ថែមដើម្បីពង្រឹង និងពង្រីកឱ្យបានដល់គ្រប់មូលដ្ឋាន និងលើគ្រប់វិស័យ ជាពិសេសក៏មិនភ្លេចផងដែរការដាក់ឱ្យវិស័យឯកជនចូលរួមអភិវឌ្ឍទន្ទឹមគ្នានេះដែរ។ កត្តាបច្ចេកទេសនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធអេឡិចត្រូនិចនេះក្ដី កម្ពុជាយើងទទួលស្គាល់នូវកម្រិតនៃការទទួលយកភាពថ្មីទាំងនេះ ដោយយើងនៅមានការខ្វះខាតមួយចំនួនទៀត ដែលត្រូវខិតខំប្រឹងប្រែងស្រាវជ្រាវ និងសហការដើម្បីក្លាយខ្លួនជាប្រទេសដែលមានគ្រប់គ្រាន់នៃសម្ភារៈបរិក្ខារសម្រាប់ការអនុវត្ត ការអប់រំ និងបណ្ដុះបណ្ដាលជាដើម។ ជាមួយគ្នានេះដែរការផ្សព្វផ្សាយនៃប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច នៅតែមិនទាន់បានទូលំទូលាយនៅឡើយនាតំបន់ដាច់ស្រយាល ឬជនបទមួយចំនួន បើទោះបីជាយើងបានឈានជើងចូលមកដល់សម័យកាលនៃ

បច្ចេកវិទ្យានេះក្តី។ ប្រការនេះទាំងរដ្ឋាភិបាល និងទាំងប្រជាជនខ្លួនឯងផ្ទាល់ ត្រូវយកចិត្តទុកដាក់តាមដាន និងសិក្សាបន្ថែមដើម្បីផ្តល់ភាពងាយស្រួលដល់ខ្លួនឯងក្នុងការទាមទារសេវារហ័ស និងមានប្រសិទ្ធភាពពីអ្នកផ្តល់សេវា (រដ្ឋ)។ កត្តារួមផ្សំមួយទៀតដែរ គឺកត្តាបុគ្គល ដែលនៅក្នុងប្រទេសកម្ពុជាយើងគឺសំដៅដល់ទាំងអ្នកផ្តល់សេវា (រដ្ឋ, ក្រសួង, ស្ថាប័ន, អង្គភាពនានា) និងអ្នកទទួលសេវា (ប្រជាពលរដ្ឋ, បុគ្គលិក) ផងដែរ។ កត្តានេះគឺយើងមិនទាន់មានភាពរឹងមាំនៅឡើយទេ ចំពោះសមត្ថភាព និងកម្រិតនៃការយល់ដឹងលើប្រព័ន្ធបច្ចេកវិទ្យាទំនើប បានស៊ីជម្រៅនៅឡើយ ដែលទាមទារឱ្យមានការអប់រំ និងបណ្តុះបណ្តាលជាប្រចាំរហូតដល់ភាពមួយដែលអាចទទួលយកបាន និងអាចយកទៅប្រើប្រាស់បាន ហើយជាពិសេសត្រូវមានគ្រប់ទីតាំងមូលដ្ឋាន ដែលបម្រើសេវាទាំងនោះ ដើម្បីឆ្លើយតបទាន់ពេលវេលារាល់ពេលពលរដ្ឋគ្រប់រូបមានតម្រូវការណាមួយ។

គោលដៅចម្បងក្នុងការដាក់ឱ្យអនុវត្តតាមប្រព័ន្ធអេឡិចត្រូនិច ដូចដែលយើងបានដឹងមកនេះ គឺដើម្បីឈានឆ្ពោះទៅកាន់ អភិបាលកិច្ចល្អមួយ ដែលត្រូវបានគេកត់សម្គាល់ឃើញថាវាជាឧត្តមគតិដែលពិបាកនឹងសម្រេចបានក្នុងការចូលរួមដោយបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា និងហិរញ្ញវត្ថុតែករណីធនធាន និងប្រតិបត្តិការប្រកបដោយនិរន្តភាពត្រូវបានយកចិត្តទុកដាក់សម្រាប់ការអនុវត្តប្រព័ន្ធអេឡិចត្រូនិច (ICT) នោះ វានឹងជំរុញការគ្រប់គ្រងអេឡិចត្រូនិចសម្រាប់កម្ពុជា តំបន់អាស៊ាន និងសកលភាវូបនីយកម្មបានកាន់តែល្អប្រសើរតែម្តង ហើយជាមួយគ្នានេះយើងនឹងសម្រេចបាន នូវអភិបាលកិច្ចល្អ (Good Governance) ស្របពេលជាមួយនឹងទំនើបកម្មនៅកម្ពុជាយើងផងដែរ។

រាជរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងយកចិត្តទុកដាក់ និងធ្វើការលើកកម្ពស់ ការយល់ដឹងនានា និងបានដាក់ជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍបន្ថែមទៀតប្រព័ន្ធអេឡិចត្រូនិច ក្នុងកិច្ចការបម្រើប្រជាពលរដ្ឋ។ រដ្ឋាភិបាល ក៏បានកំណត់ទិសដៅច្បាស់លាស់សម្រាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មានវិទ្យា ដោយផ្សារភ្ជាប់នឹងគោលនយោបាយរដ្ឋាភិបាលអេឡិចត្រូនិកនៅកម្ពុជា។ ក្នុងនោះមានវិស័យបីនៃការអនុវត្តន៍ការគ្រប់គ្រងអេឡិចត្រូនិចៈ (ក) ការគ្រប់គ្រងអេឡិចត្រូនិចសំដៅលើការកែលម្អដំណើរការរបស់រដ្ឋាភិបាល និងកិច្ចការផ្ទៃក្នុងនៃវិស័យសាធារណៈជាមួយនឹងដំណើរការព័ត៌មានថ្មីដែលប្រតិបត្តិដោយ ICT, (ខ) សេវាកម្មអេឡិចត្រូនិចសំដៅលើការផ្តល់សេវាសាធារណៈកាន់តែប្រសើរឡើងដល់ប្រជាជន, (គ) របបលិទ្ធិប្រជាធិបតេយ្យសម័យរដ្ឋបាលទំនើប មានន័យដល់ការចូលរួមកាន់តែច្រើន និងកាន់តែសកម្មរបស់ប្រជាពលរដ្ឋដោយបច្ចេកវិទ្យាថ្មី (ICT) ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។

# អនុសាសន៍

អភិបាលកិច្ច ដោយប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា អាចបង្កើតបានអភិបាលកិច្ចល្អ (Good Governance) កាន់តែប្រសើរឡើង។ ការអនុវត្តការគ្រប់គ្រងតាមប្រព័ន្ធអេឡិចត្រូនិចនេះ គឺជាការអនុវត្តអភិបាលកិច្ច ដែលមានសារៈសំខាន់មួយ និងជាគន្លឹះក្នុងដំណើរការអភិបាលកិច្ចល្អនៅកម្ពុជាសម្រាប់អភិបាលកិច្ចថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន។ លើសពីនេះទៅទៀតអេឡិចត្រូនិចគឺមានគន្លឹះសំខាន់ចំពោះអភិបាលកិច្ចល្អ ខណៈពេលដែលរដ្ឋាភិបាលបានដាក់មកអនុវត្តដើម្បីជាគន្លឹះដ៏សំខាន់មួយក្នុងការកាត់បន្ថយភាពក្រីក្រសម្រាប់ប្រជាជនកម្ពុជា។ សព្វថ្ងៃសម្រាប់ប្រទេសកម្ពុជាក្នុងសម័យទំនើបនៃបច្ចេកវិទ្យាសកលភាវូបនីយកម្ម ការគ្រប់គ្រងគឺជាគន្លឹះមួយសម្រាប់អភិបាលកិច្ចល្អហើយក៏ជាវិស័យដ៏សំខាន់បំផុត សម្រាប់ការកាត់បន្ថយភាពក្រីក្រក្នុងយុទ្ធសាស្ត្ររបស់ថ្នាក់ ដឹកនាំគ្រប់ជាន់ថ្នាក់ ដ៏ដូចជារាជរដ្ឋាភិបាលកម្ពុជា។ ដោយសារភាពចាំបាច់នៃការប្រើប្រាស់ ICT មេដឹកនាំទាំងអស់ និងអ្នកគ្រប់គ្រង ដែលត្រូវបានផ្តល់អាទិភាពជាមុនកំពុងព្យាយាមយកចិត្តទុកដាក់យ៉ាងខ្លាំង និងសម្របខ្លួនទៅនឹង ICT នេះ។ មួយវិញទៀត បុគ្គលិកនិងយុវវ័យកម្ពុជាគាត់គួរតែប្រឹងប្រែងធ្វើបច្ចុប្បន្នភាពអក្ខរកម្មរបស់គាត់លើបច្ចេកវិទ្យា អាយស៊ីធី (ICT) នៅថ្ងៃនេះស្របនឹងការវិវឌ្ឍរបស់ពិភពលោក។

ជារួម ការអនុវត្តការគ្រប់គ្រងតាមប្រព័ន្ធអេឡិចត្រូនិច កន្លងមកបានចូលរួមបម្រើសេវាសាធារណៈយ៉ាងរហ័ស តម្លាភាព និងមានប្រសិទ្ធភាពខ្ពស់ ឆ្លើយតបទាន់ពេលវេលានូវតម្រូវការរបស់ប្រជាពលរដ្ឋ កាត់បន្ថយអំពើពុករលួយ ការចំណាយក្រៅផ្លូវការផ្សេងៗ បើទោះបីជាមានបញ្ហាប្រឈមមួយចំនួនទាក់ទងនឹងសមត្ថភាពបច្ចេកទេសក្តី សម្ភារៈបរិក្ខារនៅតាមអង្គភាពផ្តល់សេវានានាក្តី ក៏ប្រព័ន្ធនេះនៅតែមានសារៈសំខាន់សម្រាប់កម្ពុជាក្នុងកិច្ចការបន្តបន្ទាប់នាពេលអនាគតដ៏ឆាប់នេះ។

- ជាមួយគ្នានេះសំណួរដែលកម្ពុជាត្រូវចោទសួរខ្លួនឯងបន្ទាប់ទៀតគឺថា តើប្រទេសអភិវឌ្ឍណាមួយ ដែលយើងគួរយកជាប្រទេសគំរូ (Model) សម្រាប់ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាជាពិសេសការគ្រប់គ្រងរដ្ឋបាល តាមប្រព័ន្ធអេឡិចត្រូនិចឱ្យបានកាន់តែប្រសើរ?
- ប្រធានបទ ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានវិទ្យាទាំងនេះរួមមាន៖ ទស្សនវិស័យ សកល និងតំបន់ ឬភូមិភាគ, គោលនយោបាយព័ត៌មានវិទ្យា (IT) ជាតិ, បច្ចេកវិទ្យាព័ត៌មានវិទ្យា ក្នុងការអប់រំ/ការអប់រំនៅក្នុង បច្ចេកវិទ្យាព័ត៌មានវិទ្យា, រដ្ឋាភិបាលអេឡិចត្រូនិចដំណើរការស្តង់ដារ, ការរៀបចំអេឡិចត្រូនិកកម្ពុជា និងការអភិវឌ្ឍ អ៊ីនធឺណេត (Internet) សម្រាប់ទាំងអស់គ្នា។

- ការគិតគូរបន្ថែមលើបញ្ហាប្រឈម ដែលបានជួបប្រទះកន្លងមកគឺយើង ក៏ត្រូវគិតគូរពីហានិភ័យនានា នៃការគ្រប់គ្រងប្រព័ន្ធអេឡិចត្រូនិចផងដែរ ដែលពិភពលោកទាំងមូលកំពុងមានការប្រុងប្រយ័ត្ន និងដោះស្រាយលើការចូលលួចទិន្នន័យ និងគ្រប់គ្រងប្រព័ន្ធដោយក្រុម Hacker (ឧក្រិដ្ឋជនអេឡិចត្រូនិច)។

លទ្ធផលពីសារណានេះគួរតែត្រូវបានសំដៅជាការរកឃើញបឋម និងអនាគត ហើយការសិក្សាជាក់ស្តែងលើដំណោះស្រាយនានានៅកម្ពុជា ក៏ដូចជាពិភពលោកគួរត្រូវបានស្នើឡើង។

# ឯកសារយោង

## ឯកសារជាខេមរភាសា


១- ច្បាប់ស្តីពីទូរគមនាគមន៍, រដ្ឋសភាអនុម័តកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥។

២- គោលនយោបាយ និងយុទ្ធសាស្រ្តប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ក្នុងការអប់រំនៅកម្ពុជា, ក្រសួងអប់រំ យុវជន និងកីឡា, ខែធ្នូ ឆ្នាំ២០០៩។

៣- គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈរបស់ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល នៃរាជរដ្ឋាភិបាលកម្ពុជា, ខែមករា ឆ្នាំ២០១១។

៤- អនុក្រឹត្យ លេខ១១០ អនក្រ.បក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការផ្តល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យ បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន របស់រាជរដ្ឋាភិបាលកម្ពុជា

៥- យុទ្ធសាស្រ្តចតុកោណ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជាដំណាក់កាលទី២, រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨

៦- វចនានុក្រមខ្មែរ, សម្តេចសង្ឃរាជ ជួន ណាត, ភ្នំពេញ, ឆ្នាំ១៩៦៧។

៧- សុន្ទរកថា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការបង្កើតវិស័យ ICT ដល់យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី២ ថ្លែងក្នុងពិធីបើកការដាក់ឱ្យប្រើប្រព័ន្ធអេឡិចត្រូនិច សម្រាប់ ក្រុមប្រឹក្សារដ្ឋមន្ត្រី ឆ្នាំ២០០៩

៨- សុន្ទរកថា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីក្នុងការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច ថ្លែងក្នុងពិធីចែកសញ្ញាបត្រដល់និស្សិតនៃវិទ្យាស្ថានវ៉ាន់ដា នាថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥

៩- សុន្ទរកថា ឯកឧត្តម ពេជ្រ ប៊ុនធិន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ស្តីពីការចូលរួម ប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចក្នុងមុខងារសាធារណៈថ្លែងក្នុងពិធីប្រគល់វិញ្ញាបនបត្រដល់សិស្សសាលាភូមិន្ទរដ្ឋបាល នៅវិទ្យាស្ថានជាតិអប់រំ នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧


## ឯកសារជាភាសាបរទេស


១០- A Key to Good Governance in Cambodia (vol.5, No.1,2015. Author: PHO Kevreaksmey), July, 2017

១១- Cambodia: The road to e-governance , Leewood Phu, National ICT Development Authority (NiDA), July, 2017

១២- What is Good Governance, United Nation Economics and Social Commission for Asia and the Pacific, July, 2017

# ព្រះរាជក្រម

នស/រកម/១២១៥/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីទូរគមនាគមន៍ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ទូរគមនាគមន៍

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណង ៖

- ធានាការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្ដាញនិងការផ្ដល់សេវាទូរគមនាគមន៍ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព គុណភាព ភាពអាចទុកចិត្តបាន និងថ្លៃសមរម្យ ដែលឆ្លើយតបទៅនឹងសេចក្ដីត្រូវការនៃការអភិវឌ្ឍ សង្គម និងសេដ្ឋកិច្ច
- ធានាការចូលរួមនិងលើកទឹកចិត្តដល់វិស័យឯកជន ក្នុងការអភិវឌ្ឍវិស័យទូរគមនាគមន៍ និងការប្រកួត ប្រជែងស្របច្បាប់និងប្រកបដោយប្រសិទ្ធភាព និង
- ធានាការការពារអ្នកប្រើប្រាស់ និងជំរុញការកៀរគរចំណូលថវិកាជាតិ ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅកំណត់អំពី ៖

- សមត្ថកិច្ចរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ការបង្កើត មុខងារ និងភារកិច្ចរបស់និយ័តករទូរគមនាគមន៍កម្ពុជា
- ចំណាត់ថ្នាក់និងប្រភេទនៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណ
- សមត្ថកិច្ចគ្រប់គ្រង និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្ដាញ
- ស្តង់ដាគុណភាពនៃសេវា និងគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍
- កាតព្វកិច្ចសេវាសកល
- ការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ
- ប្លង់លេខទូរគមនាគមន៍ជាតិ និងអាសយដ្ឋានអេឡិកត្រូនិក
- វិធានស្ដីពីថ្លៃសេវាទូរគមនាគមន៍ និងការប្រកួតប្រជែងដោយស្របច្បាប់ និងស្មោះត្រង់
- សិទ្ធិរបស់ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និង
- សិទ្ធិរបស់អ្នកប្រើប្រាស់ ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះគ្រប់ប្រតិបត្តិការទូរគមនាគមន៍ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែវិស័យសន្តិសុខ និងការពារជាតិ ។

**មាត្រា ៤.-**

និយមន័យនៃពាក្យបច្ចេកទេសក្នុងច្បាប់នេះ ត្រូវបានកំណត់ដោយសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

# ជំពូកទី ២
## សមត្ថកិច្ចរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

**មាត្រា ៥.-**

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សរសេរកាត់ថា **ក.ប.ទ.** ។

**ក.ប.ទ.** មានសមត្ថកិច្ចដូចតទៅ ៖

ក- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងក្របខណ្ឌគតិយុត្តសម្រាប់គ្រប់គ្រងប្រតិបត្តិការ ទូរគមនាគមន៍និងហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ខ- ធ្វើជាហត្ថលេខី និងជាតំណាងនៃរាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យទូរគមនាគមន៍

គ- ជំរុញការបង្កើត និងការប្រើប្រាស់កម្មវិធីកាតព្វកិច្ចសេវាសកល និងផែនការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ

ឃ- ផ្តល់សេចក្តីណែនាំ ជួយសម្រួលកិច្ចការពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ដល់ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍

ង- លើកកម្ពស់ និងជំរុញការអនុវត្តច្បាប់នេះឲ្យមានប្រសិទ្ធភាព

ច- ចេញប្រកាសពាក់ព័ន្ធនឹងចំណុចដូចខាងក្រោម ៖

១) លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ ការកែប្រែ ការព្យួរ ការផ្ទេរ និងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ

២) ការតភ្ជាប់បណ្តាញរវាងប្រតិបត្តិករទូរគមនាគមន៍

៣) ការកំណត់ស្តង់ដាសម្រាប់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញ និងការផ្តល់សេវាទូរគមនាគមន៍ ព្រមទាំងស្តង់ដាគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍

៤) ប្លង់លេខទូរគមនាគមន៍ជាតិ និងអាសយដ្ឋានអេឡិកត្រូនិក

៥) លក្ខខណ្ឌនៃការបែងចែក និងការប្រើប្រាស់បន្ទាត់ហ្វ្រេកង់ស៍ និងការផ្តល់ ការកែប្រែ ការព្យួរ ការផ្ទេរ និងការដកហូតអាជ្ញាបណ្ណហ្វ្រេកង់ស៍វិទ្យុ

៦) សកម្មភាពប្រកួតប្រជែងស្របច្បាប់ និងស្មោះត្រង់របស់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍

៧) ការគ្រប់គ្រងប្រព័ន្ធ និងសេវាអ៊ិនធឺណិត និង

ឆ- បំពេញកិច្ចការផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់នេះ ឬបទប្បញ្ញត្តិផ្សេងទៀតដែលពាក់ព័ន្ធ ។

**មាត្រា ៦.-**

**គ.ប.ទ.** មានសមត្ថកិច្ចគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យាគ្រប់ប្រភេទ និងសេវាថ្មីៗស្របតាមការវិវត្តនៃបច្ចេកវិទ្យាលើវិស័យនេះ ។ គ្រប់ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ត្រូវផ្តល់ទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យាមក **គ.ប.ទ.**។

ការប្រព្រឹត្តទៅនៃការគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍និងព័ត៌មានវិទ្យា ត្រូវកំណត់ដោយប្រកាសរបស់ **គ.ប.ទ.**។

**មាត្រា ៧.-**

ក្នុងករណីប្រធានសក្តិ **គ.ប.ទ.** ឬក្រសួង ស្ថាប័នមានសមត្ថកិច្ច អាចបញ្ជាទៅប្រតិបត្តិករទូរគមនាគមន៍ដែលពាក់ព័ន្ធឲ្យចាត់វិធានការចាំបាច់ ដោយផ្អែកតាមការសម្រេចរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៣
## និយ័តករទូរគមនាគមន៍កម្ពុជា

### ផ្នែកទី ១
### ការបង្កើតនិយ័តករទូរគមនាគមន៍កម្ពុជា

**មាត្រា ៨.-**

និយ័តករទូរគមនាគមន៍កម្ពុជា ត្រូវបានបង្កើតឡើងដោយច្បាប់នេះ ។

និយ័តករទូរគមនាគមន៍កម្ពុជា សរសេរកាត់ថា **ន.ទ.ក.** ។

**មាត្រា ៩.-**

**ន.ទ.ក.** ត្រូវដឹកនាំដោយប្រធាន ១(មួយ)រូប ឋានៈស្មើរដ្ឋលេខាធិការ និងមានសមាជិកមួយចំនួន ដែលមានឋានៈស្មើអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

ប្រធាននិងសមាជិក **ន.ទ.ក.** មានអាណត្តិ ៣(បី) ឆ្នាំ ។

បេក្ខភាពរបស់ប្រធាន និងសមាជិក **ន.ទ.ក.** ត្រូវជ្រើសរើស និងស្នើឡើងដោយរដ្ឋមន្ត្រី **គ.ប.ទ.** ជូនប្រមុខរាជរដ្ឋាភិបាល ។ ប្រធាន និងសមាជិក **ន.ទ.ក.** ត្រូវមានសញ្ញាបត្រថ្នាក់ឧត្តមសិក្សាមានសមត្ថភាព និងលក្ខណសម្បត្តិគ្រប់គ្រាន់ និងសមស្របក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ព្រមទាំងមានបទពិសោធយ៉ាងតិច ១០(ដប់) ឆ្នាំ សម្រាប់ជំនាញមួយ ឬច្រើន ដូចជាទូរគមនាគមន៍ ព័ត៌មានវិទ្យា នីតិសាស្ត្រ រដ្ឋបាលសាធារណៈ សេដ្ឋកិច្ច និងពាណិជ្ជកម្ម ព្រមទាំងផ្នែកផ្សេងទៀតតាមតម្រូវការជាក់ស្តែង ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## ផ្នែកទី ២
## មុខងារ និងភារកិច្ចរបស់និយ័តករទូរគមនាគមន៍កម្ពុជា

**មាត្រា ១០.-**

**ន.ទ.ក.** បំពេញមុខងារនិងភារកិច្ច ដោយមានស្វ័យភាពខាងផ្នែករដ្ឋបាល និងនិយ័តកម្ម ព្រមទាំងដោយឯករាជ្យពីប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ។

**ន.ទ.ក.** មានថវិកាស្វយ័តដោយត្រូវឆ្លុះបញ្ចាំងជាឧបសម្ព័ន្ធនៃថវិការបស់ **ក.ប.ទ.** ។

**មាត្រា ១១.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃថវិការបស់ **ន.ទ.ក.** ត្រូវកំណត់ដោយអនុក្រឹត្យយោងតាមសំណើរបស់ **ក.ប.ទ.** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

**មាត្រា ១២.-**

**ន.ទ.ក.** មានមុខងារ និងភារកិច្ចដូចខាងក្រោម ៖

ក- ធ្វើនិយ័តកម្មស្របតាមគោលនយោបាយនិងក្របខណ្ឌគតិយុត្តនៃវិស័យទូរគមនាគមន៍ និងបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា

ខ- ត្រួតពិនិត្យ និងតាមដានការផ្តល់សេវាទូរគមនាគមន៍ស្របតាមបទប្បញ្ញត្តិជាធរមាន

គ- លើកសំណើផ្តល់យោបល់លើវិសោធនកម្មប្រកាស ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍

ឃ- ចេញសេចក្តីសម្រេចបន្ថែមលើករណីមួយចំនួនស្របតាមមាត្រា ៥ ចំណុច(ច)នៃច្បាប់នេះ

ង- រាយការណ៍ និងផ្តល់អនុសាសន៍ជូនរដ្ឋមន្ត្រី **ក.ប.ទ.** នូវបញ្ហាទាំងអស់ពាក់ព័ន្ធនឹងការគ្រប់គ្រងការអភិវឌ្ឍ និងការត្រួតពិនិត្យវិស័យទូរគមនាគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ច- ផ្តល់ កែប្រែ ព្យួរ ផ្ទេរ ឬដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

ឆ- ពិនិត្យសំណុំឯកសារស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ និងអនុញ្ញាតលើពាក្យស្នើសុំដែលបានបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

ជ- ពិនិត្យឯកសារផ្តល់ព័ត៌មានទាក់ទងនឹងសំណុំឯកសារស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណដែលដាក់ពាក្យសុំមក **ន.ទ.ក.** ដើម្បីធានានូវការគោរពតាមលក្ខខណ្ឌ នៃច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត និងចុះបញ្ជីឯកសារដែលបានបំពេញតាមលក្ខខណ្ឌកំណត់

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ឈ-ត្រួតពិនិត្យឯកសារផ្តល់ព័ត៌មានអំពីការគ្រប់គ្រងថ្លៃដើម របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ដោយសវនករឯករាជ្យដែលទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងព័ត៌មានពុំមែន ហិរញ្ញវត្ថុដែលត្រូវផ្តល់ជូនដោយប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍រៀងរាល់ឆ្នាំសារពើពន្ធ ដើម្បីជានានូវការគោរពលក្ខខណ្ឌប្រកួតប្រជែងនៅក្នុងច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

ញ- ដើរតួនាទីជាស្ថាប័នត្រួតពិនិត្យ និងដោះស្រាយវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការទូរគមនាគមន៍ ស្របតាមការកំណត់នៃច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

ដ- ចាត់វិធានការសមស្របតាមច្បាប់នេះ ដើម្បីសហការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបអាជីវកម្មខុសច្បាប់ ផ្ទុយនឹងក្រមសីលធម៌ លក្ខខណ្ឌនៃបច្ចេកវិទ្យា លក្ខខណ្ឌនៃស្តង់ដាគុណភាពនៃសេវា និងគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ដែលត្រូវកំណត់ក្នុងច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

ឋ- ដឹកនាំរៀបចំក្រមសីលធម៌វិជ្ជាជីវៈនៃវិស័យទូរគមនាគមន៍ ។

**មាត្រា ១៣.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ **ន.ទ.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤

## លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណ

**មាត្រា ១៤.-**

គ្មានបុគ្គលណាអាចបំពេញប្រតិបត្តិការទូរគមនាគមន៍ ឬតាំងខ្លួនជាប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ទេ លើកលែងតែបុគ្គលនោះបានទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណពី **ន.ទ.ក.** ស្របតាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

### ផ្នែកទី ១

### លក្ខខណ្ឌតម្រូវនៃការស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ

**មាត្រា ១៥.-**

បុគ្គលទាំងឡាយត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតដើម្បីបំពេញប្រតិបត្តិការពី **ន.ទ.ក.** ដូចតទៅ ៖

ក- ការនាំចូល ការនាំចេញ ការផ្គត់ផ្គង់ និងការចែកចាយគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍

ខ- ការបើកអាជីវកម្មសាលបម្រើសេវាអ៊ិនធឺណិត

គ- ការបើកលក់ និង/ឬជួសជុលគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍

ឃ- ការបោះពុម្ពផ្សាយសៀវភៅលេខទូរគមនាគមន៍ និង

ង- ការធ្វើប្រតិបត្តិការផ្សេងទៀត ដែលកំណត់ដោយប្រកាសរបស់ **ក.ប.ទ.** ។

**មាត្រា ១៦.-**

បុគ្គលទាំងឡាយត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ ដើម្បីបំពេញប្រតិបត្តិការពី **ន.ទ.ក.** ដូចតទៅ ៖

ក- ការទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារនាំចូល ផ្គត់ផ្គង់ និងចែកចាយ គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍

ខ- ការទទួលស្គាល់យថាប្រភេទនៃគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និង

គ- ប្រតិបត្តិការផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់ **ក.ប.ទ.** ។

**មាត្រា ១៧.-**

បុគ្គលទាំងឡាយត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ដើម្បីបំពេញប្រតិបត្តិការពី **ន.ទ.ក.** ដូចតទៅ ៖

ក- ការស្ថាបនា ឬ/និងការផ្តល់សេវាប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទូរគមនាគមន៍

ខ- ការផ្តល់សេវាទូរគមនាគមន៍ និង

គ- ប្រតិបត្តិការផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់ **ក.ប.ទ.** ។

**មាត្រា ១៨.-**

ប្រតិបត្តិករទូរគមនាគមន៍ណាដែលបានទទួលការណែនាំពី **ន.ទ.ក.** តាមមាត្រា ៧៨ កថាខណ្ឌទី១ នៃច្បាប់នេះ ដែលតម្រូវឲ្យអនុវត្តតាមលក្ខខណ្ឌ ឬលក្ខខណ្ឌបន្ថែមនៃអាជ្ញាបណ្ណ ត្រូវគោរពតាមការណែនាំក្នុងរយៈពេលជាក់លាក់មួយដែលកំណត់ដោយប្រកាសរបស់ **ក.ប.ទ.** ឬសេចក្តីសម្រេចបន្ថែមរបស់ **ន.ទ.ក.** ។

## ផ្នែកទី ២

## នីតិវិធីនៃការស្នើសុំ និងការផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ

**មាត្រា ១៩.-**

ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ត្រូវគោរពតាមនីតិវិធីដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ក្រសួងព្រះបរមរាជវាំង

## ផ្នែកទី ៣
## ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ឬ
## ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការដាក់ប្រាតិភោគ និងការក្ស័យធន

**មាត្រា ២២.-**

ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការដាក់ប្រាតិភោគនូវសិទ្ធិដែលកំណត់ក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ដូចមានចែងក្នុងជំពូកទី ៤ នៃច្បាប់នេះត្រូវគោរពតាមច្បាប់នេះ និងបទប្បញ្ញត្តិជាធរមាន ។

ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការដាក់ប្រាតិភោគនូវសិទ្ធិដែលកំណត់ក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ត្រូវគោរពតាមនីតិវិធីដូចគ្នាទៅនឹងការផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ និងនីតិវិធីដែលមានចែងក្នុងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ។

ក្នុងករណីប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ មានបំណងចង់បញ្ឈប់ប្រតិបត្តិការរបស់ខ្លួន ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍នោះត្រូវជូនព័ត៌មានជាលាយលក្ខណ៍អក្សរ ទៅ **ន.ទ.ក.** យ៉ាងតិច ៣០(សាមសិប)ថ្ងៃ មុនថ្ងៃបញ្ឈប់ប្រតិបត្តិការដោយបញ្ជាក់អំពីមូលហេតុនៃការបញ្ឈប់ប្រតិបត្តិការ និងចុះហត្ថលេខាដោយប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ឬមេធាវីតំណាងផ្ទាល់របស់ខ្លួន ។

**មាត្រា ២៣.-**

ក្នុងករណីពិនិត្យឃើញថា ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍អាចជាអសាធនីយ ឬមានបញ្ហាផ្នែកហិរញ្ញវត្ថុ ស្របតាមការវាយតម្លៃរបស់សវនករឯករាជ្យ **ន.ទ.ក.** មានសិទ្ធិស្នើសុំទៅតុលាការ បន្ទាប់ពីបានទទួលការយល់ព្រមពី **ក.ប.ទ.** ដើម្បីប្រកាសបើកសំណុំរឿងក្ស័យធន និងតែងតាំងអភិបាលបណ្តោះអាសន្ន ស្របតាមបទប្បញ្ញត្តិស្តីពីក្ស័យធន ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ។ អភិបាលបណ្តោះអាសន្នដែលអាចត្រូវបានតែងតាំង ត្រូវបំពេញលក្ខណសម្បត្តិបន្ថែមស្របតាមប្រកាសរួមរបស់ **ក.ប.ទ.** និងក្រសួងយុត្តិធម៌ ។

## ជំពូកទី ៥
## ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញ

**មាត្រា ២៤.-**

ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញនិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទូរគមនាគមន៍ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ **ក.ប.ទ.** ផ្អែកតាមបទប្បញ្ញត្តិជាធរមាន ។

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

**មាត្រា ២៥.-**

ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញ អាចត្រូវបានប្រើប្រាស់ជាអាទិភាពនៅក្នុងលម្ហអាកាស លម្ហ-សាធារណៈ លើដី ក្រោមដី បាតទន្លេ និងបាតសមុទ្រ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន ។

ការរៀបចំប្លង់ស្ថាបនាប្រព័ន្ធគមនាគមន៍ មជ្ឈមណ្ឌលប្រជុំជន មជ្ឈមណ្ឌលលំនៅឋាន តំបន់ឧស្សាហកម្ម តំបន់សេដ្ឋកិច្ចពិសេស និងតំបន់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ត្រូវមានរួមបញ្ចូលនូវប្លង់ស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញទូរគមនាគមន៍ផងដែរ ។

**មាត្រា ២៦.-**

ទីតាំងសម្រាប់ប្រើប្រាស់សេវាទូរគមនាគមន៍សាធារណៈ អាចកំណត់ជាអាទិភាពនៅតាមស្ថានីយរថភ្លើង ស្ថានីយរថយន្តសាធារណៈ កំពង់ផែ អាកាសយានដ្ឋាន ច្រកទ្វារព្រំដែន មន្ទីរពេទ្យ និងទីកន្លែងសាធារណៈផ្សេងទៀត ស្របតាមការកំណត់ដោយច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

## ផ្នែកទី ១
## ការប្រើប្រាស់ដីធ្លីសម្រាប់ផ្តល់សេវាទូរគមនាគមន៍

**មាត្រា ២៧.-**

ការកំណត់ទីតាំងនៃដីធ្លី សំណង់ ឬអគារណាមួយសម្រាប់ដំឡើង សាងសង់ ឬប្រើប្រាស់ជាហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញនិងការប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិផ្សេងទៀត ។

**មាត្រា ២៨.-**

ប្រតិបត្តិករទូរគមនាគមន៍ ត្រូវពិភាក្សា និងស្នើសុំការអនុញ្ញាតពីក្រសួង ស្ថាប័ន និង/ឬអាជ្ញាធរមានសមត្ថកិច្ច មុននឹងដំឡើងខ្សែកាប្លិ៍និងឧបករណ៍ពាក់ព័ន្ធនៅលើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

ប្រតិបត្តិករទូរគមនាគមន៍ ត្រូវចរចា និងចុះកិច្ចព្រមព្រៀងជាមួយកម្មសិទ្ធិករ ស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត មុននឹងដំឡើងខ្សែកាប្លិ៍និងឧបករណ៍ពាក់ព័ន្ធនៅលើទ្រព្យសម្បត្តិឯកជន ។

**មាត្រា ២៩.-**

ប្រតិបត្តិករទូរគមនាគមន៍អាចកំណត់និងចូលក្នុងទីតាំងសម្រាប់សាងសង់ ដំឡើងនិង/ឬថែរក្សាហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញ ឬគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ដើម្បីសិក្សាលក្ខណៈបច្ចេកទេស បន្ទាប់ពីបានទទួលការអនុញ្ញាតពីកម្មសិទ្ធិករ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ៣០.-**

កម្មសិទ្ធិករដីឬអ្នកម្ចាស់ការត្រូវជូនដំណឹងនិងសុំកិច្ចសហការទៅក្រសួង ស្ថាប័ន និង/ឬអាជ្ញាធរមានសមត្ថកិច្ច និងប្រតិបត្តិករទូរគមនាគមន៍យ៉ាងតិចបំផុត ១៥(ដប់ប្រាំ)ថ្ងៃ មុននឹងបើកការដ្ឋានជីកលុងដីឯកជន ឬដីសាធារណៈ ដើម្បីជៀសវាងការបង្កព្យសនកម្មដល់ហេដ្ឋារចនាសម្ព័ន្ធ ឬបណ្តាញទូរគមនាគមន៍ ។

## ផ្នែកទី ២
## ការតភ្ជាប់ និងការប្រើប្រាស់បណ្តាញ និងហេដ្ឋារចនាសម្ព័ន្ធរួម

**មាត្រា ៣១.-**

ដើម្បីធានាប្រសិទ្ធភាពនៃការតភ្ជាប់ ការគ្រប់គ្រងបណ្តាញ និងការប្រកួតប្រជែងស្របច្បាប់និងស្មោះត្រង់នៅក្នុងវិស័យទូរគមនាគមន៍ ប្រតិបត្តិករទូរគមនាគមន៍ដូចដែលបានកំណត់ក្នុងមាត្រា ១៧ នៃច្បាប់នេះត្រូវ ៖

ក- តភ្ជាប់បណ្តាញទូរគមនាគមន៍របស់ខ្លួនជាមួយបណ្តាញទូរគមនាគមន៍ដទៃ

ខ- អនុញ្ញាតឲ្យប្រតិបត្តិករទូរគមនាគមន៍ដទៃ មានលទ្ធភាពប្រើប្រាស់សេវាទូរគមនាគមន៍របស់ខ្លួនដូចដែល មានចែងក្នុងចំណុច (ក) នៃមាត្រានេះ ផ្អែកតាមសំណើដែលមានខ្លឹមសារ និងលក្ខខណ្ឌសមរម្យ ដោយគ្មានការរើសអើង និងស្របតាមលក្ខខណ្ឌនៃស្តង់ដាបច្ចេកទេស គុណភាពនៃសេវា គោលការណ៍ តម្លាភាព និងថ្លៃសមរម្យ

គ- ធានាការប្រើប្រាស់សេវាទូរគមនាគមន៍ដល់ប្រតិបត្តិករទូរគមនាគមន៍ដទៃ ដោយស្របតាមបញ្ញត្តិ ដែលមានចែងក្នុងចំណុច (ខ) នៃមាត្រានេះ

ឃ- ធ្វើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ យោងតាមបទប្បញ្ញត្តិស្តីពីការតភ្ជាប់បណ្តាញរវាងប្រតិបត្តិករទូរគមនាគមន៍

ង- ដាក់សំណើស្តីពីការប្រើប្រាស់សេវាទូរគមនាគមន៍ ដូចដែលបានកំណត់ក្នុងចំណុច (ក) នៃមាត្រានេះ ទៅ **ន.ទ.ក.** ។ ក្នុងករណីដែលប្រតិបត្តិករទូរគមនាគមន៍ទាំងសងខាងពុំឯកភាពគ្នា **ន.ទ.ក.** មានសិទ្ធិសម្រេចចុងក្រោយអំពីខ្លឹមសារ និងលក្ខខណ្ឌទាំងឡាយណាដែលប្រតិបត្តិករទូរគមនាគមន៍ទាំងសងខាង ពុំឯកភាពគ្នា ផ្អែកតាមបទប្បញ្ញត្តិស្តីពីការកំណត់ខ្លឹមសារ និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងដែលបានកំណត់ដោយច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ច- ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ **ន.ទ.ក.** អំពីការព្រមព្រៀងក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីមានការឯកភាពរវាងប្រតិបត្តិករទូរគមនាគមន៍ដែលមានការពាក់ព័ន្ធ និង

ឆ- ផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរតាមការស្នើសុំរបស់ **ន.ទ.ក.** ទាក់ទងនឹងចំណុច (ក) នៃមាត្រានេះ និងព័ត៌មានផ្សេងទៀតដែល **ន.ទ.ក.** យល់ឃើញថាចាំបាច់ ។

## មាត្រា ៣២.-

ដើម្បីធានាប្រសិទ្ធភាពនៃការតភ្ជាប់ ការគ្រប់គ្រងបណ្តាញ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការប្រកួតប្រជែងស្របច្បាប់ និងស្មោះត្រង់នៅក្នុងវិស័យទូរគមនាគមន៍ ប្រតិបត្តិករទូរគមនាគមន៍ដូចដែលបានកំណត់ក្នុងចំណុច (ក) នៃមាត្រា ១៧ នៃច្បាប់នេះត្រូវ ៖

ក- ផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញនិងសេវាហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទូរគមនាគមន៍ទៅប្រតិបត្តិករទូរគមនាគមន៍ដទៃទៀតដូចដែលបានកំណត់ក្នុងមាត្រា ១៧ នៃច្បាប់នេះ

ខ- ផ្តល់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញ ឬគ្រឿងសម្ភារៈបរិក្ខាររួមគ្នាជាមួយប្រតិបត្តិករទូរគមនាគមន៍ដទៃទៀត ដូចដែលបានកំណត់ក្នុងមាត្រា ១៧ នៃច្បាប់នេះ និង

គ- គោរពតាមបទប្បញ្ញត្តិ ដូចដែលមានចែងក្នុងមាត្រា ៣១ នៃច្បាប់នេះ ។

## មាត្រា ៣៣.-

**ន.ទ.ក.** ត្រូវបង្កើតនិងរក្សាបញ្ជីកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ និងកិច្ចព្រមព្រៀងគោលដែលប្រតិបត្តិករ ទូរគមនាគមន៍បានធ្វើស្របតាមទម្រង់បែបបទត្រឹមត្រូវ កំណត់ដោយច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

## មាត្រា ៣៤.-

**ក.ប.ទ.** ត្រូវដឹកនាំ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និង/ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធលើការរៀបចំប្លង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបណ្តាញរួមលើវិស័យទូរគមនាគមន៍ ដោយត្រូវបន្សុីជាមួយនឹងប្លង់ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ការផ្គត់ផ្គង់ថាមពល ការបំភ្លឺសាធារណៈ ការផ្គត់ផ្គង់ទឹកស្អាត ការបង្ហូរកាកសំណល់រឹងនិងរាវ និងប្លង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ។

**ក.ប.ទ.** ត្រូវផ្សព្វផ្សាយបទប្បញ្ញត្តិស្តីពីការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបណ្តាញរួមពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ទៅប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ។

## មាត្រា ៣៥.-

ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញរួមពាក់ព័ន្ធវិស័យគមនាគមន៍និងទូរគមនាគមន៍ ការផ្គត់ផ្គង់ថាមពល ការបំភ្លឺសាធារណៈ ការផ្គត់ផ្គង់ទឹកស្អាត ការបង្ហូរកាកសំណល់រឹងនិងរាវ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ត្រូវធ្វើឡើងប្រកបដោយប្រសិទ្ធភាព សំដៅការពារសោភណភាព បរិស្ថាន និងសុខុមាលភាពសាធារណៈ និងត្រូវស្របតាមប្លង់នគរូបនីយកម្ម ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញរួមពាក់ព័ន្ធវិស័យគមនាគមន៍ និងទូរគមនាគមន៍ ការផ្គត់ផ្គង់ថាមពល ការបំភ្លឺសាធារណៈ ការផ្គត់ផ្គង់ទឹកស្អាត ការបង្ហូរកាកសំណល់រឹង និងរាវ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣៦.-**

**ន.ទ.ក.** ត្រូវរៀបចំលក្ខខណ្ឌបន្ថែមស្តីពីការតភ្ជាប់ និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញជាតិ និងអន្តរជាតិ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធរួម ស្របតាមការកំណត់របស់ច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

## ផ្នែកទី ៣
## ស្តង់ដា គុណភាពនៃសេវា និងគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍

**មាត្រា ៣៧.-**

**ក.ប.ទ.** ត្រូវរៀបចំលក្ខខណ្ឌកំណត់អំពីស្តង់ដាទូរគមនាគមន៍ជាតិ និងបទដ្ឋានស្តីពីឯកការូបនីយកម្មរវាងស្តង់ដាជាតិនិងអន្តរជាតិដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធបញ្ជូនស៊ីញ៉ាល់ បណ្តាញដែលអាចបំពេញ ប្រតិបត្តិការរវាងគ្នាទៅវិញទៅមក និងគុណភាពនៃសេវា ព្រមទាំងគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ។ ប្រភេទនៃគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ដែលស្ថិតនៅក្រោមស្តង់ដាទូរគមនាគមន៍ជាតិជាអាទិ៍ គ្រឿងសម្ភារៈបរិក្ខារហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញ គ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍ និងគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍សម្រាប់អ្នកប្រើប្រាស់នឹងត្រូវកំណត់ក្នុងបទប្បញ្ញត្តិដោយឡែក ។

**ន.ទ.ក.**ត្រូវផ្សព្វផ្សាយជាសាធារណៈនូវស្តង់ដាទាំងអស់នៃគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ។

**មាត្រា ៣៨.-**

**ក.ប.ទ.** ត្រូវរៀបចំលក្ខខណ្ឌកំណត់អំពីស្តង់ដានៃការផ្តល់សេវាទូរគមនាគមន៍ប្រកបដោយគុណភាព ។

## ជំពូកទី ៦
## កាតព្វកិច្ចសេវាសកល

**មាត្រា ៣៩.-**

កម្មវិធីកាតព្វកិច្ចសេវាសកលមានគោលបំណងដូចតទៅ ៖

ក- លើកទឹកចិត្តការសាងសង់ និងការអភិវឌ្ឍបណ្តាញទូរគមនាគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ខ- ជំរុញការផ្តល់សេវាទូរគមនាគមន៍មូលដ្ឋាន សេវាទូរគមនាគមន៍តម្លៃបន្ថែម និងសេវាគ្រាអាសន្នឲ្យបានទូលំទូលាយដល់តំបន់ជនបទនិងដាច់ស្រយាល និង

គ- ជំរុញការកាត់បន្ថយគម្លាតឌីជីថល ដើម្បីចូលរួមអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ។

**មាត្រា ៤០.-**

យន្តការសម្រាប់អនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកល ត្រូវបានបង្កើតឡើងដោយផ្អែកលើគោលការណ៍តម្លាភាព អព្យាក្រឹត និងមិនរើសអើង ។ យន្តការនេះត្រូវកំណត់អំពីកាតព្វកិច្ចសេវាសកលដែលរួមមាន ៖

ក- ការបង្កើត និងការគ្រប់គ្រងមូលនិធិកាតព្វកិច្ចសេវាសកល

ខ- កាតព្វកិច្ច ឬលក្ខខណ្ឌដែលមានចែងក្នុងអាជ្ញាបណ្ណសម្រាប់ប្រតិបត្តិករទូរគមនាគមន៍ដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់នេះ

គ- លក្ខខណ្ឌសម្រាប់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដទៃទៀតដែលអាចប្រើប្រាស់មូលនិធិកាតព្វកិច្ចសេវាសកល

ឃ- នីតិវិធីនៃការប្រើប្រាស់មូលនិធិកាតព្វកិច្ចសេវាសកល និង

ង- ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកាតព្វកិច្ចសេវាសកល ។

យន្តការសម្រាប់អនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកល ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤១.-**

**ន.ប.ទ.** ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការបង្កើត គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃការប្រើប្រាស់មូលនិធិកាតព្វកិច្ចសេវាសកលស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

**មាត្រា ៤២.-**

មូលនិធិកាតព្វកិច្ចសេវាសកលអាចមានប្រភពមកពីថវិកាក្នុង ឬក្រៅប្រទេស ។

ប្រតិបត្តិករទូរគមនាគមន៍ត្រូវចូលរួមលើកកម្ពស់កម្មវិធីកាតព្វកិច្ចសេវាសកល ដោយត្រូវចូលរួមវិភាគទានរៀងរាល់ឆ្នាំចំនួន ២ (ពីរ) ភាគរយ នៃចំណូលដុល ទៅក្នុងមូលនិធិកាតព្វកិច្ចសេវាសកល ។

## ជំពូកទី ៧
## ការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ

**មាត្រា ៤៣.-**

យន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍ ត្រូវកំណត់អំពី ៖

ក- ការបង្កើតនិងការគ្រប់គ្រងមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ

ខ- កាតព្វកិច្ច ឬលក្ខខណ្ឌដែលមានចែងក្នុងអាជ្ញាបណ្ណសម្រាប់ប្រតិបត្តិករទូរគមនាគមន៍ដូចដែលមានចែងក្នុងមាត្រា ១៧ នៃច្បាប់នេះ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

គ- លក្ខខណ្ឌសម្រាប់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដទៃទៀតដែលអាចប្រើប្រាស់មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ

ឃ- នីតិវិធីនៃការប្រើប្រាស់មូលនិធិនៃការកសាងសមត្ថភាពនិងការស្រាវជ្រាវ និងការអភិវឌ្ឍ និង

ង- ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ ។

យន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤៤.-**

**ក.ប.ទ.** ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការបង្កើត គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃការប្រើប្រាស់ មូលនិធិនៃការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍ ស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

**មាត្រា ៤៥.-**

ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ត្រូវមានផែនការផ្ទាល់ខ្លួនដើម្បីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ ស្របតាមការវិវត្តនៃបច្ចេកវិទ្យាថ្នាក់តំបន់ និងសកលលោក ។

**មាត្រា ៤៦.-**

មូលនិធិនៃការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍ អាចមានប្រភពមកពីថវិកាក្នុង ឬក្រៅប្រទេស ។

ប្រតិបត្តិករទូរគមនាគមន៍ ត្រូវចូលរួមលើកកម្ពស់ការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ ដោយត្រូវបង់វិភាគទានរៀងរាល់ឆ្នាំ ចំនួន ១(មួយ) ភាគរយ នៃចំណូលដុល ទៅក្នុងមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ ។

## ជំពូកទី ៨
## ការគ្រប់គ្រងធនធានវិសាលគមន៍ប្រេកង់វិទ្យុ

**មាត្រា ៤៧.-**

វិសាលគមន៍ប្រេកង់វិទ្យុ គឺជាធនធានរបស់រដ្ឋដែលពុំត្រូវធ្វើជាកម្មវត្ថុនៃការលក់ទិញ ប៉ុន្តែអាចធ្វើជាកម្មវត្ថុនៃការជួល ឬការផ្តល់សិទ្ធិប្រើប្រាស់តាមរយៈការផ្តល់អាជ្ញាបណ្ណ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

វិសាលគមន៍ប្រេកង់វិទ្យុត្រូវស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ **ក.ប.ទ.**។ ការរៀបចំការគ្រប់គ្រង និងការបែងចែកវិសាលគមន៍ប្រេកង់វិទ្យុ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤៨.-**

**គ.ម.ទ.** ត្រូវរៀបចំផែនការជាតិវិសាលគមន៍ប្រេកង់វិទ្យុ ។ ផែនការជាតិវិសាលគមន៍ប្រេកង់វិទ្យុត្រូវកំណត់នូវចំណុចមួយចំនួន ជាអាទិ៍ ៖

ក- ការរៀបចំតារាងបែងចែកប្រេកង់វិទ្យុ

ខ- ការប្រើប្រាស់បន្ទារប្រេកង់វិទ្យុ និងវិធានការទប់ស្កាត់ការឆ្លងរំខានការទទួលស៊ីញ៉ាល់ជាដើម

គ- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការប្រើប្រាស់បន្ទារប្រេកង់វិទ្យុ ។

**ន.ទ.ក.** ត្រូវចេញបទប្បញ្ញត្តិបន្ថែមពាក់ព័ន្ធនឹងការទូទាត់ប្រាក់កម្រៃពីអ្នកទទួលអាជ្ញាបណ្ណចំពោះការប្រើប្រាស់ ប្រេកង់វិទ្យុ ស្របតាមប្រកាសរបស់ **គ.ម.ទ.** ។

បុគ្គលទាំងអស់ ត្រូវគោរពតាមផែនការជាតិវិសាលគមន៍ប្រេកង់វិទ្យុ ។

## ជំពូកទី ៩

## ការកំណត់ប្លង់លេខទូរគមនាគមន៍ជាតិ និងអាសយដ្ឋានអេឡិកត្រូនិក

**មាត្រា ៤៩.-**

**គ.ម.ទ.** មានសមត្ថកិច្ចគ្រប់គ្រងប្លង់លេខទូរគមនាគមន៍ជាតិនិងអាសយដ្ឋានអេឡិកត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ការគ្រប់គ្រង និងការកំណត់ប្លង់លេខទូរគមនាគមន៍ជាតិ ការបែងចែកក្បាលលេខទូរគមនាគមន៍ និងការផ្តល់លេខទូរគមនាគមន៍ រួមទាំងលេខទូរគមនាគមន៍សម្រាប់អង្គភាពសង្គ្រោះបន្ទាន់ ព្រមទាំងការគ្រប់គ្រងអាសយដ្ឋានអេឡិកត្រូនិក ត្រូវធ្វើឡើងស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

**មាត្រា ៥០.-**

**ន.ទ.ក.** ត្រូវណែនាំនិងផ្សព្វផ្សាយប្លង់លេខទូរគមនាគមន៍ជាតិ និងអាសយដ្ឋានអេឡិកត្រូនិកទាក់ទងនឹងចំណុចមួយចំនួនដូចខាងក្រោមនេះ ចំពោះប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ៖

ក- ការបែងចែកក្បាលលេខទូរគមនាគមន៍ លេខទូរគមនាគមន៍ និងអាសយដ្ឋានអេឡិកត្រូនិក

ខ- ការផ្ទេរ ការប្រគល់មកវិញ ឬការដកហូតក្បាលលេខទូរគមនាគមន៍ និងលេខទូរគមនាគមន៍ព្រមទាំងអាសយដ្ឋានអេឡិកត្រូនិក

គ- កម្រៃនៃការប្រើប្រាស់ក្បាលលេខទូរគមនាគមន៍ និងលេខទូរគមនាគមន៍ ព្រមទាំងអាសយដ្ឋានអេឡិកត្រូនិក និង

ឃ- ចំណុចផ្សេងទៀតដែលត្រូវកំណត់បន្ថែមដោយ **គ.ម.ទ.** ។

**មាត្រា ៥១.-**

**ន.ទ.ក.** ត្រូវណែនាំនិងផ្សព្វផ្សាយលេខទូរគមនាគមន៍ និងអាសយដ្ឋានអេឡិកត្រូនិកទាក់ទងនឹងចំណុចមួយចំនួនដូចខាងក្រោមនេះដល់អ្នកប្រើប្រាស់ ៖

ក- ការប្រើប្រាស់ រក្សាទុក ផ្លាស់ប្តូរ ឬផ្ទេរលេខទូរគមនាគមន៍

ខ- ការប្រើប្រាស់ រក្សាទុក ផ្លាស់ប្តូរ ឬផ្ទេរអាសយដ្ឋានអេឡិកត្រូនិក និង

គ- ចំណុចផ្សេងទៀតដែលត្រូវកំណត់បន្ថែមដោយ **ក.ប.ទ.** ។

**មាត្រា ៥២.-**

**ក.ប.ទ.** ត្រូវកំណត់អំពីការបែងចែក និងអនុញ្ញាតឲ្យផ្ទេរក្បាលលេខទូរគមនាគមន៍ លេខទូរគមនាគមន៍ និងអាសយដ្ឋានអេឡិកត្រូនិករវាងប្រតិបត្តិករទូរគមនាគមន៍ ដូចដែលបានកំណត់ក្នុងមាត្រា ១៧ នៃច្បាប់នេះ ។ ការបែងចែកនិងការអនុញ្ញាតនេះ ត្រូវគោរពគោលការណ៍តម្លាភាព និងពុំរើសអើង។

**មាត្រា ៥៣.-**

**ក.ប.ទ.** ត្រូវបង្កើតនិងរក្សាប្លង់លេខទូរគមនាគមន៍ជាតិ ក្បាលលេខទូរគមនាគមន៍ និងអាសយដ្ឋានអេឡិកត្រូនិក និងបញ្ជីប្រតិបត្តិករទូរគមនាគមន៍ដូចដែលបានកំណត់ក្នុងមាត្រា ១៧ នៃច្បាប់នេះ។ ទម្រង់បែបបទនេះត្រូវកំណត់ ដោយប្រកាសរបស់ **ក.ប.ទ.** ។

**ន.ទ.ក.** ត្រូវផ្សព្វផ្សាយប្លង់លេខទូរគមនាគមន៍ជាតិ និងបញ្ជីដូចបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ជាសាធារណៈ ។

## ជំពូកទី ១០
## ថ្លៃសេវាទូរគមនាគមន៍ និងការប្រកួតប្រជែង

**មាត្រា ៥៤.-**

**ក.ប.ទ.** មានសមត្ថកិច្ចកំណត់វិធានស្តីពីថ្លៃសេវាទូរគមនាគមន៍ ដើម្បីធានាការប្រកួតប្រជែងស្របច្បាប់និងស្មោះត្រង់ ។

**មាត្រា ៥៥.-**

**ក.ប.ទ.** ត្រូវរៀបចំប្រកាសដើម្បីកំណត់វិធានស្តីពីថ្លៃសេវាទូរគមនាគមន៍ ដោយអនុលោមតាមចំណុចមួយ ចំនួនដូចតទៅ ៖

ក- គោលនយោបាយនិងបទប្បញ្ញត្តិនៃការប្រកួតប្រជែង ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀត

ខ- ថ្លៃដើម របាយការណ៍ហិរញ្ញវត្ថុរបស់សវនករឯករាជ្យដែលទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងព័ត៌មានមិនមែនហិរញ្ញវត្ថុដែលត្រូវប្រគល់ដោយប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និង

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

គ- ចំណុចផ្សេងទៀតដែលត្រូវកំណត់ដោយច្បាប់នេះ និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៥៦.-**

**ន.ទ.ក.** មានសមត្ថកិច្ចត្រួតពិនិត្យនិងតាមដានថ្លៃសេវាទូរគមនាគមន៍ ។ **ន.ទ.ក.** ត្រូវផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តស្តីពីថ្លៃសេវាទូរគមនាគមន៍ដែលមានខ្លឹមសារមួយចំនួនដូចខាងក្រោម ៖

ក- ថ្លៃសេវាទូរគមនាគមន៍រវាងអ្នកទទួលអាជ្ញាបណ្ណ

ខ- ថ្លៃសេវាទូរគមនាគមន៍រវាងអ្នកទទួលអាជ្ញាបណ្ណនិងអ្នកប្រើប្រាស់

គ- រូបមន្តគណនាថ្លៃដើមនៃសេវាទូរគមនាគមន៍ និងទម្រង់បែបបទនៃការប្រគល់ថ្លៃដើមរបស់សេវានេះ និង

ឃ- ទម្រង់បែបបទនៃការបញ្ចុះថ្លៃសេវាទូរគមនាគមន៍ដែលត្រូវគោរពគោលការណ៍តម្លាភាព ស្មើភាព និងសមរម្យ ។

**មាត្រា ៥៧.-**

**ក.ប.ទ.** មានសិទ្ធិស៊ើបអង្កេតលើលិខិតបទដ្ឋានគតិយុត្តស្តីពីថ្លៃសេវាទូរគមនាគមន៍ ។

**មាត្រា ៥៨.-**

ប្រតិបត្តិករទូរគមនាគមន៍មិនត្រូវកំណត់ថ្លៃសេវាទូរគមនាគមន៍ទាបជាងថ្លៃដើម ដូចមានចែងក្នុងចំណុច (គ) មាត្រា ៥៦ នៃច្បាប់នេះទេ ។

ប្រតិបត្តិករទូរគមនាគមន៍ ត្រូវផ្តល់សេវាគ្រាអាសន្នដោយពុំយកថ្លៃ ។

**ន.ទ.ក.** ត្រូវចាត់វិធានការបន្ថែមសមស្របដូចមានចែងក្នុងច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ដើម្បីធានានូវការប្រកួតប្រជែងស្របច្បាប់និងស្មោះត្រង់ ។

**មាត្រា ៥៩.-**

ប្រតិបត្តិករទូរគមនាគមន៍ត្រូវ ៖

ក- ផ្សព្វផ្សាយជាសាធារណៈនូវតារាងថ្លៃសេវាទូរគមនាគមន៍ ស្របតាមការកំណត់នៅក្នុងចំណុច (ក) នៃ មាត្រា៥៦នៃច្បាប់នេះ និង

ខ- ផ្សព្វផ្សាយជាសាធារណៈនូវថ្លៃសេវាទូរគមនាគមន៍ រួមទាំងការផ្លាស់ប្តូរ ឬការកែប្រែថ្លៃសេវានេះ ស្រប តាមការកំណត់នៅក្នុងចំណុច (ខ) នៃមាត្រា ៥៦ នៃច្បាប់នេះ ។

**មាត្រា ៦០.-**

**ន.ទ.ក.** មានសមត្ថកិច្ចត្រួតពិនិត្យ តាមដាន និងវាយតម្លៃសកម្មភាពប្រកួតប្រជែងស្របច្បាប់និងស្មោះត្រង់ក្នុងទីផ្សារទូរគមនាគមន៍ ហើយត្រូវរាយការណ៍ជូន **ក.ប.ទ.** ដើម្បីរៀបចំបទប្បញ្ញត្តិ

បន្ថែម ។ ដើម្បីជានាការប្រកួត ប្រជែងស្របច្បាប់ និងស្មោះត្រង់ **ន.ទ.ក.** ត្រូវអនុវត្តលក្ខខណ្ឌមួយចំនួនជាអាទិ៍ ៖

ក- ជួយអ្នកប្រើប្រាស់ឲ្យទទួលសេវាក្នុងថ្លៃសមរម្យ មានគុណភាពល្អ និងមានជម្រើសច្រើន

ខ- គាំទ្រឲ្យមានការប្រាស្រ័យទាក់ទងគ្នារវាងអ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណដោយស្មើភាព និងតម្លាភាព

គ- ការពារអ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ មិនឲ្យខូចផលប្រយោជន៍ដោយសារការប្រកួតប្រជែងមិនស្របច្បាប់និងមិនស្មោះត្រង់ និង

ឃ- លក្ខខណ្ឌនៃការប្រកួតប្រជែងផ្សេងទៀតដែលត្រូវកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

## មាត្រា ៦១.-

គ្រប់ប្រតិបត្តិការទូរគមនាគមន៍ ត្រូវធ្វើឡើងដោយគោរពគោលការណ៍ប្រកួតប្រជែងដោយស្មោះត្រង់ សេរី ស្មើភាព និងប្រកបដោយប្រសិទ្ធភាព ។

ត្រូវបានហាមឃាត់សកម្មភាពដែលត្រូវបានប្រព្រឹត្តផ្ទុយនឹងគោលការណ៍ប្រកួតប្រជែងដោយស្មោះត្រង់ សេរី ស្មើភាព និងប្រកបដោយប្រសិទ្ធភាព ៖

ក- រាល់ការប្រមូលផ្តុំ ការព្រមព្រៀង ការមូលមតិ ដោយតុណ្ហីភាព ឬជាលាយលក្ខណ៍អក្សរលើការបំពេញ ប្រតិបត្តិការដែលមានចរិតរាំង រឹតបន្តឹង បង្ខូចដល់ការប្រកួតប្រជែងលើទីផ្សារ ប្រសិនបើកិច្ចទាំងនោះ ត្រូវបានធ្វើឡើងដើម្បី ៖

១) រារាំង ឬកម្រិតសិទ្ធិលើការជ្រៀតចូលទីផ្សារទូរគមនាគមន៍ដោយប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍មួយ ឬច្រើន

២) បង្កជាឧបសគ្គដល់ការកំណត់ថ្លៃដោយសេរីដែលជាកត្តានាំឲ្យមានការឡើង ឬចុះថ្លៃដែលបង្កប់ចរិត លក្ខណៈនិម្មិត

៣) កម្រិតសិទ្ធិមួយផ្នែក ឬទាំងស្រុងលើការគ្រប់គ្រងប្រតិបត្តិការទូរគមនាគមន៍ ការវិនិយោគ ឬការអភិវឌ្ឍ បច្ចេកវិទ្យា ឬ

៤) បែងចែកទីផ្សារទូរគមនាគមន៍ ឬប្រភពផ្គត់ផ្គង់ ។

ខ- រាល់ការរំលោភឧត្តមភាពទីផ្សារដែលមានចរិតលក្ខណៈដូចបានកំណត់ក្នុងចំណុច (ក) ដែលនាំឲ្យ ប៉ះពាល់ដល់ទីផ្សារ ឬផ្នែកមួយនៃទីផ្សារ ដោយប្រតិបត្តិករ ក្រុមប្រតិបត្តិករ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ដែលអាចនាំឲ្យប៉ះពាល់ដល់ដំណើរការ ឬដល់ប្រព័ន្ធនៃការប្រកួតប្រជែង។ ការរំលោភនេះ អាចជាការបដិសេធលក់ ការលក់ដោយមានលក្ខខណ្ឌ ការលក់ដោយមានភាពរើសអើង ឬការលុបចោល កិច្ចសន្យាដោយហេតុថាភាគីម្ខាងទៀតមិនព្រមទទួលយកលក្ខខណ្ឌពាណិជ្ជកម្មដោយគ្មានហេតុផល ។

គ- រាល់ការរំលោភលើអនិស្សរភាពរបស់ប្រតិបត្តិករ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ណាមួយ ដែលមានចរិតលក្ខណៈ ដូចបានកំណត់ក្នុងចំណុច (ក) ដែលអាចនាំឲ្យប៉ះពាល់ដល់ដំណើរការ ឬដល់ប្រព័ន្ធនៃការប្រកួតប្រជែង ។ ការរំលោភនេះអាចជាការបដិសេធលក់ ការលក់ដោយមានលក្ខខណ្ឌ ឬការលក់ដោយមានភាពរើសអើង ។

ឃ- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នារវាងប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ដែលបង្កប់នូវចរិតលក្ខណៈ ដូចមានចែងក្នុងចំណុច (ក) ។

## មាត្រា ៦២.-

សកម្មភាពខាងក្រោមដែលបង្កប់នូវចរិតលក្ខណៈណាមួយ ដូចមានចែងក្នុងមាត្រា ៦១ កថាខណ្ឌទី ២ (ក) នៃច្បាប់នេះ ក៏ត្រូវបានចាត់ទុកជាអំពើរំលោភលើគោលការណ៍ប្រកួតប្រជែងដោយស្មោះត្រង់ សេរី ស្មើភាព និងប្រកប ដោយប្រសិទ្ធភាព ជាអាទិ៍ ៖

ក- ការព្រមព្រៀងគ្នាផ្តល់សិទ្ធិផ្តាច់មុខចំពោះប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍មួយ ឬច្រើន ឬការបំពេញប្រតិបត្តិការទាំងឡាយណាដែលឈានទៅរកការទទួលសិទ្ធិផ្តាច់មុខ

ខ- ការផ្តល់ឧបត្ថម្ភធនតាមគ្រប់រូបភាពនិងទម្រង់ទាំងអស់ លើកលែងតែមានការអនុញ្ញាតដោយបទប្បញ្ញត្តិផ្សេងទៀត

គ- ការប្រើប្រាស់ព័ត៌មានសម្ងាត់ផ្នែកពាណិជ្ជកម្ម បច្ចេកទេស ហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុរបស់ប្រតិបត្តិករ ទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍មួយ ឬច្រើន ដោយប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍មួយ ឬច្រើនផ្សេងទៀត ឬដោយបុគ្គលទាំងឡាយណាដែលមានប្រយោជន៍

ឃ- ការមិនផ្តល់នូវព័ត៌មានបច្ចេកទេសពាក់ព័ន្ធគ្រឿងសម្ភារៈបរិក្ខារសំខាន់ៗ និងព័ត៌មានផ្នែកពាណិជ្ជកម្ម ដោយប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ជូនទៅប្រតិបត្តិករទូរគមនាគមន៍ដទៃ ឬបុគ្គលទាំងឡាយណាដែលមានប្រយោជន៍

ង- ការរើសអើង ឬបដិសេធពុំផ្តល់សេវាដោយប្រតិបត្តិករទូរគមនាគមន៍ ដល់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍មួយ ឬច្រើន ឬដៃគូពាណិជ្ជកម្មផ្សេងៗ ឬអ្នកប្រើប្រាស់ដោយ ពុំរាប់បញ្ចូលនូវគម្លាត ដែលបណ្តាលមកពីបរិមាណនៃការផ្តល់សេវា ទំហំនៃបណ្តាញ ទីកន្លែងផ្តល់សេវារយៈពេលនៃការផ្តល់សេវា និងជាតុផ្សំផ្សេងទៀតកំណត់ដោយ **ន.ទ.ក.**

ច- ការផ្តល់ជាកញ្ចប់នូវសេវា និង/ឬផលិតផល ឬការលក់ដោយមានលក្ខខណ្ឌដែលមានចរិតលក្ខណៈប្រកួតប្រជែងមិនស្របច្បាប់ ផ្អែកតាមការកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន និង

ឆ- សកម្មភាពទាំងឡាយណា ដែលបានកំណត់ក្នុងបទប្បញ្ញត្តិស្តីពីការប្រកួតប្រជែង និងបទប្បញ្ញត្តិផ្សេងទៀត ។

**មាត្រា ៦៣.-**

**ន.ទ.ក.** ត្រូវផ្តល់ការយល់ព្រមជាមុនចំពោះការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការទិញយកក្រុមហ៊ុន ឬភាគហ៊ុន ឬការដាក់ប្រាតិភោគ បន្ទាប់ពីមានការស្នើសុំពីប្រតិបត្តិករទូរគមនាគមន៍ និងស្របតាមការកំណត់របស់ **ក.ប.ទ.** ផ្អែកតាមលក្ខខណ្ឌដូចបានកំណត់ក្នុងច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការទិញយកក្រុមហ៊ុនឬភាគហ៊ុន ឬការដាក់ប្រាតិភោគ ពុំមានសុពលភាពនោះទេ ក្នុងករណីដែលពុំមានការយល់ព្រមជាមុនពី **ន.ទ.ក.** ។

ផ្អែកតាមការស្នើសុំរបស់ **ន.ទ.ក.** ចំពោះករណីប្រតិបត្តិករទូរគមនាគមន៍មួយ ឬច្រើន ជួបប្រទះនូវវិបត្តិហិរញ្ញវត្ថុ **ក.ប.ទ.** មានសិទ្ធិសម្រេចលើលទ្ធភាពនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការលក់ក្រុមហ៊ុន ឬភាគហ៊ុន ។

## ជំពូកទី ១១
## សិទ្ធិរបស់ប្រតិបត្តិករទូរគមនាគមន៍ និងអ្នកប្រើប្រាស់

**មាត្រា ៦៤.-**

ប្រតិបត្តិករទូរគមនាគមន៍មានសិទ្ធិមូលដ្ឋានដូចខាងក្រោម ៖

ក- សិទ្ធិប្រកួតប្រជែងស្របច្បាប់ និងស្មោះត្រង់ផ្អែកតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

ខ- សិទ្ធិចូលរួមពិគ្រោះយោបល់ពាក់ព័ន្ធនឹងការរៀបចំគោលនយោបាយ និងបទប្បញ្ញត្តិទាក់ទងនឹងការអភិវឌ្ឍន៍វិស័យទូរគមនាគមន៍

គ- សិទ្ធិក្នុងការកំណត់ថ្លៃ និងការទូទាត់ថ្លៃសេវាទូរគមនាគមន៍ពីអ្នកប្រើប្រាស់ផ្អែកតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

ឃ- សិទ្ធិពាក់ព័ន្ធនឹងការកំណត់វិធានការនៃការផ្តាច់ចេញ និង/ឬការផ្អាកសេវា ក្នុងករណីពុំបានទូទាត់វិក្កយបត្រ ឬបំពានកាតព្វកិច្ចនៃកិច្ចសន្យាផ្អែកតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

ង- សិទ្ធិពាក់ព័ន្ធនឹងការទទួលសំណងចំពោះព្យសនកម្ម បង្កដោយអ្នកប្រើប្រាស់ដែលបំពានកាតព្វកិច្ចនៃកិច្ចសន្យា

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ច- សិទ្ធិបង្កើតសមាគម និងសហការរៀបចំក្រមសីលធម៌វិជ្ជាជីវៈ ផ្អែកតាមរដ្ឋធម្មនុញ្ញ និងបទប្បញ្ញត្តិផ្សេងទៀត និង

ឆ- សិទ្ធិទាំងឡាយដែលត្រូវកំណត់ដោយច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

**មាត្រា ៦៥.-**

អ្នកប្រើប្រាស់ មានសិទ្ធិមូលដ្ឋានដូចខាងក្រោម ៖

ក- សិទ្ធិទទួលសេវាទូរគមនាគមន៍ប្រកបដោយគុណភាព និងព័ត៌មានពាក់ព័ន្ធនឹងសេវានេះ

ខ- សិទ្ធិទទួលការការពារព័ត៌មានឯកជន សន្តិសុខ និងសុវត្ថិភាពនៃការប្រើប្រាស់សេវាទូរគមនាគមន៍ លើកលែងមានច្បាប់ពិសេសចែងផ្សេងពីនេះ

គ- សិទ្ធិចូលរួមពិគ្រោះយោបល់ពាក់ព័ន្ធនឹងការរៀបចំគោលនយោបាយ និងបទប្បញ្ញត្តិទាក់ទងនឹងការអភិវឌ្ឍ វិស័យទូរគមនាគមន៍

ឃ- សិទ្ធិសាកសួរព័ត៌មានចំពោះ **ន.ទ.ក.** អំពីបញ្ហាពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍

ង- សិទ្ធិទទួលនូវយន្តការដោះស្រាយវិវាទរវាងអ្នកប្រើប្រាស់ និងប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ដែលត្រូវបានកំណត់ដោយច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

ច- សិទ្ធិពាក់ព័ន្ធនឹងការទទួលសំណងចំពោះព្យសនកម្ម ដែលបង្កដោយការបំពានកាតព្វកិច្ចនៃកិច្ចសន្យារបស់ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍

ឆ- សិទ្ធិបង្កើតសមាគមអ្នកប្រើប្រាស់សេវាទូរគមនាគមន៍ផ្អែកតាមរដ្ឋធម្មនុញ្ញ និងបទប្បញ្ញត្តិផ្សេងទៀត និង

ជ- សិទ្ធិទាំងឡាយដែលត្រូវកំណត់ដោយបទប្បញ្ញត្តិផ្សេងទៀត ។

**មាត្រា ៦៦.-**

ការបង្កើត ការដំឡើង ការប្រើប្រាស់ ឬការកែប្រែហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញទូរគមនាគមន៍ ឬការបង្កើត ការដំឡើង ការប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារវិស័យទូរគមនាគមន៍ ដែលបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងនាំឲ្យអន្តរាយដល់សន្តិសុខជាតិ ត្រូវហាមឃាត់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១២
# ការដោះស្រាយវិវាទ

## មាត្រា ៦៧.-

ក្រៅពីករណីបទល្មើសព្រហ្មទណ្ឌ គ្រប់វិវាទដែលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ជាអាទិ៍ វិវាទរវាងប្រតិបត្តិករទូរគមនាគមន៍ និងប្រតិបត្តិករទូរគមនាគមន៍ និងរវាងប្រតិបត្តិករទូរគមនាគមន៍ និងអ្នកប្រើប្រាស់ភាគីវិវាទត្រូវដាក់សំណុំរឿងទៅ **ន.ទ.ក.** ដើម្បីធ្វើការផ្សះផ្សា ។

នីតិវិធីនៃការផ្សះផ្សាត្រូវកំណត់ដោយ **ក.ប.ទ.**។ កម្រៃសេវាសម្រាប់ការដោះស្រាយវិវាទត្រូវកំណត់ដោយប្រកាសរួមរវាង **ក.ប.ទ.** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## មាត្រា ៦៨.-

លទ្ធផលនៃការផ្សះផ្សា ត្រូវចុះក្នុងកំណត់ហេតុដែលធ្វើឡើងដោយ **ន.ទ.ក.** ។ កំណត់ហេតុនេះត្រូវចុះពីការយល់ព្រមសះជា ឬការមិនយល់ព្រមសះជារវាងភាគីវិវាទ និងត្រូវចុះហត្ថលេខាដោយ **ន.ទ.ក.** និងភាគីវិវាទទាំងអស់ រួចត្រូវចម្លងជូនគ្រប់ភាគីវិវាទ ។

ការព្រមព្រៀងដែលបានធ្វើឡើងនៅចំពោះមុខ **ន.ទ.ក.** មានអានុភាពអនុវត្តក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ចាប់ពីថ្ងៃទទួលបានកំណត់ហេតុសះជា ។

ក្នុងករណីពុំព្រមអនុវត្តតាមការព្រមព្រៀងដូចមានក្នុងកំណត់ហេតុសះជា ឬក្នុងករណីពុំមានការយល់ព្រមសះជា ភាគីវិវាទអាចបន្តនីតិវិធីទៅមជ្ឈត្តការ ឬប្តឹងទៅតុលាការមានសមត្ថកិច្ចស្របតាមបទប្បញ្ញត្តិជាធរមាន ។

ដើម្បីទទួលបានគុណវុឌ្ឍិជាមជ្ឈត្តករក្នុងវិស័យទូរគមនាគមន៍ មជ្ឈត្តករក្នុងន័យនៃបទប្បញ្ញត្តិស្តីពីមជ្ឈត្តការពាណិជ្ជកម្ម ត្រូវទទួលការបណ្តុះបណ្តាលបន្ថែមពី **ក.ប.ទ.** ។ លក្ខខណ្ឌនៃការបណ្តុះបណ្តាលនេះត្រូវកំណត់ដោយប្រកាសរបស់ **ក.ប.ទ.** ។

បទប្បញ្ញត្តិនៃមាត្រានេះពុំអនុវត្តចំពោះចំណុច (ង) នៃមាត្រា ៣១ នៃច្បាប់នេះទេ ។

## មាត្រា ៦៩.-

បន្ថែមទៅលើវិធានការដែល **ក.ប.ទ.** ដាក់ឲ្យអនុវត្តនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ **ន.ទ.ក.** អាចចាត់វិធានការ ដូចខាងក្រោមក្នុងករណីប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍បានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬបទប្បញ្ញត្តិផ្សេងទៀត ៖

ក- ចេញលិខិតព្រមាន

ខ- ចេញបទបញ្ជាឲ្យជួសជុល ឬផ្តល់សំណងព្យសនកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

គ- ស្នើសុំឲ្យតុលាការមានសមត្ថកិច្ចចេញសេចក្តីសម្រេចតម្រូវឲ្យអនុវត្តតាមបទប្បញ្ញត្តិជាធរមាន និងឲ្យជួសជុល ឬផ្តល់សំណងព្យសនកម្ម

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

ឃ- ចាត់វិធានការដាក់ទណ្ឌកម្មរដ្ឋបាល ។ ទណ្ឌកម្មរដ្ឋបាលនិងនីតិវិធីត្រូវកំណត់បន្ថែមដោយប្រកាសរបស់ **ក.ប.ទ.** ។

## ជំពូកទី ១៣
## អធិការកិច្ចទូរគមនាគមន៍

### មាត្រា ៧០.-

រដ្ឋមន្ត្រី **ក.ប.ទ.** ត្រូវចាត់តាំងមន្ត្រីអធិការកិច្ចទូរគមនាគមន៍ ដើម្បីតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់នេះ ។

មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានភារកិច្ច និងសិទ្ធិដូចខាងក្រោម ៖

ក- ធ្វើអធិការកិច្ចបច្ចេកទេសលើគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ហេដ្ឋារចនាសម្ព័ន្ធ និងបណ្ដាញទូរគមនាគមន៍ និងការផ្ដល់សេវាទូរគមនាគមន៍

ខ- ស្រាវជ្រាវ អង្កេត តាមដាន ទប់ស្កាត់ និងបង្ក្រាបបទល្មើសក្នុងវិស័យទូរគមនាគមន៍

គ- ដកយកសំណាកទិន្នន័យ និងគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យស្តង់ដា និងមុខងារគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និងការធ្វើវិភាគផ្ទៀងផ្ទាត់បរិមាណសេវាទូរគមនាគមន៍

ឃ- ចាប់យកវត្ថុតាងនិងបិទស្លាកបោះត្រាលើវត្ថុតាង និង

ង- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី **ក.ប.ទ.** ។

### មាត្រា ៧១.-

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឲ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះ ដោយអនុវត្តឲ្យស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បែបបទ និងនីតិវិធីនៃការផ្ដល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចទូរគមនាគមន៍ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រី **ក.ប.ទ.** ។

### មាត្រា ៧២.-

ក្នុងក្របខណ្ឌនៃប្រតិបត្តិការទាក់ទងនឹងការពិនិត្យ និងការស៊ើបអង្កេតបទល្មើសដែលមានចែងក្នុងច្បាប់នេះ មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានសិទ្ធិអំណាចធ្វើការឆែកឆេរ ចាប់យកវត្ថុតាង កោះហៅបុគ្គលពាក់ព័ន្ធ និងបំពេញកិច្ចនីតិវិធីដទៃទៀត ដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ក្នុងករណីចាំបាច់ដែល ត្រូវឃាត់ខ្លួនជនសង្ស័យ មន្ត្រីអធិការកិច្ចទូរគមនាគមន៍ត្រូវទទួលការអនុញ្ញាត និងត្រូវស្ថិតនៅក្រោមការដឹកនាំ សម្របសម្រួលដោយផ្ទាល់ពីព្រះរាជអាជ្ញា ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានសមត្ថកិច្ច អាចស្នើសុំជំនួយពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៧៣.-**

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ត្រូវមានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ។ នៅពេលប្រតិបត្តិការ អនុវត្តច្បាប់ មន្ត្រីអធិការកិច្ចទូរគមនាគមន៍ត្រូវមានលិខិតបញ្ជាបេសកកម្ម ។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៤.-**

នៅក្នុងដំណើរការអធិការកិច្ចវិស័យទូរគមនាគមន៍ ក្នុងករណីមានភស្តុតាងជាក់ស្តែង ឬលទ្ធផលវិភាគ ផ្ទៀងផ្ទាត់បញ្ជាក់ថាសេវានិងគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ណាមួយ មានលក្ខណៈបច្ចេកទេសផ្ទុយពីស្តង់ដា ដែលត្រូវបានកំណត់នៅក្នុងច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត នៅពេលស្នើសុំការចុះបញ្ជី ឬមានប្រតិបត្តិការណាមួយ បង្កប់នូវចរិតលក្ខណៈផ្ទុយពីគោលការណ៍នៃការប្រកួតប្រជែងស្របច្បាប់ ដែលបានកំណត់ក្នុងច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានសមត្ថកិច្ចចាត់វិធានការផ្អាកជាបណ្តោះអាសន្ននូវការផ្តល់សេវា ការផ្គត់ផ្គង់ ការចែកចាយគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និងប្រតិបត្តិការផ្សេងទៀតពាក់ព័ន្ធនឹងបទល្មើស ដើម្បីដោះស្រាយ តាមនីតិវិធី ។

**មាត្រា ៧៥.-**

បុគ្គលណាដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ អាចប្តឹងតវ៉ាក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៅ **ក.ប.ទ.** គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច ។

រដ្ឋមន្ត្រី **ក.ប.ទ.** ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

ក្នុងករណីបុគ្គលនោះមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី **ក.ប.ទ.** ជននោះមានសិទ្ធិធ្វើបណ្តឹង ទៅយន្តការផ្សេងទៀតរបស់រាជរដ្ឋាភិបាល ឬទៅតុលាការតាមនីតិវិធី ។

**មាត្រា ៧៦.-**

នៅពេលប្រតិបត្តិការអនុវត្តច្បាប់នេះ ក្នុងករណីដែលវត្ថុតាងនៃបទល្មើសជាផលិតផលហាមឃាត់ ឬមានគ្រោះថ្នាក់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ មានសិទ្ធិស្នើសុំដីកាសម្រេចរបស់ព្រះរាជអាជ្ញា ដើម្បីធ្វើការបំផ្លាញចោល ដោយអនុលោមតាមនីតិវិធីជាធរមាន ។

ការចំណាយលើការលើកដាក់ ការដឹកជញ្ជូន ការថែរក្សា និងការបំផ្លាញចោលវត្ថុតាងនៅក្នុងដំណើរការ អនុវត្តច្បាប់នេះ គឺជាបន្ទុករបស់ម្ចាស់វត្ថុតាងនៃបទល្មើស ។ ករណីអត្តសញ្ញាណម្ចាស់វត្ថុតាងនៃបទល្មើសមិនត្រូវបាន ស្គាល់រាល់ការចំណាយជាបន្ទុករបស់រដ្ឋ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ៧៧.–**

បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចទូរគមនាគមន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.** ។

## ជំពូកទី ១៤
## ទោសប្បញ្ញត្តិ

**មាត្រា ៧៨.–**

ក្រោយពេលផ្តល់អាជ្ញាបណ្ណក្រោមច្បាប់នេះ ប្រសិនបើពិនិត្យឃើញថាប្រតិបត្តិករទូរគមនាគមន៍ មិនអនុវត្តតាម លក្ខខណ្ឌណាមួយនៃអាជ្ញាបណ្ណ ឬលក្ខខណ្ឌណាមួយដែលកំណត់ដោយច្បាប់នេះ ឬបទប្បញ្ញត្តិផ្សេងទៀត **ន.ទ.ក.** អាចចាត់វិធានការជាអាទិ៍ដូចខាងក្រោម ៖

ក- ដឹកនាំកែតម្រង់ប្រតិបត្តិករទូរគមនាគមន៍ឲ្យអនុវត្តតាមលក្ខខណ្ឌ ឬលក្ខខណ្ឌបន្ថែម

ខ- ដាក់កំហិតលើអាជ្ញាបណ្ណ

គ- ព្យួរអាជ្ញាបណ្ណរហូតដល់ប្រតិបត្តិករទូរគមនាគមន៍គោរពពេញលេញតាមលក្ខខណ្ឌ ឬ លក្ខខណ្ឌបន្ថែម ។

ក្នុងករណីប្រតិបត្តិករទូរគមនាគមន៍បានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬបទប្បញ្ញត្តិផ្សេងទៀត **ន.ទ.ក.** អាចចាត់វិធានការជាអាទិ៍ដូចខាងក្រោម ៖

ក- ព្យួរបណ្តោះអាសន្ន ឬបញ្ឈប់ការងាររបស់អគ្គនាយក នាយកប្រតិបត្តិ សមាជិកគណៈគ្រប់គ្រង ឬបុគ្គលិកជាន់ខ្ពស់របស់ប្រតិបត្តិករទូរគមនាគមន៍

ខ- ជ្រើសរើសនិងផ្តល់អំណាចដល់បុគ្គលដែលមានសមត្ថកិច្ចសមស្រប ដើម្បីពិនិត្យមើលសកម្មភាពអាជីវកម្ម ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតរបស់ប្រតិបត្តិករទូរគមនាគមន៍ ។ បុគ្គលនោះត្រូវធ្វើរបាយការណ៍ឲ្យទៅ **ន.ទ.ក.** តាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាជាមួយ **ន.ទ.ក.** ឬ

គ- ដាក់កំហិត ឬបញ្ឈប់សកម្មភាពជាក់លាក់ ឬទូទៅរបស់ប្រតិបត្តិករទូរគមនាគមន៍ ទោះបីជាសកម្មភាពទាំងនោះបានធ្វើឡើងស្រប ឬមិនស្របតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណក៏ដោយ ។

**ន.ទ.ក.** អាចចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ លុះត្រាតែបានជូនដំណឹងជា លាយលក្ខណ៍អក្សរជាមុនដល់ប្រតិបត្តិករទូរគមនាគមន៍ អំពីមូលហេតុនៃការចាត់វិធានការនេះនិងបានផ្តល់ឱកាសឲ្យ ប្រតិបត្តិករទូរគមនាគមន៍ធ្វើការពន្យល់ ។

**មាត្រា ៧៩.-**

បទល្មើសក្នុងវិស័យទូរគមនាគមន៍ដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការដាក់ពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់ **ន.ប.ទ.** ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការដាក់ពិន័យអន្តរកាណ៍ត្រូវកំណត់ដោយប្រកាសរបស់ **ន.ប.ទ.** ។

**មាត្រា ៨០.-**

ការបង្កើត ការដំឡើង ការប្រើប្រាស់ ឬការកែប្រែហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញទូរគមនាគមន៍ ឬការបង្កើត ការដំឡើង ការប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខាវិស័យទូរគមនាគមន៍ កាលបើអំពើនេះអាចនាំឲ្យអន្តរាយដល់សន្តិសុខជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ៨១.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៨០ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ១៥០ ០០០ ០០០ (មួយរយសែសិបលាន) រៀល ទៅ ៣០០ ០០០ ០០០ (បីរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៨២.-**

ការបំផ្លាញ ឬការធ្វើឲ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញទូរគមនាគមន៍ ដោយចេតនា ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

អំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ៖

- ពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០(ដប់) ឆ្នាំ កាលបើអំពើនេះបង្កឲ្យមានរបួសដល់អ្នកដទៃ ។
- ពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះនាំឲ្យមានការកាត់អវយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ ។
- ពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តឡើងជាក្រុមមានការចាត់តាំង ។
- ពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះបណ្តាលឲ្យអ្នកដទៃស្លាប់ដោយគ្មានចេតនាសម្លាប់ ។

**មាត្រា ៨៣.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៨២ ខាងលើនេះ ត្រូវពិន័យជាប្រាក់

ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ ៤០០ ០០០ ០០០ (បួនរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៨៤.-**

ការបង្កើត ការដំឡើង ការប្រើប្រាស់ ឬការកែប្រែហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញទូរគមនាគមន៍ ឬគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ដើម្បីបង្កការកាត់ផ្តាច់ ការរំខាន ឬការជ្រៀតជ្រែកលើហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធទូរគមនាគមន៍ ឬបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

**មាត្រា ៨៥.-**

ការបង្កើតប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលដំណើរការជាមួយបណ្តាញទូរគមនាគមន៍សម្រាប់ប្រើប្រាស់ក្នុងគោលបំណងគេចវេះពីការទូទាត់ប្រាក់ ឬកេងចំណេញលើបរិមាណនៃការផ្តល់សេវាទូរគមនាគមន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

**មាត្រា ៨៦.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៨៤ និងមាត្រា ៨៥ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៨៧.-**

ការប្រើប្រាស់ ឬការអនុញ្ញាតឲ្យប្រើប្រាស់ដោយបន្លំនូវសេវាទូរគមនាគមន៍ ក្នុងគោលបំណងគេចវេះពីការទូទាត់ប្រាក់ ឬកេងចំណេញលើបរិមាណនៃការផ្តល់សេវាទូរគមនាគមន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៨៨.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៨៧ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៦០ ០០០ ០០០ (ហុកសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៨៩.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល ចំពោះ ៖

ក- ការធ្វើប្រតិបត្តិការដូចមានចែងក្នុងមាត្រា ១៥ នៃច្បាប់នេះ ដោយគ្មានលិខិតអនុញ្ញាតពី **ន.ធ.ក.** ។

ខ- ការធ្វើប្រតិបត្តិការដូចមានចែងក្នុងមាត្រា ១៦ នៃច្បាប់នេះ ដោយគ្មានវិញ្ញាបនបត្រពី **ន.ធ.ក.** ។

**មាត្រា ៩០.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៨៩ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៩១.-**

ការធ្វើប្រតិបត្តិការដូចមានចែងក្នុងមាត្រា១៧នៃច្បាប់នេះ ដោយគ្មានអាជ្ញាបណ្ណពី **ន.ធ.ក.** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន)រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

**មាត្រា ៩២.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៩១ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល ទៅ ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៩៣.-**

អំពើគំរាមកំហែងថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមប្រឆាំងនឹងបុគ្គល កាលបើការគំរាមកំហែងនេះធ្វើឡើង ម្តងហើយម្តងទៀត តាមគ្រប់មធ្យោបាយទូរគមនាគមន៍ ទោះបីជាបង្ហាញ ឬពុំបង្ហាញនូវអត្តសញ្ញាណរបស់ខ្លួនក្តី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ១ ០០០ ០០០ (មួយលាន) រៀល ។

អំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ៖

- ពី ៦ (ប្រាំមួយ) ខែ ទៅ ២(ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល កាលបើអំពើនេះត្រូវបានធ្វើឡើងដោយមានបញ្ជាឲ្យបំពេញលក្ខខណ្ឌអ្វីមួយ ។
- ពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល កាលបើអំពើនេះ ជាអំពើគំរាមកំហែងថានឹងសម្លាប់ ។
- ពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល កាលបើអំពើនេះ ជាអំពើគំរាមកំហែងថានឹងសម្លាប់ ដោយមានបញ្ជាឲ្យបំពេញលក្ខខណ្ឌអ្វីមួយ ។

**មាត្រា ៩៤.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៩៣ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៦០ ០០០ ០០០ (ហុកសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៩៥.-**

អំពើគំរាមកំហែងថានឹងប្រព្រឹត្តការបំផ្លិចបំផ្លាញ ការធ្វើឲ្យទ្រុឌទ្រោម ឬការធ្វើឲ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់ជនដទៃ កាលបើការគំរាមកំហែងនេះធ្វើឡើងម្តងហើយម្តងទៀត តាមគ្រប់មធ្យោបាយទូរគមនាគមន៍ ទោះបីជាបង្ហាញ ឬពុំបង្ហាញនូវអត្តសញ្ញាណរបស់ខ្លួនក្តី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន)រៀល ទៅ ១ ០០០ ០០០ (មួយលាន) រៀល ។

អំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល កាលបើអំពើគំរាម កំហែងនេះមានភ្ជាប់នូវបញ្ជាឲ្យបំពេញ ឬមិនបំពេញកិច្ចអ្វីមួយ ។

**មាត្រា ៩៦.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៩៥ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤០ ០០០ ០០០ (សែសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ៩៧.-**

ការលបស្តាប់ឬការលបថតការសន្ទនា ដោយការប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ដោយបុគ្គលដែលពុំមែនជាភាគីនៃការសន្ទនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងទទួលពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល ។

បទប្បញ្ញត្តិកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តទេ ក្នុងករណីដែលការស្តាប់ ឬការថតការសន្ទនានោះ ធ្វើឡើងដោយមានការយល់ព្រមពីបុគ្គលដែលមានការពាក់ព័ន្ធ ឬដោយមានការអនុញ្ញាតពីអាជ្ញាធរ ជម្មានុរូប ។

ត្រូវផ្តន្ទាទោសដូចគ្នាចំពោះការផ្សព្វផ្សាយខ្លឹមសារនៃការសន្ទនា ដោយពុំបានទទួលសិទ្ធិស្របច្បាប់ពីភាគីនៃការសន្ទនា ឬពីអាជ្ញាធរជម្មានុរូប ឬពីបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា ៩៨.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៩៧ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៩៩.-**

ការផលិត ការដំឡើង ឬការចែកចាយដោយគ្មានការអនុញ្ញាតពីអាជ្ញាធរជម្មានុរូបនូវកម្មវិធីសូហ្វវែរ ឬឧបករណ៍ស្តាប់ ឬថតការសន្ទនាដោយការប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។

**មាត្រា ១០០.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៩៩ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៤០ ០០០ ០០០ (សែសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមាន ចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ១០១.-**

ការយកអត្តសញ្ញាណតតិយជន ដោយប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ ក្នុងកាលៈទេសៈដែលនាំឲ្យមាន ឬដែលអាចនាំឲ្យមានការចោទប្រកាន់ខាងបទព្រហ្មទណ្ឌចំពោះតតិយជននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

**មាត្រា ១០២.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយភ្ជាប់នូវលក្ខខណ្ឌកែតម្រូវសម្រាប់រយៈពេលកំណត់ណាមួយ ដោយ **ន.ធ.ភ.** ចំពោះប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ដែលធ្វើការប្រកួតប្រជែងមិនស្របច្បាប់ល្មើសនឹងកថាខណ្ឌទី ១ នៃមាត្រា ៥៨ មាត្រា ៦១ ឬមាត្រា ៦២ នៃច្បាប់នេះ ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន) រៀល ។

**មាត្រា ១០៣.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ១០២ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល ទៅ ១ ០០០ ០០០ ០០០(មួយពាន់លាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ១០៤.-**

ជនណាដែលបានក្លែងបន្លំព័ត៌មានអំពីថ្លៃដើម របាយការណ៍ហិរញ្ញវត្ថុ ឬព័ត៌មានពុំមែនហិរញ្ញវត្ថុ ហើយបានផ្ញើទៅ **ន.ធ.ភ.** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន) រៀល ។

**មាត្រា ១០៥.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ១០៤ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល ទៅ ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ១០៦.-**

ចំពោះបទល្មើសប្រព្រឹត្តដោយរូបវន្តបុគ្គលដូចមានចែងក្នុងច្បាប់នេះ ទោសបន្ថែមមួយឬច្រើន ដែលមានចែង ក្នុងក្រមព្រហ្មទណ្ឌដូចខាងក្រោមនេះ អាចត្រូវបានប្រកាស ៖

១- ការដកសិទ្ធិខ្លះជាពលរដ្ឋ ។

២- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណាដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ។

៣- ការហាមឃាត់ចំពោះការស្នាក់នៅ ។

៤- ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាចំពោះទណ្ឌិតដែលជាជនបរទេស ។

៥- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ។

៦- ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៧- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៨- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

៩- ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។

១០- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

១១- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

១២- ការបិទគ្រឹះស្ថានដែលប្រើប្រាស់ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ។

១៣- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ។

១៤- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ។

១៥- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៦- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

**មាត្រា ១០៧.-**

អំពើល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គល គឺជាអំពើល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ ។

អង្គការ ឬអ្នកតំណាងរបស់នីតិបុគ្គល សំដៅដល់អង្គការ ឬបុគ្គលដែលមានសិទ្ធិសម្រេចក្នុងនាមនីតិបុគ្គល ស្របតាមលក្ខន្តិកៈរបស់នីតិបុគ្គលនោះ ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលនោះទេ ។

**មាត្រា ១០៨.-**

មន្ត្រី **អ.ប.ឧ.** និង **ន.ឧ.អ.** ណាដែលរំលោភលើសមត្ថកិច្ចរបស់ខ្លួន ឬប្រើសិទ្ធិអំណាចរាំងការអនុវត្តច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលតាមច្បាប់ជាធរមានដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ១០៩.-**

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងមាត្រា ៨២ មាត្រា ៨៤ មាត្រា ៨៥ មាត្រា៨៧ មាត្រា ៩៩ មាត្រា ១០១ មាត្រា ១០២ និងមាត្រា ១០៤ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមបានសម្រេចដែរ ។

## ជំពូកទី ១៥
## អន្តរប្បញ្ញត្តិ

**មាត្រា ១១០.-**

ក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ត្រូវបំពេញទម្រង់បែបបទថ្មីនៅ **ន.ទ.ក.** ដើម្បីសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណដែលនៅមានសុពលភាពក្រោយច្បាប់នេះចូលជាធរមាន ត្រូវអនុវត្តតាមលក្ខខណ្ឌស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

**មាត្រា ១១១.-**

បញ្ញត្តិករទូរគមនាគមន៍កម្ពុជា គឺជានិយ័តករទូរគមនាគមន៍កម្ពុជាបន្ទាប់ពីច្បាប់នេះចូលជាធរមាន ។ បញ្ញត្តិករ ទូរគមនាគមន៍កម្ពុជា ត្រូវបំពេញមុខងារ និងភារកិច្ចបន្តរហូតដល់អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនិយ័តករ ទូរគមនាគមន៍កម្ពុជា ចូលជាធរមាន ។

**មាត្រា ១១២.-**

លក្ខខណ្ឌដូចដែលមានចែងក្នុងបទប្បញ្ញត្តិនៃជំពូក ៦ និងជំពូក ៧ នៃច្បាប់នេះ នឹងត្រូវអនុវត្តក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ។

ROYAUME DU CAMBODGE - LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១៦
# អវសានប្បញ្ញត្តិ

**មាត្រា ១១៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១៤.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០១៥

[illegible]

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**
**ហត្ថលេខា**
**ប្រាក់ សុខុន**

លេខៈ ០៦៥៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ [illegible] ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ឧបសម្ព័ន្ធនៃច្បាប់ស្តីពីទូរគមនាគមន៍
# សទ្ទានុក្រមសម្រាប់ប្រើប្រាស់ក្នុងច្បាប់នេះ

- **កាតព្វកិច្ចសេវាសកល** សំដៅដល់កាតព្វកិច្ចរបស់ប្រតិបត្តិករទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការផ្តល់សេវាទូរគមនាគមន៍មូលដ្ឋាន និងសេវាតម្លៃបន្ថែមជូនដល់ប្រជាពលរដ្ឋទូទៅគ្រប់រូប ក្នុងតម្លៃសមរម្យ គុណភាពសេវាល្អ និងអាចប្រើប្រាស់បាននៅគ្រប់ទីកន្លែងទូទាំងព្រះរាជាណាចក្រកម្ពុជា ។
- **កម្មវិធីកាតព្វកិច្ចសេវាសកល** សំដៅដល់គោលនយោបាយឬផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រង រៀបចំ និងអនុវត្តកាតព្វកិច្ចសេវាសកល ។
- **កម្មវិធីសូហ្វវែរ** សំដៅដល់កម្មវិធីកុំព្យូទ័រទាំងឡាយណាដែលរចនាឡើងក្នុងគោលបំណងសម្រួលដល់អ្នកប្រើប្រាស់ដើម្បីធ្វើអ្វីមួយនៅលើឬតាមរយៈកុំព្យូទ័រ កុំព្យូទ័របន្ទះ ទូរស័ព្ទវៃឆ្លាត ឬឧបករណ៍ បច្ចេកវិទ្យា ទាំងឡាយណាដែលត្រូវ ការការបញ្ចូលកម្មវិធី បែបខាងលើនេះ ។
- **ការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍ** សំដៅដល់យន្តការកសាង បណ្តុះបណ្តាល និងពង្រឹង សមត្ថភាពវិជ្ជាជីវៈ ការស្រាវជ្រាវ និងការអភិវឌ្ឍក្នុងវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ។
- **ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញ** សំដៅដល់ការតភ្ជាប់រវាងហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញរបស់ប្រតិបត្តិករទូរគមនាគមន៍មួយ ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញរបស់ប្រតិបត្តិករទូរគមនាគមន៍មួយទៀត ដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់ឬអតិថិជននៃបណ្តាញផ្សេងគ្នាអាចភ្ជាប់ ការប្រាស្រ័យទាក់ទង ឬការសន្ទនាជាមួយគ្នាបានដោយរលូន ។
- **ការបោះពុម្ពផ្សាយសៀវភៅលេខទូរគមនាគមន៍** សំដៅដល់សកម្មភាពនៃការបោះពុម្ពផ្សាយសៀវភៅ អត្ថបទឬឯកសារលេខទូរគមនាគមន៍ ក្រោមទម្រង់ជាក្រដាស ឬអេឡិចត្រូនិក ក្នុងគោលបំណងធ្វើអាជីវកម្ម ឬពាណិជ្ជកិច្ច ។
- **កិច្ចព្រមព្រៀងគោល** សំដៅដល់លិខិតបទដ្ឋានគតិយុត្ត ឬបទប្បញ្ញត្តិដែលកំណត់អំពីខ្លឹមសារ និងលក្ខខណ្ឌ ស្តីពីការតភ្ជាប់និងលទ្ធភាពនៃការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញទូរគមនាគមន៍ ។
- **កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់** សំដៅដល់កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញ ។
- **ក្បាលលេខទូរគមនាគមន៍** សំដៅដល់លេខ លេខកូដ និងសញ្ញាពិសេសទូរគមនាគមន៍ ដែលត្រូវបាន បែងចែកឲ្យទៅប្រតិបត្តិករទូរគមនាគមន៍យកទៅប្រើប្រាស់ ក្នុងការផ្តល់សេវា ទូរគមនាគមន៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

- **គម្លាតឌីជីថល** សំដៅដល់គម្លាតនៃការទទួលបានសេវានិងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅតាមទីក្រុង ទីប្រជុំជន និងជនបទ។
- **គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍** សំដៅដល់សម្ភារៈបរិក្ខារ ឧបករណ៍ គ្រឿងបង្គុំ ឬឋបនីយកណ្ឌ ដែលត្រូវបានផលិត និង/ឬនាំចេញឬនាំចូលយកមកប្រើប្រាស់ក្នុងប្រព័ន្ធទូរគមនាគមន៍ និង បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ។
- **ថ្លៃដើមនៃសេវាទូរគមនាគមន៍** សំដៅដល់ថ្លៃដើមនៃសេវាទូរគមនាគមន៍ដែលប្រតិបត្តិករ ទូរគមនាគមន៍ត្រូវ ផ្តល់ជូន **ន.ទ.ក.** ក្នុងពេលកំណត់មួយជាក់លាក់សម្រាប់ធ្វើជាមូលដ្ឋាន ដើម្បី ត្រួតពិនិត្យនិងតាមដានអំពីនីត្យានុកូលភាពនិងភាពស្មោះត្រង់នៃការប្រកួតប្រជែង ។ រូបមន្ត កំណត់ថ្លៃដើមនេះ ត្រូវកំណត់ដោយ **ក.ប.ទ.** តាមសំណើរបស់ **ន.ទ.ក.** ។
- **ថ្លៃសេវាទូរគមនាគមន៍** សំដៅដល់ថ្លៃសេវាទូរគមនាគមន៍ទាំងឡាយណាដែលត្រូវបានកំណត់ ដោយប្រតិបត្តិករទូរគមនាគមន៍ ជូនដល់អ្នកប្រើប្រាស់ ។
- **ទិន្នន័យសេវាទូរគមនាគមន៍និងព័ត៌មានវិទ្យា** សំដៅដល់ទិន្នន័យទាំងឡាយពាក់ព័ន្ធនឹងប្រតិបត្តិការ ទូរគមនាគមន៍ ដែលត្រូវបានផ្តល់តាមរយៈការតភ្ជាប់បណ្តាញផ្ទាល់ ឬតាមមធ្យោបាយ បច្ចេកទេស សមស្របផ្សេងទៀតជាមួយ ប្រតិបត្តិករឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ។
- **ទីផ្សារទូរគមនាគមន៍** សំដៅដល់ទីកន្លែងសម្រាប់ធ្វើពាណិជ្ជកិច្ចវិស័យទូរគមនាគមន៍ ។
- **ទម្រង់ទាំងអស់** សំដៅដល់ទម្រង់ទាំងឡាយដែលត្រូវបានកំណត់ក្នុងបទប្បញ្ញត្តិស្តីពីការប្រកួត ប្រជែង ។
- **ទូរគមនាគមន៍** សំដៅដល់វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាក្នុងការបញ្ជូននិងទទួលស៊ីញ៉ាល់ ទិន្នន័យ សំឡេង រូបភាព ឬប្រភេទព័ត៌មានដទៃទៀត តាមរយៈការប្រើប្រាស់ថាមពលក្រោម ទម្រង់អេឡិក ត្រូម៉ាញ៉េទិក អគ្គិសនី វិទ្យុ ពន្លឺ ឬទម្រង់ដទៃទៀត ។
- **ធនធានវិសាលគមន៍ប្រេកង់វិទ្យុ** សំដៅដល់ធនធាននៃថាមពលអេឡិកត្រូម៉ាញ៉េទិកទាំងមូល ដែលត្រូវបានផ្សាយនិងត្រូវបានកំណត់ជាប្រេកង់ ឬជំហានរលកអាកាស ។
- **ប្រេកង់វិទ្យុ** សំដៅដល់អត្រាលំយោលនៃរលកអាកាសវិទ្យុ ក្នុងចិរវេលាកំណត់មួយ ។
- **និយ័តករទូរគមនាគមន៍កម្ពុជា** សំដៅដល់និយ័តករទូរគមនាគមន៍ដែលត្រូវបានបង្កើតដោយ ច្បាប់នេះ ។
- **បុគ្គល** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គល ។
- **បុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលកំពុងធ្វើ ពាណិជ្ជកិច្ច ក្នុងវិស័យទូរគមនាគមន៍ ដោយមិនរាប់បញ្ចូលនូវប្រតិបត្តិករទូរគមនាគមន៍ ។
- **បណ្តាញរួម** សំដៅដល់បណ្តាញទាំងឡាយណាដែលត្រូវបានប្រើប្រាស់ដោយប្រតិបត្តិករ ទូរគមនាគមន៍ពីរ ឬច្រើន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

- **ប្រតិបត្តិករទូរគមនាគមន៍** សំដៅដល់នីតិបុគ្គលដែលទទួលអាជ្ញាបណ្ណធ្វើប្រតិបត្តិការទូរគមនាគមន៍ទាំងអស់ នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។
- **ប្រតិបត្តិការទូរគមនាគមន៍** សំដៅដល់រាល់សកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ក្នុងការបញ្ជូននិងទទួលស៊ីញ៉ាល់ ទិន្នន័យ សំឡេង រូបភាព ឬប្រភេទព័ត៌មានដទៃទៀត តាមរយៈការប្រើប្រាស់ថាមពលក្រោមទម្រង់អេឡិកត្រូម៉ាញ៉េទិក អគ្គិសនី វិទ្យុ ពន្លឺ ឬទម្រង់ដទៃទៀត ។
- **ប្លង់លេខទូរគមនាគមន៍ជាតិ** សំដៅដល់ប្លង់ដែលត្រូវបានរៀបចំ ដើម្បីគ្រប់គ្រង និងកំណត់អំពីលេខ លេខកូដ និងសញ្ញាសម្គាល់ពិសេសទូរគមនាគមន៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- **ប្លង់វិសាលគមន៍ប្រេកង់សវិទ្យុជាតិ** សំដៅដល់ប្លង់ដែលកំណត់ បែងចែក និងប្រើប្រាស់ធនធានវិសាលគមន៍ វិទ្យុជាតិប្រកបដោយប្រសិទ្ធភាព ស្របតាមបទដ្ឋាន ឬស្តង់ដា ក្នុងតំបន់ និងអន្តរជាតិ ។
- **មជ្ឈត្តការមានសមត្ថកិច្ច** សំដៅដល់ការផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្ម ដែលក្នុងនោះ មជ្ឈត្តករ ទទួលបានការបណ្តុះបណ្តាលក្នុងវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងទទួលបានគុណវុឌ្ឍិពី **ន.ទ.ក.** ។
- **មូលនិធិនៃកាតព្វកិច្ចសេវាសកល** សំដៅដល់សំណុំនៃថវិកាទាំងឡាយដែលប្រើប្រាស់ដើម្បីទ្រទ្រង់និងអនុវត្ត កម្មវិធីកាតព្វកិច្ចសេវាសកល ។
- **មូលនិធិនៃការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍ** សំដៅដល់សំណុំនៃថវិកាទាំងឡាយដែល ប្រើប្រាស់ដើម្បីទ្រទ្រង់ និងលើកកម្ពស់ដល់ការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ ក្នុងវិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ។
- **លេខទូរគមនាគមន៍** សំដៅដល់លេខ លេខកូដ និងសញ្ញាសម្គាល់ពិសេសទូរគមនាគមន៍ ។
- **វិស័យសន្តិសុខនិងការពារជាតិ** ក្នុងន័យនៃមាត្រា ៣ នៃច្បាប់នេះ សំដៅដល់ប្រតិបត្តិការទូរគមនាគមន៍ដែលត្រូវបានប្រើប្រាស់សម្រាប់វិស័យសន្តិសុខនិងការពារជាតិ ។
- **សេវាគ្រាអាសន្ន** សំដៅដល់សេវាទូរគមនាគមន៍ដែលត្រូវបានប្រើប្រាស់ក្នុងគ្រាអាសន្ន ដោយសាធារណជន និងត្រូវបានផ្តល់ទៅដល់អង្គភាពនគរបាលជាតិ អង្គភាពពន្លត់អគ្គិភ័យ និងអង្គភាពសេវារថយន្តសង្គ្រោះបន្ទាន់ ។
- **សេវាទូរគមនាគមន៍** សំដៅដល់សេវាទាំងឡាយណាដែលត្រូវបានផ្តល់សម្រាប់ការបញ្ជូន និងការទទួលសំឡេង ទិន្នន័យ ស៊ីញ៉ាល់ រូបភាព ឬប្រភេទព័ត៌មានដទៃទៀត តាមរយៈការប្រើប្រាស់ថាមពលក្រោមទម្រង់អេឡិកត្រូម៉ាញ៉េទិក អគ្គិសនី វិទ្យុ ពន្លឺ ឬទម្រង់ដទៃទៀត ។ សេវាទូរគមនាគមន៍ក្នុងន័យនៃច្បាប់នេះ រួមបញ្ចូលទាំងសេវាទូរគមនាគមន៍មូលដ្ឋាន និងសេវាទូរគមនាគមន៍តម្លៃបន្ថែម ។

- **សេវាទូរគមនាគមន៍មូលដ្ឋាន** សំដៅដល់សេវាទូរគមនាគមន៍ទាំងឡាយណា ដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់ធ្វើការប្រាស្រ័យទាក់ទង ឬសន្ទនាជាមួយគ្នាដោយផ្ទាល់ក្នុងពេលវេលាពិតប្រាកដស្របតាមការកំណត់របស់អង្គការ ពាណិជ្ជកម្មពិភពលោក ។
- **សេវាទូរគមនាគមន៍តម្លៃបន្ថែម** សំដៅដល់សេវាទាំងឡាយណាដែលប្រតិបត្តិករ ទូរគមនាគមន៍ផ្តល់នូវតម្លៃបន្ថែម លើសេវាទូរគមនាគមន៍មូលដ្ឋានតាមរយៈការធ្វើឲ្យប្រសើរឡើងនូវទម្រង់ ឬមាតិកាព័ត៌មាន ឬផ្តល់ការរក្សាទុក និងទាញយកព័ត៌មាន ។
- **សេវាទូរគមនាគមន៍សាធារណៈ** សំដៅដល់សេវាទូរគមនាគមន៍សម្រាប់បម្រើដល់សាធារណជន ។
- **ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញ** សំដៅដល់បង្គុំនៃបរិក្ខារទូរគមនាគមន៍ដូចជា បបមាណីទូរគមនាគមន៍បណ្តាញបញ្ជូនស៊ីញ៉ាល់ និងសំណង់ទូរគមនាគមន៍ពាក់ព័ន្ធ ។
- **ហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទូរគមនាគមន៍** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធទាំងឡាយណាដែលត្រូវបានប្រើប្រាស់សម្រាប់ទ្រទ្រង់ និងគាំពារហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ។
- **ហេដ្ឋារចនាសម្ព័ន្ធរួបវន្ត** សំដៅទៅលើសំណុំហេដ្ឋារចនាសម្ព័ន្ធ ដែលរាប់បញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធ ប្រើប្រាស់សម្រាប់បម្រើវិស័យគមនាគមន៍ ថាមពល ទឹកស្អាត កាកសំណល់រឹង និងរាវ វិស័យទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ។
- **អនិស្សរភាព** ភាពដែលចំណុះគេ ។
- **អាសយដ្ឋានអេឡិកត្រូនិក** សំដៅដល់លេខឬអក្សរអេឡិកត្រូនិក សម្រាប់កំណត់អំពី អាសយដ្ឋាន ឬអត្តសញ្ញាណនៃបណ្តាញបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ។
- **ឧបសម្ព័ន្ធនៃថវិកា** សំដៅដល់ថវិកាដែលត្រូវបានរៀបចំក្នុងតារាងដោយឡែកពីថវិការបស់ក្រសួង ស្ថាប័ន អាណាព្យាបាលបច្ចេកទេស ដោយត្រូវគោរពតាមទម្រង់គំរូ ដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ និងស្របតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ ដូចមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។ ថវិកានេះត្រូវភ្ជាប់ជាមួយថវិការបស់ក្រសួង ស្ថាប័ន អាណាព្យាបាលបច្ចេកទេស និងត្រូវបម្រើឲ្យគោលបំណងនៃគោលនយោបាយរបស់ក្រសួង ស្ថាប័នអាណាព្យាបាល បច្ចេកទេស ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្តល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា២៦ មាត្រា២៧ មាត្រា២៨ និងមាត្រា២៩ និងបំពេញបន្ថែមមាត្រា២៩ ស្ទួន នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលបំណងធានាការគ្រប់គ្រងឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ប្រកបដោយប្រសិទ្ធភាពនិងគណនេយ្យភាព ធានានិងលើកទឹកចិត្តការប្រមូលផ្តុំប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្នុងន័យជំរុញនវានុវត្តន៍ កំណើនសេដ្ឋកិច្ច និងការកៀគរចំណូលថវិកាជាតិ និងធានាសន្តិសុខនិងសុវត្ថិភាពរបស់ប្រជាជន។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពី៖

- លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ ការផ្ទេរ និងការដកហូតការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការត្រួតពិនិត្យនិងការតាមដានការអនុវត្តលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណ។

**មាត្រា៣ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តន៍ចំពោះរាល់ប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .-**

និយមន័យនៃពាក្យបច្ចេកទេសក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

**ការអនុញ្ញាត** សំដៅដល់ លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ។

**សូហ្វវែរ** សំដៅដល់កម្មវិធីសម្រាប់ធ្វើឱ្យដំណើរការប្រព័ន្ធកុំព្យូទ័រ ឬកម្មវិធីសម្រាប់សម្រួលដល់ការងាររបស់អ្នកប្រើប្រាស់នៅលើកុំព្យូទ័រ កុំព្យូទ័របន្ទះ ទូរស័ព្ទវៃឆ្លាត ឬឧបករណ៍បច្ចេកវិទ្យាផ្សេងទៀត។

**ការផលិត** សំដៅដល់ការបង្កើតផលិតផលសម្រេចដោយបំលែងចេញពីវត្ថុធាតុដើមឬផលិតផលមិនទាន់សម្រេច។

**ការផ្គុំ** សំដៅដល់ការបង្កើតផលិតផលសម្រេចដោយផ្គុំឡើងពីផលិតផលមិនទាន់សម្រេច។

**ការដំឡើង** សំដៅដល់ការរៀបចំដាក់ឱ្យប្រើប្រាស់។

**គ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ** សំដៅដល់សម្ភារៈបរិក្ខារ ឧបករណ៍ គ្រឿងបង្គុំឬបបនីយកណ្ឌដែលត្រូវបានផលិតនិង/ឬនាំចេញឬនាំចូលសម្រាប់ប្រើប្រាស់ជាមួយនឹងកុំព្យូទ័រ។

**បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន** សំដៅដល់បច្ចេកវិទ្យា ដែលរួមមានទាំងហាដវែរនិងសូហ្វវែរសម្រាប់ដំណើរការ រក្សាទុក វិភាគនិង/ឬបញ្ជូនទិន្នន័យ ឬព័ត៌មានតាមប្រព័ន្ធទូរគមនាគមន៍។

**មជ្ឈមណ្ឌលទិន្នន័យ** សំដៅដល់ទីតាំងដែលផ្តល់សេវារក្សាទុក ដំណើរការវិភាគ ការពារសុវត្ថិភាពបញ្ជូនទទួលទិន្នន័យនិងសេវាពាក់ព័ន្ធ។

**មាតិកា** សំដៅដល់កម្រងព័ត៌មានឌីជីថលដែលត្រូវបានរក្សាទុក ដំណើរការ ឬផ្សព្វផ្សាយតាមរយៈកុំព្យូទ័រ កុំព្យូទ័របន្ទះ ទូរស័ព្ទវៃឆ្លាត ឬឧបករណ៍បច្ចេកវិទ្យាផ្សេងៗទៀត។

**សេវាអនឡាញ** សំដៅដល់សេវាទាំងឡាយណាដែលត្រូវបានផ្តល់តាមរយៈប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន លើកលែងតែសេវាល្បែងស៊ីសង។

**ឧបករណ៍អេឡិកត្រូនិក** សំដៅដល់ឧបករណ៍ទាំងឡាយណាដែលត្រូវបានបង្កើតឡើងសម្រាប់ធ្វើអ្វីមួយជាក់លាក់ដោយប្រើប្រាស់គ្រឿងអេឡិកត្រូនិកជាធាតុផ្សំនិងជាខួរក្បាលនៃឧបករណ៍។

## ជំពូកទី២
## លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណ

### មាត្រា៥.-

គ្មានបុគ្គលណាអាចបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ លើកលែងតែបុគ្គលនោះបានទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**)។

អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (**អ.ប.គ.ព.**) ជាសេនាធិការរបស់ **ក.ប.ទ.** ក្នុង ការគ្រប់គ្រង ការផ្តល់ ការត្រួតពិនិត្យ និងការតាមដានការអនុវត្តលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ស្របតាមអនុក្រឹត្យនេះនិងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

### មាត្រា៦.-

បុគ្គលទាំងឡាយត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតដើម្បីបំពេញប្រតិបត្តិការទៅ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងករណីដែលទីតាំងនៃប្រតិបត្តិការស្ថិតក្នុងដែនសមត្ថកិច្ចនៃមន្ទីរនោះ ដូចតទៅ៖

ក- ការលក់គ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ ឧបករណ៍អេឡិកត្រូនិកដែលបំពាក់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬសូហ្វវែរ ដូចដែលមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ

ខ- ការរៀបចំព្រឹត្តិការណ៍ពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬ

គ- ប្រតិបត្តិការផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ទ.**។

### មាត្រា៧.-

បុគ្គលទាំងឡាយត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រដើម្បីបំពេញប្រតិបត្តិការទៅ **អ.ប.គ.ព.** ដូចតទៅ៖

ក- ការទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារនាំចូល ផ្គត់ផ្គង់ និង/ឬចែកចាយគ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ ឧបករណ៍អេឡិកត្រូនិកដែលបំពាក់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬសូហ្វវែរ

ខ- ការទទួលស្គាល់យថាប្រភេទនៃគ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ ឬឧបករណ៍អេឡិកត្រូនិកដែលបំពាក់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

គ- ការផលិត ការផ្គុំ ឬការដំឡើងគ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ ឧបករណ៍អេឡិកត្រូនិកដែលបំពាក់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬសូហ្វវែរ

ឃ- ការនាំចូល/នាំចេញ ឬការចែកចាយគ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ ឧបករណ៍អេឡិកត្រូនិកដែលបំពាក់បច្ចេក-វិទ្យាគមនាគមន៍និងព័ត៌មាន ឬសូហ្វវែរ

ង- សេវាអនឡាញ

ច- ការផ្តល់សេវាប្រឹក្សានិងសេវាបច្ចេកទេសផ្នែកបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានដោយយកកម្រៃ ឬ

ឆ- ប្រតិបត្តិការផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ឆ.**។

**មាត្រា៨ .-**

បុគ្គលទាំងឡាយត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណដើម្បីបំពេញប្រតិបត្តិការទៅ **អ.ប.ឥ.៧.** ដូចតទៅ៖

ក- ការផលិតឬការផ្គុំគ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ ឧបករណ៍អេឡិកត្រូនិកដែលបំពាក់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬសូហ្វវែរជាលក្ខណៈឧស្សាហកម្ម

ខ- ការបង្កើតនិងធ្វើអាជីវកម្មមជ្ឈមណ្ឌលទិន្នន័យ

គ- ការបង្កើតសួនឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬ

ឃ- ប្រតិបត្តិការផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ឆ.**។

## ជំពូកទី៣

## លក្ខខណ្ឌនៃការស្នើសុំនិងការផ្តល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

**មាត្រា៩ .-**

បុគ្គលដែលមានបំណងស្នើសុំលិខិតអនុញ្ញាត ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

ក- ជារូបវន្តបុគ្គលឬនីតិបុគ្គលស្ថិតក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង

ខ- លក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ឆ.**។

**មាត្រា១០ .-**

បុគ្គលដែលមានបំណងស្នើសុំវិញ្ញាបនបត្រឬអាជ្ញាបណ្ណ ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

ក- ជារូបវន្តបុគ្គលឬនីតិបុគ្គលស្ថិតក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា

ខ- មានបច្ចេកវិទ្យានិងធនធានមនុស្សគ្រប់គ្រាន់តាមប្រភេទនៃប្រតិបត្តិការ ស្របតាមការកំណត់របស់ **ក.ប.ឆ.** និង

គ- លក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ឆ.**។

**មាត្រា១១ .-**

បុគ្គលដែលមានបំណងស្នើសុំអាជ្ញាបណ្ណ ត្រូវបំពេញលក្ខខណ្ឌបន្ថែមដូចខាងក្រោម៖

ក- មានរចនាសម្ព័ន្ធគ្រប់គ្រងក្រុមហ៊ុនដែលកំណត់ច្បាស់លាស់ពីការទទួលខុសត្រូវ និងភារកិច្ចដែលអាចធានាបាននូវគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងអភិបាលកិច្ចសាជីវកម្មល្អ

ខ- មានគម្រោងវិនិយោគផ្នែកធុរកិច្ចនិងផ្នែកបច្ចេកទេសច្បាស់លាស់

គ-	តម្កល់ប្រាក់ធានា និងបង់កម្រៃសម្រាប់ដាក់ពាក្យស្នើសុំ ស្របតាមការកំណត់របស់ **ក.ប.ទ.** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង

ឃ-	លក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ទ.**។

## ជំពូកទី៤

## នីតិវិធីនៃការស្នើសុំនិងការផ្តល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

### ផ្នែកទី១

### នីតិវិធីនៃការស្នើសុំនិងការផ្តល់លិខិតអនុញ្ញាតនិងវិញ្ញាបនបត្រ

**មាត្រា១២ .-**

បុគ្គលដែលមានបំណងបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដូចមានកំណត់ក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវស្នើសុំមក **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ទៅតាមទម្រង់បែបបទ និងលក្ខខណ្ឌដែលកំណត់ដោយ **ក.ប.ទ.** ព្រមទាំងភ្ជាប់នូវឯកសារដូចខាងក្រោម៖

ក-	ពាក្យស្នើសុំលិខិតអនុញ្ញាត ដែលកំណត់ដោយ **ក.ប.ទ.**

ខ-	ឯកសារថតចម្លងបញ្ជាក់ពីអត្តសញ្ញាណរបស់បុគ្គលដាក់ពាក្យស្នើសុំ ដែលមានការបញ្ជាក់ភាពត្រឹមត្រូវតាមច្បាប់ដើមពីអាជ្ញាធរមានសមត្ថកិច្ច និង

គ-	ឯកសារឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ទ.**។

**មាត្រា១៣ .-**

បុគ្គលដែលមានបំណងធ្វើប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដូចមានកំណត់ក្នុងមាត្រា៧ នៃអនុក្រឹត្យនេះ ត្រូវស្នើសុំមក **អ.ប.គ.ព.** ទៅតាមទម្រង់បែបបទ និងលក្ខខណ្ឌដែលកំណត់ដោយ **ក.ប.ទ.** ព្រមទាំងភ្ជាប់នូវឯកសារដូចខាងក្រោម៖

ក-	ពាក្យស្នើសុំវិញ្ញាបនបត្រ ដែលកំណត់ដោយ **ក.ប.ទ.**

ខ-	ឯកសារថតចម្លងបញ្ជាក់ពីអត្តសញ្ញាណរបស់បុគ្គលដាក់ពាក្យស្នើសុំ ដែលមានការបញ្ជាក់ភាពត្រឹមត្រូវតាមច្បាប់ដើមពីអាជ្ញាធរមានសមត្ថកិច្ច និង

គ-	ឯកសារឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ទ.**។

**មាត្រា១៤ .-**

**អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវពិនិត្យពាក្យស្នើសុំនិងឯកសារគាំទ្រ ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានពាក្យស្នើសុំ។

**អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំផ្តល់នូវព័ត៌មានបន្ថែមតាមការចាំបាច់ និងអាចបដិសេធពិនិត្យពាក្យស្នើសុំនោះរហូតដល់បុគ្គលដាក់ពាក្យស្នើសុំបានផ្តល់ព័ត៌មានគ្រប់គ្រាន់។

**មាត្រា១៥ .-**

ក្រោយពីពិនិត្យឃើញថា បុគ្គលដាក់ពាក្យស្នើសុំបានបំពេញគ្រប់លក្ខខណ្ឌនិងមានឯកសារគាំទ្រត្រឹមត្រូវនិងពេញលេញ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវសម្រេចផ្តល់លិខិតអនុញ្ញាតឬវិញ្ញាបនបត្រជូនបុគ្គលដាក់ពាក្យស្នើសុំក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ។

**អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ អាចបដិសេធការផ្តល់លិខិតអនុញ្ញាតឬវិញ្ញាបនបត្រដល់បុគ្គលដាក់ពាក្យស្នើសុំ ដោយបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរ។ បុគ្គលដាក់ពាក្យស្នើសុំអាចតវ៉ាមក **គ.ប.ឆ.** ចំពោះសេចក្តីសម្រេចបដិសេធរបស់ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលសេចក្តីសម្រេចបដិសេធនេះ។ សេចក្តីសម្រេចរបស់ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវបិទផ្លូវតវ៉ា ក្នុងករណីដែលបុគ្គលដាក់ពាក្យស្នើសុំមិនបានតវ៉ាក្នុងរយៈពេលកំណត់នេះ។

ក្នុងករណីទទួលបានពាក្យស្នើសុំតវ៉ា **គ.ប.ឆ.** ត្រូវសម្រេចលើពាក្យស្នើសុំតវ៉ានេះ ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំតវ៉ា។ បុគ្គលដាក់ពាក្យស្នើសុំតវ៉ាអាចប្តឹងទៅតុលាការមានសមត្ថកិច្ចលើការសម្រេចរបស់ **គ.ប.ឆ.** ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីថ្ងៃទទួលសេចក្តីសម្រេចលើពាក្យស្នើសុំតវ៉ា។ ការសម្រេចរបស់ **គ.ប.ឆ.** ត្រូវបិទផ្លូវតវ៉ា ក្នុងករណីដែលបុគ្គលដាក់ពាក្យស្នើសុំតវ៉ាមិនបានដាក់ពាក្យបណ្តឹងក្នុងរយៈពេលកំណត់នេះ។

**មាត្រា១៦ .-**

បុគ្គលដែលមានបំណងធ្វើប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដូចមានកំណត់ក្នុងមាត្រា៦ និងមាត្រា៧ នៃអនុក្រឹត្យនេះ ក្រោយទទួលបានលិខិតអនុញ្ញាតឬវិញ្ញាបនបត្រ តទៅហៅថា "**បុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន**"។

លិខិតអនុញ្ញាតមានសុពលភាព ០២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត លើកលែងតែចំណុច (ខ) នៃមាត្រា៦ នៃអនុក្រឹត្យនេះ។

វិញ្ញាបនបត្រមានសុពលភាព ០៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រ។

លិខិតអនុញ្ញាតឬវិញ្ញាបនបត្រអាចបន្តសាជាថ្មីបាន លុះណាតែបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន បានដាក់ពាក្យស្នើសុំបន្តទៅ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងអំឡុងពេលយ៉ាងតិច ៣០ (សាមសិប) ថ្ងៃមុនពេលអស់សុពលភាព។ ទម្រង់នៃពាក្យស្នើសុំបន្តលិខិតអនុញ្ញាតឬវិញ្ញាបនបត្រ ត្រូវកំណត់ដោយ **គ.ប.ឆ.**។

ក្នុងករណីខកខានមិនបានដាក់ពាក្យស្នើសុំបន្តក្នុងអំឡុងពេលដូចកំណត់ក្នុងកថាខណ្ឌទី២ ខាងលើ បុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានត្រូវស្នើសុំលិខិតអនុញ្ញាតឬវិញ្ញាបនបត្រជាថ្មី ស្របតាមលក្ខខណ្ឌ និងនីតិវិធីនៃការស្នើសុំនិងការផ្តល់លិខិតអនុញ្ញាតនិងវិញ្ញាបនបត្រ ដែលកំណត់ក្នុងអនុក្រឹត្យនេះ។

## ផ្នែកទី២
## នីតិវិធីនៃការស្នើសុំនិងការផ្តល់អាជ្ញាបណ្ណ

**មាត្រា១៧ .-**

បុគ្គលដែលមានបំណងធ្វើប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដូចមានកំណត់ក្នុងមាត្រា៨ នៃអនុក្រឹត្យនេះ ត្រូវស្នើសុំមក **អ.ប.គ.ព.** ទៅតាមទម្រង់បែបបទនិងលក្ខខណ្ឌដែលកំណត់ដោយ **គ.ប.ឆ.** ព្រមទាំងភ្ជាប់នូវឯកសារដូចខាងក្រោម៖

ក- ពាក្យស្នើសុំអាជ្ញាបណ្ណ ដែលកំណត់ដោយ **ក.ប.ទ.**

ខ- គម្រោងវិនិយោគផ្នែកធុរកិច្ចនិងផ្នែកបច្ចេកទេសសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ ដោយរួមបញ្ចូលទាំងកាលបរិច្ឆេទចាប់ផ្តើមធ្វើប្រតិបត្តិការនិងសកម្មភាពដែលពាក់ព័ន្ធផ្សេងៗ

គ- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិងលក្ខន្តិកៈក្រុមហ៊ុន

ឃ- ព័ត៌មានអំពីរចនាសម្ព័ន្ធម្ចាស់ហ៊ុន ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងនៃបុគ្គលដាក់ពាក្យស្នើសុំ

ង- ឯកសារថតចម្លងបញ្ជាក់ពីអត្តសញ្ញាណរបស់បុគ្គលដាក់ពាក្យស្នើសុំ ដែលមានការបញ្ជាក់ភាពត្រឹមត្រូវតាមច្បាប់ដើមពីអាជ្ញាធរមានសមត្ថកិច្ច និង

ច- ឯកសារឬព័ត៌មានផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ទ.**។

**មាត្រា១៨ .-**

**អ.ប.គ.ព.** ត្រូវពិនិត្យពាក្យស្នើសុំនិងឯកសារគាំទ្រផ្សេងៗទៀត ក្នុងរយៈពេលមិនលើសពី ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានពាក្យស្នើសុំអាជ្ញាបណ្ណ។

**អ.ប.គ.ព.** អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំផ្តល់នូវព័ត៌មានបន្ថែមតាមការចាំបាច់ និងអាចបដិសេធពិនិត្យពាក្យស្នើសុំនោះរហូតដល់បុគ្គលដាក់ពាក្យស្នើសុំបានផ្តល់ព័ត៌មានគ្រប់គ្រាន់។

**មាត្រា១៩ .-**

ក្រោយពីពិនិត្យឃើញថា បុគ្គលដាក់ពាក្យស្នើសុំបានបំពេញគ្រប់លក្ខខណ្ឌនិងមានឯកសារភ្ជាប់ត្រឹមត្រូវនិងពេញលេញ **អ.ប.គ.ព.** ត្រូវស្នើសុំគោលការណ៍ពីរដ្ឋមន្ត្រី **ក.ប.ទ.** ដើម្បីចេញអាជ្ញាបណ្ណ ដល់បុគ្គលដាក់ពាក្យស្នើសុំ ក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ។

**អ.ប.គ.ព.** អាចស្នើសុំគោលការណ៍ពីរដ្ឋមន្ត្រី **ក.ប.ទ.** ដើម្បីចេញសេចក្តីសម្រេចបដិសេធការផ្តល់អាជ្ញាបណ្ណ ដល់បុគ្គលដាក់ពាក្យស្នើសុំ ដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់។ បុគ្គលដាក់ពាក្យស្នើសុំអាចតវ៉ាមក **ក.ប.ទ.** ចំពោះសេចក្តីសម្រេចបដិសេធក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលសេចក្តីសម្រេចបដិសេធនេះ។ សេចក្តីសម្រេចបដិសេធត្រូវបិទផ្លូវតវ៉ា ក្នុងករណីដែលបុគ្គលដាក់ពាក្យស្នើសុំមិនបានតវ៉ាក្នុងរយៈពេលកំណត់នេះ។

ក្នុងករណីទទួលបានពាក្យស្នើសុំតវ៉ា **ក.ប.ទ.** ត្រូវសម្រេចលើពាក្យស្នើសុំតវ៉ានេះ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំតវ៉ា។ បុគ្គលដាក់ពាក្យស្នើសុំតវ៉ាអាចប្តឹងទៅតុលាការមានសមត្ថកិច្ចលើការសម្រេចរបស់ **ក.ប.ទ.** ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្តីសម្រេចលើពាក្យស្នើសុំតវ៉ា។ ការសម្រេចរបស់ **ក.ប.ទ.** ត្រូវបិទផ្លូវតវ៉ា ក្នុងករណីដែលបុគ្គលដាក់ពាក្យស្នើសុំតវ៉ាមិនបានដាក់ពាក្យបណ្តឹងក្នុងរយៈពេលកំណត់នេះ។

**មាត្រា២០ .-**

បុគ្គលដែលមានបំណងធ្វើប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដូចមានកំណត់ក្នុង មាត្រា៨ នៃអនុក្រឹត្យនេះ ក្រោយទទួលបានអាជ្ញាបណ្ណ តទៅហៅថា "**ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន**"។

អាជ្ញាបណ្ណមានសុពលភាព ១៥ (ដប់ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណ។

អាជ្ញាបណ្ណអាចបន្តសាជាថ្មីបាន លុះណាតែប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានបានដាក់ពាក្យស្នើសុំបន្តមក **អ.ប.គ.ព.** ក្នុងអំឡុងពេលយ៉ាងតិច ០៦ (ប្រាំមួយ) ខែ មុនពេលអស់សុពលភាព។ ទម្រង់នៃពាក្យស្នើសុំបន្តអាជ្ញាបណ្ណ ត្រូវកំណត់ដោយ **គ.ប.ធ.**។

ក្នុងករណីខកខានមិនបានជូនដំណឹងក្នុងអំឡុងពេលដូចកំណត់ក្នុងកថាខណ្ឌទី២ ខាងលើ ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានត្រូវស្នើសុំអាជ្ញាបណ្ណជាថ្មី ស្របតាមលក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំនិងការផ្តល់អាជ្ញាបណ្ណដែលកំណត់ក្នុងអនុក្រឹត្យនេះ។

## ជំពូកទី៥
## ការព្យួរនិងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ
### ផ្នែកទី១
### មូលហេតុនៃការព្យួរនិងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ

**មាត្រា២១.-**

លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ត្រូវបានព្យួរក្នុងករណីណាមួយដូចខាងក្រោម៖

ក- ការស្នើសុំពីប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ខ- សេចក្តីត្រូវការដាក់ស្ពែងទាក់ទងនឹងការរក្សាសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ និងការពារជាតិ

គ- ការខកខានមិនបានបង់កម្រៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ក្នុងរយៈពេល ០៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទត្រូវបង់

ឃ- ការខកខានបំពេញកាតព្វកិច្ចរបស់ខ្លួនណាមួយដែលកំណត់ក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ទោះបីជាបានទទួលលិខិតជូនដំណឹងជាបន្តបន្ទាប់គ្នាចំនួន ០៣ (បី) លើកពី **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍

ង- ស្ថានភាពបច្ចេកទេសឬហិរញ្ញវត្ថុទន់ខ្សោយឬការចាប់ផ្តើមបើកនីតិវិធីក្ស័យធន ស្របតាមការសម្រេចរបស់តុលាការ ឬ

ច- មូលហេតុផ្សេងទៀតដែលកំណត់ដោយអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**មាត្រា២២.-**

លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ត្រូវបានដកហូតក្នុងករណីណាមួយដូចខាងក្រោម៖

ក- ការព្យួរលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ លើសពីរយៈពេល ០១ (មួយ) ឆ្នាំ

ខ- ប្រតិបត្តិការប៉ះពាល់អវិជ្ជមានដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ និងការពារជាតិ

គ- ការទទួលបានលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ដោយក្លែងឯកសារឬព័ត៌មាន

ឃ- ការបន្តធ្វើប្រតិបត្តិការក្នុងអំឡុងពេលព្យួរលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ

ង- ត្រូវបានប្រកាសក្ស័យធនដោយតុលាការ ឬ

ច- មូលហេតុផ្សេងទៀតដែលកំណត់ដោយអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

## ជំពូកទី២
## នីតិវិធីនៃការព្យួរនិងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ

**មាត្រា២៣.-**

ក្រោយពិនិត្យឃើញថា មានមូលហេតុណាមួយដូចបានកំណត់ក្នុងមាត្រា២១ ឬមាត្រា២២ នៃអនុក្រឹត្យនេះ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ អាចសម្រេចព្យួរឬដកហូតលិខិតអនុញ្ញាតឬវិញ្ញាបនបត្រ។

**អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ អាចព្យួរឬដកហូតលិខិតអនុញ្ញាត ឬវិញ្ញាបនបត្ររបស់បុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដោយបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរ។

លិខិតអនុញ្ញាតឬវិញ្ញាបនបត្រ អាចត្រូវបានព្យួរសម្រាប់រយៈពេល ០៦ (ប្រាំមួយ) ខែ ហើយអាចពន្យារពេលនៃការព្យួរនេះរហូតដល់ ០១ (មួយ) ឆ្នាំ។ ហួសពីរយៈពេលនេះ លិខិតអនុញ្ញាតឬវិញ្ញាបនបត្រ ត្រូវក្លាយជាកម្មវត្ថុនៃការដកហូត។

បុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានអាចតវ៉ាមក **ក.ប.ឆ.** ចំពោះសេចក្តីសម្រេចរបស់ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលសេចក្តីសម្រេចនេះ។ សេចក្តីសម្រេចរបស់ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវបិទផ្លូវតវ៉ាក្នុងករណីដែលបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានមិនបានតវ៉ាក្នុងរយៈពេលកំណត់នេះ។

ក្នុងករណីទទួលបានពាក្យស្នើសុំតវ៉ា **ក.ប.ឆ.** ត្រូវសម្រេចលើពាក្យស្នើសុំតវ៉ានេះ ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំតវ៉ា។ បុគ្គលដាក់ពាក្យស្នើសុំតវ៉ាអាចប្តឹងទៅតុលាការមានសមត្ថកិច្ចលើការសម្រេចរបស់ **ក.ប.ឆ.** ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្តីសម្រេចលើពាក្យស្នើសុំតវ៉ា។ ការសម្រេចរបស់ **ក.ប.ឆ.** ត្រូវបិទផ្លូវតវ៉ា ក្នុងករណីដែលបុគ្គលដាក់ពាក្យស្នើសុំតវ៉ាមិនបានដាក់ពាក្យបណ្តឹងក្នុងរយៈពេលកំណត់នេះ។

**មាត្រា២៤.-**

ក្រោយពីពិនិត្យឃើញថា មានមូលហេតុណាមួយដូចបានកំណត់ក្នុងមាត្រា២១ និងមាត្រា២២ នៃអនុក្រឹត្យនេះ **ក.ប.ឆ.** អាចសម្រេចព្យួរឬដកហូតអាជ្ញាបណ្ណ។

**ក.ប.ឆ.** អាចព្យួរឬដកហូតអាជ្ញាបណ្ណរបស់ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដោយបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរ។

អាជ្ញាបណ្ណអាចត្រូវបានព្យួរសម្រាប់រយៈពេល ០៦ (ប្រាំមួយ) ខែ ហើយអាចពន្យារហូតដល់ ០១ (មួយ) ឆ្នាំ។ ហួសពីរយៈពេលនេះ អាជ្ញាបណ្ណ ត្រូវក្លាយជាកម្មវត្ថុនៃការដកហូត។

ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានអាចតវ៉ាមក **ក.ប.ឆ.** ចំពោះសេចក្តីសម្រេចព្យួរឬដកហូតអាជ្ញាបណ្ណ ក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលសេចក្តីសម្រេចនេះ។ សេចក្តីសម្រេចរបស់ **ក.ប.ឆ.** ត្រូវបិទផ្លូវតវ៉ា ក្នុងករណីដែលប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានមិនបានតវ៉ាក្នុងរយៈពេលកំណត់នេះ។

ក្នុងករណីទទួលបានពាក្យស្នើសុំតវ៉ា **គ.ម.ឆ.** ត្រូវសម្រេចលើពាក្យស្នើសុំតវ៉ានេះ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំតវ៉ា។ បុគ្គលដាក់ពាក្យស្នើសុំតវ៉ាអាចប្ដឹងទៅតុលាការមានសមត្ថកិច្ចលើការសម្រេចរបស់ **គ.ម.ឆ.** ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្ដីសម្រេចលើពាក្យស្នើសុំតវ៉ា។ ការសម្រេចរបស់ **គ.ម.ឆ.** ត្រូវបិទផ្លូវតវ៉ា ក្នុងករណីដែលបុគ្គលដាក់ពាក្យស្នើសុំតវ៉ាមិនបានដាក់ពាក្យបណ្ដឹងក្នុងរយៈពេលកំណត់នេះ។

## ជំពូកទី៦

## ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការដាក់ប្រាតិភោគ

**មាត្រា២៥.-**

ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការដាក់ប្រាតិភោគនូវសិទ្ធិដែលកំណត់ក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការដាក់ប្រាតិភោគនូវសិទ្ធិដែលកំណត់ក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ត្រូវគោរពតាមនីតិវិធីដូចគ្នាទៅនឹងការផ្ដល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ និងនីតិវិធីដែលមានចែងក្នុងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

ក្នុងករណីប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន មានបំណងចង់បញ្ឈប់ប្រតិបត្តិការរបស់ខ្លួន ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននោះ ត្រូវជូនព័ត៌មានជាលាយលក្ខណ៍អក្សរទៅ **អ.ម.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ចំពោះលិខិតអនុញ្ញាត យ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនបញ្ចប់ប្រតិបត្តិការដោយបញ្ជាក់អំពីមូលហេតុនៃការបញ្ចប់ប្រតិបត្តិការ។

**គ.ម.ឆ.** អាចតម្រូវឱ្យប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន អនុវត្តកាតព្វកិច្ចមួយឬច្រើន មុននឹងបញ្ឈប់ប្រតិបត្តិការរបស់ខ្លួន។

## ជំពូកទី៧

## សិទ្ធិនិងកាតព្វកិច្ចរបស់ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

**មាត្រា២៦.-**

ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន មានសិទ្ធិដូចខាងក្រោម៖

ក- ធ្វើប្រតិបត្តិការដែលបានស្នើសុំ

ខ- ដាក់ប្រាតិភោគនូវសិទ្ធិដែលកំណត់ក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ

គ- ស្នើសុំព្យួរលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ

ឃ- ស្នើសុំកែប្រែគម្រោងវិនិយោគផ្នែកធុរកិច្ចនិងផ្នែកបច្ចេកទេស និង

ង-  សិទ្ធិផ្សេងទៀតដែលកំណត់ក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**មាត្រា២៧.-**

ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន មានកាតព្វកិច្ចដូចខាងក្រោម៖

ក-  អនុវត្តទៅតាមលក្ខខណ្ឌទាំងឡាយដែលត្រូវបានកំណត់នៅក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ និងអនុក្រឹត្យនេះនិងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត

ខ-  បង់កម្រៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ និង/ឬកម្រៃផ្សេងទៀត

គ-  ផ្តល់ព័ត៌មានអំពីការផ្លាស់ប្តូរទីតាំង មក **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍

ឃ-  ផ្តល់ព័ត៌មានអំពីការបញ្ឈប់ប្រតិបត្តិការ មក **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍

ង-  ផ្តល់ទិន្នន័យនិងស្ថិតិពាក់ព័ន្ធនឹងប្រតិបត្តិការនិងហិរញ្ញវត្ថុ

ច-  ការពារព័ត៌មានឯកជន សន្តិសុខ និងសុវត្ថិភាពនៃការប្រើប្រាស់សេវាបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ឆ-  បំពេញប្រតិបត្តិការស្របតាមគោលការណ៍ប្រកួតប្រជែងដោយស្មោះត្រង់ សេរី ស្មើភាព និងប្រកបដោយប្រសិទ្ធភាព

ជ-  ចូលរួមអនុវត្តតាមការណែនាំរបស់ **គ.ប.ទ.**

ឈ-  ហាមបើកអាជីវកម្មដែលមានលក្ខណៈខុសច្បាប់

ញ-  កាតព្វកិច្ចផ្សេងទៀតតាមការកំណត់របស់ **គ.ប.ទ.**។

បន្ថែមលើកាតព្វកិច្ចដែលបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានត្រូវផ្តល់ឯកសារអំពីការគ្រប់គ្រងថ្លៃដើម របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ដោយសវនករឯករាជ្យដែលទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងព័ត៌មានពុំមែនហិរញ្ញវត្ថុ ជារៀងរាល់ឆ្នាំសារពើពន្ធ មក **គ.ប.ទ.**។

**មាត្រា២៨.-**

កម្រៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ និង/ឬកម្រៃផ្សេងទៀត និងនីតិវិធីនៃការបង់កម្រៃ ត្រូវកំណត់ដោយប្រកាសរួមរវាង **គ.ប.ទ.** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៨

## ទោសប្បញ្ញត្តិ

**មាត្រា២៩.-**

ក្រោយពេលផ្តល់វិញ្ញាបនបត្រឬអាជ្ញាបណ្ណក្រោមអនុក្រឹត្យនេះ ប្រសិនបើពិនិត្យឃើញថាប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន មិនអនុវត្តតាមលក្ខខណ្ឌណាមួយនៃវិញ្ញាបនបត្រឬអាជ្ញាបណ្ណ ឬលក្ខខណ្ឌណាមួយដែលកំណត់ដោយអនុក្រឹត្យនេះ ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត **គ.ប.ទ.** អាចចាត់វិធានការជាអាទិ៍ ដូចខាងក្រោម៖

ក-  ដឹកនាំកែតម្រូវប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឱ្យអនុវត្តតាមលក្ខខណ្ឌឬលក្ខខណ្ឌបន្ថែម

ខ-  បង្អាក់ការនាំចេញឬការនាំចូលគ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ ឬឧបករណ៍អេឡិកត្រូនិកដែលប់ពាក់ព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

គ- បង្កកគណនីរបស់ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ឃ- ដាក់កំហិតលើវិញ្ញាបនបត្រឬអាជ្ញាបណ្ណ

ង- ព្យួរវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណរហូតដល់ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន គោរពពេញលេញតាមលក្ខខណ្ឌ ឬលក្ខខណ្ឌបន្ថែម

ច- ជ្រើសរើសនិងផ្តល់អំណាចដល់បុគ្គលដែលមានសមត្ថកិច្ចសមស្រប ដើម្បីពិនិត្យមើលសកម្មភាពអាជីវកម្ម ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតរបស់ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។ បុគ្គលនោះត្រូវធ្វើរបាយការណ៍ទៅ **ន.ប.ទ.** តាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាជាមួយ **ន.ប.ទ.**

ឆ- ដាក់កំហិត ឬបញ្ឈប់សកម្មភាពជាក់លាក់ ឬទូទៅរបស់ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ទោះបីសកម្មភាពភាពទាំងនោះបានធ្វើឡើងស្រប ឬមិនស្របតាមលក្ខខណ្ឌនៃវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណក៏ដោយ

ជ- ចាត់វិធានការផ្សេងទៀតតាមការចាំបាច់ ស្របតាមការកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**ន.ប.ទ.** អាចចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី១ លុះត្រាតែបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានអំពីមូលហេតុនៃការចាត់វិធានការនេះ និងបានផ្តល់ឱកាសឱ្យប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានធ្វើការពន្យល់។

**មាត្រា៣០.-**

ការពិន័យអន្តរការណ៍ចំពោះបទល្មើសក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ជាសមត្ថកិច្ចរបស់ **ន.ប.ទ.**។

**មាត្រា៣១.-**

ត្រូវពិន័យអន្តរការណ៍ ចំពោះការធ្វើប្រតិបត្តិការដូចមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ ដោយគ្មានលិខិតអនុញ្ញាតពី **អ.ប.ត.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ ចំនួនទឹកប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៣ ០០០ ០០០ (បីលាន) រៀល។
- នីតិបុគ្គល៖ ចំនួនទឹកប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១៥ ០០០ ០០០ (ដប់ប្រាំលាន) រៀល។

**មាត្រា៣២.-**

ត្រូវពិន័យអន្តរការណ៍ ចំពោះការធ្វើប្រតិបត្តិការដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យនេះ ដោយគ្មានវិញ្ញាបនបត្រពី **អ.ប.ត.ព.** ដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ ចំនួនទឹកប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល។
- នីតិបុគ្គល៖ ចំនួនទឹកប្រាក់ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ ៦០ ០០០ ០០០ (ហុកសិបលាន) រៀល។

**មាត្រា៣៣ .-**

ការធ្វើប្រតិបត្តិការដូចមានចែងក្នុងមាត្រា៨ នៃអនុក្រឹត្យនេះ ដោយគ្មានអាជ្ញាបណ្ណពី **ក.ប.ទ.** ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ ចំនួនទឹកប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១៥ ០០០ ០០០ (ដប់ប្រាំលាន) រៀល។
- នីតិបុគ្គល៖ ចំនួនទឹកប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ ១៥០ ០០០ ០០០ (មួយរយហាសិបលាន) រៀល។

**មាត្រា៣៤ .-**

ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដែលមិនបានផ្តល់ឯកសារអំពីការគ្រប់គ្រងថ្លៃដើម របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ព្រមទាំងព័ត៌មានពុំមែនហិរញ្ញវត្ថុ មក **ក.ប.ទ.** ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ ដូចមានកំណត់ក្នុងមាត្រា២៧ នៃអនុក្រឹត្យនេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ ៦០ ០០០ ០០០ (ហុកសិបលាន) រៀល។

**មាត្រា៣៥ .-**

បុគ្គលដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៣១ មាត្រា៣២ មាត្រា៣៣ និងមាត្រា៣៤ នៃអនុក្រឹត្យនេះ ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃដែលបានទទួលសេចក្តីសម្រេចពិន័យ។

ក្នុងករណីជនល្មើស មិនបានបង់ប្រាក់ពិន័យតាមការកំណត់ដូចកថាខណ្ឌទី១ ខាងលើ **ក.ប.ទ.** ត្រូវរៀបចំសំណុំឯកសារបញ្ជូនទៅអយ្យការអមសាលាដំបូង។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការពិន័យអន្តរការណ៍ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.** ។

## ជំពូកទី៩
## អន្តរប្បញ្ញត្តិ

**មាត្រា៣៦ .-**

ក្នុងរយៈពេល០១ (មួយ) ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទចុះហត្ថលេខាលើអនុក្រឹត្យនេះ បុគ្គលដែលកំពុងបំពេញប្រតិបត្តិការ លើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានទាំងអស់ ត្រូវមកបំពេញទម្រង់បែបបទនៅ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីសុំការអនុញ្ញាតស្របតាមលក្ខខណ្ឌទាំងឡាយនៃអនុក្រឹត្យនេះ ព្រមទាំងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

**មាត្រា៣៧ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣៨ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធភ្ជាប់អនុក្រឹត្យលេខ១១០ អនក្រ.បក ចុះថ្ងៃទី ២១.. ខែកក្កដា ឆ្នាំ២០១៧

## គ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកដែលបំពាក់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

| ល.រ | ប្រភេទនៃឧបករណ៍ (Type) |
|---|---|
| ១ | Computer |
| ២ | Keyboard |
| ៣ | MIDI Keyboard |
| ៤ | Mouse |
| ៥ | Motherboard |
| ៦ | Joystick |
| ៧ | Game Pad |
| ៨ | Scanner |
| ៩ | Printer |
| ១០ | Photocopy machine |
| ១១ | Microphone |
| ១២ | Speaker |
| ១៣ | Analog/ Digital/ IP Camera |
| ១៤ | Camcorder |
| ១៥ | Monitor/ Touch Screen |
| ១៦ | LCD/ LED Projector and LED Display |
| ១៧ | Smart TV |
| ១៨ | Internal/ External Hard drive |
| ១៩ | Floppy Disk/ CD/ DVD Reader/ Writer |
| ២០ | Memory Stick, Flash Drive... |
| ២១ | Media Card Reader |
| ២២ | PCI / PCI Express/ AGP Card |
| ២៣ | Open Hardware/ SDR Device |
| ២៤ | Hub, Switch, Router, Firewall |

២៥ Tracking Device ( GPS, Beacon, Smart Tag )

២៦ Electronic Lock, Smart Key...

២៧ Alarm Security Devices for Intrusion, Fire, CCTV

២៨ House Appliance Remote Control

២៩ Storage ( NAS, SAN .. etc )

៣០ POS and ATM Machine

៣១ Video Conference Equipment

៣២ Test Equipment such as Multimeter, Function Generator, Oscilloscope, Data Logger...

៣៣ IP STB/ Android STB/ Apple TV Box

៣៤ DVR, NVR ..

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

# គោលនយោបាយ និង យុទ្ធសាស្ត្រប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ក្នុងការអប់រំនៅកម្ពុជា



ឆ្នាំ ២០០៤

# មាតិការឿង


អារម្ភកថា ---------------------------- ៣

ចក្ខុវិស័យ ---------------------------- ៥

គោលបំណង ---------------------------- ៥

គោលនយោបាយចំពោះបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍នៅក្នុងការអប់រំ ៦

១- សាវតារ ---------------------------- ៧

២- ការវិភាគស្ថានភាព ---------------------------- ៨

២.១- កំរិតទទួលបាន និងកំរិតប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ក្នុងពេលបច្ចុប្បន្ន ---------------- ៨

២.២- អាំងឌីកាទ័រអប់រំ ---------------------------- ៩

២.៣- ស្ថានភាពបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ក្នុងការអប់រំ នាពេលបច្ចុប្បន្ន ---------------------------- ១០

២.៣.១- ការអភិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន ---------------- ១១

២.៣.២- បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍នៅក្នុងឧត្តមសិក្សា -- ១៣

២.៣.៣- ការអប់រំក្រៅប្រព័ន្ធ និង ការអប់រំពីចម្ងាយ ----------- ១៣

២.៤- ការត្រៀមលក្ខណៈបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ នៅតាមសាលារៀន ---------------------------- ១៤

៣- យុទ្ធសាស្ត្រលើកកំពស់ការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ក្នុងការអប់រំ ---------------- ១៤

៣.១- គោលដៅរយៈពេលមធ្យម -------------------- ១៤

៣.២- យុទ្ធសាស្ត្ររយៈពេលមធ្យម ---------------- ១៦

៤- ផែនការសកម្មភាព ---------------------------- ២២

**ឧបសម្ព័ន្ធទី១ :**

ចំនួនសិស្សរៀនពេញម៉ោងនៅក្នុងប្រទេសកម្ពុជា - - - - - - ២៣

**ឧបសម្ព័ន្ធទី២ :**

ផលធៀបគរុសិស្ស-កុំព្យូទ័រនៅកម្ពុជា ឆ្នាំ ២០០៤ - - - - - ២៣

**ឧបសម្ព័ន្ធទី៣ :**

ស្ថានភាពប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអេឡិចត្រូនិច និង ប្រព័ន្ធ

ផ្សព្វផ្សាយព័ត៌មានបោះពុម្ព នៅក្នុងប្រទេសកម្ពុជា - - - - - ២៤

# អារម្ភកថា

គោលនយោបាយ យុទ្ធសាស្ត្របច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ក្នុងវិស័យអប់រំនៅកម្ពុជា បានបង្ហាញពីដំណាក់កាលមួយនៃការងារសំខាន់របស់ក្រសួងអប់រំ យុវជន និង កីឡា ក្នុងការធ្វើកំណែទំរង់សេវាអប់រំនៅកម្ពុជាអោយមានប្រសិទ្ធភាពខ្ពស់ និង ឈានចូលទៅរកបរិបទថ្មីនៃសាកលភាវូបនីយកម្ម ។ គោលនយោបាយ យុទ្ធសាស្ត្របច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ក្នុងវិស័យអប់រំនៅកម្ពុជានេះ គឺជាសមិទ្ធផលសំរេចបានពីវេទិកាពិភាក្សាពិគ្រោះយោបល់ជាមួយអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អង្គការអន្តរជាតិនានាជាបន្តបន្ទាប់ ទាំងនៅក្នុងប្រទេស និង ក្នុងតំបន់ ព្រមទាំងឆន្ទៈ និង ការខិតខំប្រឹងប្រែងរបស់មន្ត្រីបច្ចេកទេសជាន់ខ្ពស់នៃក្រសួងអប់រំ យុវជន និង កីឡា ។

គោលនយោបាយ យុទ្ធសាស្ត្របច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ក្នុងវិស័យអប់រំនៅកម្ពុជា ជាមាគ៌ាដ៏ត្រឹមត្រូវស្របតាមនិន្នាការពិភពលោកដែលជាយុទ្ធសាស្ត្រ និង ជាចំណុចដៅរបស់ផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា ។ គោលនយោបាយ និង យុទ្ធសាស្ត្រនេះក៏សង្កត់ធ្ងន់ផងដែរលើការពង្រឹងការងារអប់រំក្រៅប្រព័ន្ធ ការសិក្សាពីចម្ងាយ ការបណ្តុះបណ្តាលជំនាញ ការបង្កើនគុណភាពអប់រំនៅមធ្យមសិក្សាទុតិយភូមិ និង ក្រោយមធ្យមសិក្សាតាមរយៈ បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ដែលជាតំរូវការក្នុងការបំពេញអាជីពនៅក្នុងសង្គមផ្អែកលើពុទ្ធិ និង ការកសាងភាពជាដៃគូអោយបានល្អរវាងស្ថាប័នរាជរដ្ឋាភិបាល សហគមន៍ វិស័យឯកជន អង្គការជាតិ និង អង្គការអន្តរជាតិដែលពាក់ព័ន្ធ ។

គោលនយោបាយ យុទ្ធសាស្ត្របច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ បានបញ្ជាក់ច្បាស់អំពីការជួយគាំទ្រ និង លើកកំពស់ការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មានសំរាប់ជនជួបការលំបាក ។ ឯកសារស្តីពីផែនការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ៥ឆ្នាំ លើកទី២ គោលដៅអភិវឌ្ឍសហស្សវត្ស និង ឯកសារផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៤-០៨ សុទ្ធតែបានផ្តល់នូវគំនិតសំខាន់ៗ និង ការណែនាំជាច្រើន សំរាប់ការរៀបចំការកសាងគោលនយោបាយ និង យុទ្ធសាស្ត្រនេះ ដើម្បីធានាបានការលើកទឹកចិត្ត និង ការបណ្តុះបណ្តាលមន្ត្រីអប់រំអោយមានជំនាញជាក់លាក់ ។

ជាទីបញ្ចប់ក្រសួងអប់រំ  យុវជន  និង កីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះមន្ត្រីជំនាញរបស់ក្រសួងអប់រំ  យុវជន  និង  កីឡា  អ្នកបច្ចេកទេស  ស្ថាប័ន រាជរដ្ឋាភិបាលពាក់ព័ន្ធ អង្គការស៊ីវិល និង ឯកជន ដែលបានចូលរួមចំណែកយ៉ាងធំធេង ក្នុងការកសាងគោលនយោបាយ យុទ្ធសាស្ត្របច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ។ ជាពិសេសនោះ ក្រសួងសូមថ្លែងនូវការកោតសរសើរ និង កតញ្ញូតាធមិយ៉ាងខ្ពង់ខ្ពស់ចំពោះ អង្គការ UNESCO ដែលបានផ្តល់ជំនួយបច្ចេកទេស និង ហិរញ្ញវត្ថុ ដោយបានសហការ យ៉ាងល្អពិសេស  ជាមួយអ្នកបច្ចេកទេសរបស់ក្រសួង  ក្នុងកិច្ចការធ្វើអោយសំរេច គោលនយោបាយ និង យុទ្ធសាស្ត្រដ៏មានប្រយោជន៍ចំពោះកុលបុត្រកុលធីតាខ្មែរ ។

ក្រសួងអប់រំ  យុវជន  និង  កីឡា  សង្ឃឹមយ៉ាងមុតមាំថា  គោលនយោបាយ យុទ្ធសាស្ត្រប្រើប្រាស់បច្ចេកវិទ្យា  ព័ត៌មាន  និង  សារគមនាគមន៍នេះ  នឹងរួមចំណែក អភិវឌ្ឍធនធានមនុស្សនៅកម្ពុជាប្រកបដោយគុណភាព ។

**ភ្នំពេញ,ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥**

**ទេសរដ្ឋមន្ត្រី  រដ្ឋមន្ត្រីក្រសួងអប់រំ  យុវជន  និង  កីឡា**

**បណ្ឌិត  កុល  ផេង**

# ចក្ខុវិស័យ

ចក្ខុវិស័យរយៈពេលវែង សំរាប់ការអប់រំសំរាប់ទាំងអស់គ្នានៅកម្ពុជា គឺការធានាការអប់រំប្រជាពលរដ្ឋគ្រប់រូប អោយទទួលបានដោយស្មើភាពនូវការអប់រំមូលដ្ឋានប្រកបដោយគុណភាព ព្រមទាំងត្រៀមលក្ខណៈជូនប្រជាពលរដ្ឋទាំងនោះអោយបំពេញតួនាទីដ៏សកម្មមួយនៅក្នុងការកសាងប្រទេសជាតិខ្លួនឡើងវិញ សំដៅធ្វើសមាហរណកម្មកម្ពុជាទៅក្នុងសហគមន៍សកលលោកផ្អែកលើពុទ្ធិ ។

ក្រសួងអប់រំ យុវជន និង កីឡា កំពុងតែផ្តួចផ្តើមបញ្ចូលការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និង សារគមនាគមន៍អោយកាន់តែទូលំទូលាយ ក្នុងគោលបំណងលើកកំពស់ប្រសិទ្ធភាពនៃការអប់រំសំរាប់ទាំងអស់គ្នានៅគ្រប់កំរិតសិក្សា ដើម្បីកសាងកំលាំងពលករជាអក្ខរជនបច្ចេកវិទ្យា ដែលសកម្មផលិត និង មានសមត្ថភាពវិភាគពិចារណាជូនជាតិ ។

# គោលបំណង

- លើកកំពស់ការចូលសិក្សានៅកំរិតអប់រំមូលដ្ឋាន សំរាប់ទាំងអស់គ្នាទាំងក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ ដោយប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ជាឧបករណ៍មួយនៅក្នុងចំណោមឧបករណ៍សំខាន់ៗសំរាប់រៀន សំរាប់ការបង្រៀន សំរាប់ការសិក្សាស្រាវជ្រាវ និង សំរាប់ចែករំលែកព័ត៌មាន ។
- លើកកំពស់គុណភាពអប់រំមូលដ្ឋានអោយបានប្រសើរជាងមុន ដោយជំរុញការរៀនដោយខ្លួនឯងពេញមួយជីវិត ជាពិសេសនៅកំរិតក្រោយបឋមសិក្សា ។
- បង្កើនសមត្ថភាពភ្ជាប់ទំនាក់ទំនងជាមួយពិភពលោក ដោយមានកំលាំងពលករដែលមានជំនាញបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ សំរាប់ឆ្លើយតបចំពោះតម្រូវការការងារ ចេះប្រើប្រាស់ជំនាញទាំងនោះនៅក្នុងសង្គមផ្អែកលើពុទ្ធិ ។ ធានាថាកម្ពុជាពិតជាអាចប្រជែងបាន ។

# គោលនយោបាយចំពោះបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ នៅក្នុងការអប់រំ

គោលនយោបាយ ស្តីពីបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ នៅក្នុងការអប់រំរបស់ក្រសួងអប់រំ យុវជន និង កីឡា ផ្តោតការយកចិត្តទុកដាក់ចំពោះផែនសំខាន់ៗចំនួន ៤ :

- **ផែនទី ១ :** បង្កលក្ខណៈអោយគ្រូ និង សិស្សគ្រប់រូបទាំងអស់ ជាពិសេសនៅកំរិតមធ្យមសិក្សា បានប្រាស្រ័យប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ដោយធានាអះអាងថា បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ពិតជាត្រូវបានប្រើប្រាស់ជាយានជួយកាត់បន្ថយគំលាតឌីហ្សីថលរវាងសាលារៀនកម្ពុជា ជាមួយនឹងសាលារៀនផ្សេងៗទៀតនៅប្រទេសជិតខាង ។

- **ផែនទី ២ :** សង្កត់ធ្ងន់ទៅលើតួនាទី និង មុខងាររបស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ដែលជាឧបករណ៍សំរាប់រៀន និង បង្រៀនទៅតាមមុខវិជ្ជាផ្សេងៗ និង ក៏ជាមុខវិជ្ជាដោយឡែកផងដែរ ។ ការទទួលព័ត៌មានតាមអ៊ិនធឺណែតបណ្តាញព័ត៌មានអន្តរជាតិ និង ការប្រាស្រ័យទាក់ទងគ្នាដែលកាន់តែសកម្មតាមរយៈអ៊ីមែល (សារអេឡិចត្រូនិច) រវាងសាលារៀនជាមួយសាលារៀន និង រវាងបុគ្គលជាមួយបុគ្គលនោះអាចបំពេញមុខនាទីយ៉ាងសំខាន់ នៅក្នុងការអភិវឌ្ឍន៍អាជីពជូនអ្នកអប់រំ ។

ក្រៅពីវិទ្យុ និង ទូរទស្សន៍ ដែលជាឧបករណ៍សំរាប់រៀន និង បង្រៀនដែរនោះ គោលនយោបាយនេះក៏បានសង្កត់ធ្ងន់ទៅលើការប្រើប្រាស់កុំព្យូទ័រសំរាប់ទទួលយកព័ត៌មាន បង្កើនពុទ្ធិ និង ជំនាញផ្សេងៗ សំរាប់ប្រាស្រ័យទាក់ទងគ្នា ដើម្បីផ្លាស់ប្តូរព័ត៌មានផងដែរ ។

- **ផែនទី៣ :** លើកកំពស់ការអប់រំសំរាប់ទាំងអស់គ្នា តាមរយៈការអប់រំពីចម្ងាយ និង ស្វ័យសិក្សា ជាពិសេសគឺនៅក្នុងចំណោមក្រុមកុមារ ក្រុមជំទង់ និង ក្រុមជនពេញវ័យជួបការលំបាក ដែលបាត់បង់ឱកាសចូលសិក្សានៅកំរិត

អប់រំមូលដ្ឋាន រួមមានអក្ខរកម្ម និង បណ្តុះបណ្តាលបំណិនដោយមិនគិតពី អាយុ ភេទ ជនជាតិភាគតិច ពិការភាព ឬ ទីកន្លែង ដោយគួបផ្សំជាមួយនឹងវិទ្យុ ទូរទស្សន៍ ឯកសារបោះពុម្ព និង ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានចំរុះ ។

○ **ផែនទី ៤ :** សង្កត់ធ្ងន់ទៅលើការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ដើម្បីលើកកំពស់ផលិតភាព ភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាព ការគ្រប់គ្រងអប់រំ ។ តាមរយៈការប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងនេះ នឹងត្រូវបានប្រើប្រាស់កាន់តែច្រើន ដើម្បីធ្វើអោយការងារមានល្បឿនលឿន ជាងមុន រួមមានការកត់ត្រាលទ្ធផលបំពេញមុខងាររបស់គ្រូ និង សិស្ស ការប្រាស្រ័យទាក់ទងព័ត៌មានរវាងរដ្ឋាភិបាល ជាមួយនឹងសាលារៀន កិច្ចតែង ការបង្រៀន ការវាយតម្លៃ ការធ្វើតែស ការគ្រប់គ្រងហិរញ្ញវត្ថុ និង ការថែរក្សាបញ្ជីសារពើពន្ធ ។

## ១. សាវតារ

ក្រោយសង្គ្រាមខ្ទេចខ្ទាំអស់រយៈពេល ៣០ឆ្នាំ កន្លងមក កម្ពុជាបានខិតខំអភិវឌ្ឍ ធនធានមនុស្សរបស់ខ្លួន ដើម្បីកសាងប្រទេសជាតិសាជាថ្មីឡើងវិញ និង ដើម្បីធ្វើ សមាហរណកម្មខ្លួនចូលទៅក្នុងសហគមន៍តំបន់ និង សហគមន៍ពិភពលោក ។

ដំណាក់កាលបច្ចុប្បន្ននៃការអភិវឌ្ឍន៍វិស័យអប់រំកម្ពុជា គឺស្ថិតក្នុងដំណាក់បឋម នៅឡើយ ប្រសិនបើប្រៀបធៀបជាមួយនឹងប្រទេសជិតខាង ។

រាជរដ្ឋាភិបាលកម្ពុជា និង សហគមន៍អន្តរជាតិកំពុងតែធ្វើការរួមជាមួយគ្នា ដើម្បីសំរេចអោយបានតាមគោលដៅអប់រំសំរាប់ទាំងអស់គ្នានៅឆ្នាំ២០១៥ ហើយ រាជរដ្ឋាភិបាលក៏ទទួលស្គាល់ផងដែរថា បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ មិនត្រឹមតែជាកត្តាចម្បងសំរាប់ជួយអោយសំរេចបានទាំងគោលដៅអប់រំសំរាប់ទាំង អស់គ្នាប៉ុណ្ណោះទេ ប៉ុន្តែនៅបានបង្កលក្ខណៈងាយស្រួលអោយទទួលបានសេរីភាពខាង ការបញ្ចេញមតិយោបល់ និង ការប្រាស្រ័យទាក់ទងព័ត៌មានថែមទៀតផង ។ គេរំពឹង ទុកថា ការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍នេះ ពិតជានឹងជួយ លើកទឹកចិត្តអោយមានទម្លាប់ស្វ័យសិក្សា និង រៀនពេញមួយជីវិត ។

បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ដែលប្រើប្រាស់នៅកម្ពុជា រួមមាន បច្ចេកវិទ្យាកុំព្យូទ័រ បណ្តាញកុំព្យូទ័រអ៊ីមែល (សារអេឡិចត្រូនិច) និង អ៊ិនធឺណែត (បណ្តាញព័ត៌មានអន្តរជាតិ) ព្រមជាមួយនឹងវិទ្យុ និង ទូរទស្សន៍ផងដែរ ។ គោលនយោបាយនេះ កសាងឡើងដោយបានពិគ្រោះយោបល់ជាមួយដៃគូជាតិ និង ដៃគូអន្តរជាតិតាមរយៈសិក្ខាសាលា និង កិច្ចប្រជុំការងារជាបន្តបន្ទាប់ទាំងនៅក្នុងប្រទេសកម្ពុជា និង នៅក្នុងតំបន់ ។

## ២. ការវិភាគស្ថានភាព

ព្រមជាមួយឧបសគ្គដ៏ច្រើនសន្ធឹកសន្ធាប់ ដែលកម្ពុជាចាំបាច់ត្រូវតែពុះពារជំនះអោយបាន ដើម្បីអាចផ្តល់ការអប់រំប្រកបដោយគុណភាពសំរាប់ទាំងអស់គ្នានោះ គេហាក់ដូចជាសង្កេតឃើញថា បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ស្ថិតនៅលំដាប់ចុងក្រោយក្នុងបញ្ជីអាទិភាពនៅឡើយ ។ ម្យ៉ាងទៀតនោះប្រសិនបើគេមិនបានចាត់អោយមានសកម្មភាពអ្វីនាពេលឆាប់ៗនេះទេ នោះកម្ពុជាពិតជាធ្វើដំណើរយឺតដាច់ឆ្ងាយពីប្រទេសជិតខាងជាពុំខាន ហើយនៅក្នុងខណៈនោះពលរដ្ឋក្នុងយុវវ័យរបស់ខ្លួនក៏ពិតជានឹងគ្មានបំណិនចាំបាច់សំរាប់ប្រើប្រាស់ក្នុងការរស់នៅ នៅក្នុងយុគសម័យឌីហ្ស៊ីថលនេះដែរ ។ ការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍នេះអាចជួយអោយគ្រូបង្រៀន បោះជំហានឆ្ពោះទៅរកការបង្រៀន និង របៀបរៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល ។

### ២.១. កំរិតទទួលបាន និង កំរិតប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ក្នុងពេលបច្ចុប្បន្ន

យោងតាមការអង្កេតវាយតម្លៃ ស្តីពីការត្រៀមលក្ខណៈរបស់ប្រទេសជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលបានធ្វើឡើងកាលពីឆ្នាំ២០០១ កន្លងមកនេះ ប្រទេសកម្ពុជាស្ថិតនៅលំដាប់ថ្នាក់ទី៨ ក្នុងចំណោមប្រទេសទាំង១០ជាសមាជិកអាស៊ាន នៅក្នុងន័យថាតើប្រទេសនីមួយៗសំរេចបានហេដ្ឋារចនាសម្ព័ន្ធអេឡិចត្រូនិច សង្គមអេឡិចត្រូនិច ពាណិជ្ជកម្មអេឡិចត្រូនិច និង រដ្ឋាភិបាល

អេឡិចត្រូនិចបានត្រឹមកំរិតណា ។ គេបានអោយចំណាត់ថ្នាក់ដល់ប្រទេសណាមួយថាល្អបានត្រៀមលក្ខណៈ "ជាទីសង្ឃឹម" ត្រឹមកំរិតណានោះ ដោយផ្អែកលើភាពចាំបាច់នៃការកសាងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ និង កំលាំងពលករជាអក្ខរជនផ្នែកបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ។

ការប្រាស្រ័យទាក់ទងគ្នាតាមរយៈអ៊ិនធឺណែតជាសាធារណៈ គឺនៅមានកំរិតនៅឡើយ ។ ប៉ុន្មានឆ្នាំកន្លងមកនេះ ចំនួនហាងកាហ្វេមានប្រើអ៊ិនធឺណែតបានបង្ហាញខ្លួនច្រើនជាងមុននៅតាមទីប្រជុំជន និង នៅតាមចំណុចគោលដៅទេសចរណ៍ ។ បច្ចុប្បន្ននេះគេសង្កេតឃើញមានហាងកាហ្វេប្រើអ៊ិនធឺណែតច្រើនជាង១០០ កន្លែងនៅក្នុងទីក្រុងភ្នំពេញ និង សង្កេតឃើញហាងប្រើអ៊ិនធឺណែតជាច្រើនផ្សេងទៀតនៅខេត្តសៀមរាប និង ក្រុងព្រះសីហនុ ។ វគ្គបណ្តុះបណ្តាលប្រើប្រាស់កុំព្យូទ័រកំពុងតែទទួលបានការពេញនិយមនៅតាមទីប្រជុំជនសំខាន់ៗ ។ ក៏ប៉ុន្តែពលរដ្ឋជាង៨០% ដែលរស់នៅតាមទីជនបទពិតជាមានភ័ព្វសំណាង តិចតួច ឬ ក៏គ្មានឱកាសទាល់តែសោះនៅក្នុងការប្រើប្រាស់កុំព្យូទ័រ និង អ៊ិនធឺណែត ដើម្បីទទួលបានព័ត៌មាន ។ មហាជននៅតាមជនបទពឹងផ្អែកទាំងស្រុងតែទៅលើវិទ្យុ និង ទូរទស្សន៍ ។

យោងតាមការសិក្សាស្រាវជ្រាវរបស់សហព័ន្ធទូរគមនាគមន៍អន្តរជាតិ គេបានដឹងថានៅឆ្នាំ២០០២ ការជ្រៀតចូលអ៊ិនធឺណែត មានកំរិតទាបបំផុតនៅក្នុងប្រទេសកម្ពុជា បើប្រៀបធៀបទៅនឹងកំរិតដែលប្រទេសផ្សេងៗទៀតនៅអាស៊ីអាគ្នេយ៍នេះទទួលបាន ហើយតម្លៃប្រើប្រាស់អ៊ិនធឺណែតគឺមានកំរិតខ្ពស់ ។[១]

## ២.២. អាំងឌីកាទ័រអប់រំ

អត្រាពិតនៃការសិក្សា (NER) នៅកំរិតបឋមសិក្សាសំរាប់ឆ្នាំ ២០០២-២០០៣ បាន ៨៨.៣% ដោយមានចំនួនសិស្សសរុបប្រមាណ ២ ៧៥០ ០០០នាក់ ។ នៅកំរិតមធ្យមសិក្សាវិញនោះ អត្រាពិតនៃការសិក្សាបានត្រឹមតែ ២០% ប៉ុណ្ណោះ ដែលជាអត្រាទាបបំផុតនៅក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន ។ ចំនួនសិស្សបាន

---

១ "Khmer Internet Cambodia: ករណីសិក្សា"
( Internet Telecommunication Union, មីនា 2002 )

កើនជាមធ្យមពី ៣៥០ ទៅ ៤០០នាក់ នៅតាមសាលាបឋមសិក្សានីមួយៗ ហើយ និង មានសិស្សប្រមាណជា ៧០០នាក់ នៅតាមវិទ្យាល័យ/អនុវិទ្យាល័យ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ។ នៅកំរិតបឋមសិក្សា និង មធ្យមសិក្សា ផលធៀបសិស្ស-គ្រូមាន ៥៥:១ និង ២៦:១ រៀងគ្នា (ធៀបទៅនឹងសាធារណៈរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ដែលមាន ២៨:១ និង ១៥:១ រៀងគ្នា) ។ ផលធៀបនេះបានធ្លាក់ស្រុតចុះចាប់តាំងពីឆ្នាំ១៩៩៨ ដោយហេតុថាចំនួនសិស្សបានកើនឡើងជាលំដាប់ ប៉ុន្តែការផ្គត់ផ្គង់គ្រូបង្រៀនដែលបានឆ្លងវគ្គបណ្ដុះបណ្ដាលនោះមិនទាន់បានឆ្លើយតបទៅនឹងកំណើនសិស្សដែលកើនច្រើនឡើងនោះនៅឡើយទេ ។ ផលធៀបសិស្ស-គ្រូ នេះប្រែប្រួលគួរអោយកត់សំគាល់នៅតាមបណ្ដាខេត្តផ្សេងៗ និង នៅតាមតំបន់ដាច់ស្រយាល ដោយហេតុថាផលធៀបសិស្ស-គ្រូ នៅកំរិតបឋមសិក្សាអាចកើនខ្ពស់រហូតដល់ទៅ ៩៥:១ ។

ចំនួនម៉ោងអប្បបរមា ដែលសិស្សបានជួបគ្រូនៅក្នុងសាលារៀននោះគឺ ៨០០ ម៉ោងក្នុង១ឆ្នាំសិក្សា ។ តាមការអនុវត្តន៍ជាក់ស្ដែងនោះ របាយការណ៍ពីមូលដ្ឋានបានគូសបញ្ជាក់ថា សាលារៀនភាគច្រើនដំណើរការបង្រៀនបានត្រឹមតែ ៥០០ម៉ោងប៉ុណ្ណោះនៅក្នុងឆ្នាំសិក្សានីមួយៗ ។ នៅតាមសាលារៀនដែលបានបង្រៀនពីរវេន ឬបីវេន ចំនួនម៉ោងដែលសិស្សបានប្រាស្រ័យជាមួយគ្រូនោះធ្លាក់នៅសល់ត្រឹមតែ ៣៥០ ម៉ោងប៉ុណ្ណោះក្នុងមួយឆ្នាំសិក្សា ។

## ២.៣. ស្ថានភាពបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ក្នុងការអប់រំនាពេលបច្ចុប្បន្ន ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០៤-២០០៨

យុទ្ធសាស្ត្រឆ្លងផ្នែកសំរាប់ពង្រឹងការអនុវត្តន៍គោលនយោបាយ គឺបង្កើនការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង ការប្រាស្រ័យទាក់ទង ដោយអនុវត្តតាមគោលនយោបាយថ្មីស្ដីពីបច្ចេកវិទ្យា ព័ត៌មាន និង ការប្រាស្រ័យទាក់ទង របស់ក្រសួងដែលបានអនុម័តនៅដើមឆ្នាំ២០០៤ ។ អាទិភាពមួយទៀត គឺពង្រឹងការគ្រប់គ្រងព័ត៌មានដោយផ្អែកលើបច្ចេកវិទ្យា ព័ត៌មាន និង ការប្រាស្រ័យទាក់ទងនៅគ្រប់កំរិត ដែលជាផ្នែកមួយនៃវិធានការធ្វើវិមជ្ឈការ ។ កំណែលំអការចូលរៀន និង គុណភាពត្រូវបានគាំទ្រ

ដោយការផ្តល់កាលានុវត្តភាព ក្នុងការសិក្សាពីចម្ងាយដោយផ្អែកលើបច្ចេកវិទ្យា ព័ត៌មាន និង ការប្រាស្រ័យទាក់ទង ( ឧ. ការអភិវឌ្ឍន៍គ្រូបង្រៀន ការសិក្សាពីចម្ងាយ សំរាប់កំរិតបរិញ្ញាប័ត្រជាន់ខ្ពស់ ) ការដាក់អោយអនុវត្តកម្មវិធីយល់ដឹងអំពីកុំព្យូទ័រនៅ ក្នុងសាលាមធ្យមសិក្សាទុតិយភូមិ និងគ្រឹះស្ថានក្រោយមធ្យមសិក្សា ។ ទន្ទឹមនេះដែរ ក្រសួងប្រើប្រាស់សមត្ថភាពរបស់ផ្នែកឯកជនក្នុងការកសាងកម្មវិធី និងផ្តល់តាមប្រព័ន្ធ ផ្សព្វផ្សាយព័ត៌មានចំរុះ (multi-media )សំរាប់ពង្រីកកម្មវិធីបច្ចេកវិទ្យា ព័ត៌មាន និង ការប្រាស្រ័យទាក់ទង និង បង្កើនការយល់ដឹងអំពីជំងឺ អេដស៍-ហ៊ីវ ។

## ២.៣.១. ការអភិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ក្នុងការ បណ្តុះបណ្តាលគ្រូបង្រៀន

នាពេលថ្មីៗកន្លងមកនេះ ក្រសួងអប់រំ យុវជន និង កីឡា បានបង្ហាញសក្ខីភាព នៃការប្តេជ្ញាចិត្តមោះមុត លើកកំពស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍នៅក្នុង ការអប់រំ ដោយបានតម្រូវអោយគរុសិស្សទាំងអស់រៀនមុខវិជ្ជាបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ចំនួន ២ម៉ោង ក្នុងមួយសប្តាហ៍ ចាប់ពីឆ្នាំ២០០៣ តរៀងទៅ ។

ចំនួនកុំព្យូទ័រនៅតាមសាលាគរុកោសល្យនានា បានកើនឡើងគួរអោយចាប់ អារម្មណ៍ចាប់តាំងពីឆ្នាំ២០០៣ ។ កុំព្យូទ័រមួយចំនួនក្នុងចំណោមកុំព្យូទ័រទាំងនោះ បានមកពីការចំណាយថវិកាផែនការសកម្មភាពជាអាទិភាព និងមួយចំនួនផ្សេងទៀត បានមកពីប្រភពជំនួយផ្សេងៗ ។ បរិមាណកុំព្យូទ័របានកើនច្រើនគួរអោយកត់សំគាល់ ហើយគ្រប់សាលាគរុកោសល្យទាំងអស់ សុទ្ធតែមានបន្ទប់បណ្តុះបណ្តាលការប្រើប្រាស់ កុំព្យូទ័ររៀងៗខ្លួន ។ នៅក្នុងឆ្នាំ២០០៣ នេះ ផលធៀបគរុសិស្ស-កុំព្យូទ័រនៅ តាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និង សាលាគរុកោសល្យ និង វិក្រឹតការខេត្ត-ក្រុង មាន ៦៥:១ ។ ផលធៀបនេះបានថយចុះនៅត្រឹម ៣២:១ នៅក្នុងឆ្នាំ២០០៤ ។ ប្រការនេះបានជួយបង្កលក្ខណៈអោយស្ថាប័នគរុកោសល្យទាំងឡាយ អាចចាប់ផ្តើម វគ្គបណ្តុះបណ្តាលបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍រៀងៗខ្លួន ។

ប៉ុន្តែសាលាគរុកោសល្យទាំងអស់ ពុំមែនសុទ្ធតែមានកុំព្យូទ័រគ្រប់គ្រាន់សំរាប់បង្រៀនវគ្គបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ អោយមានប្រសិទ្ធភាពនោះឡើយ ។ សាលាខ្លះជួបបញ្ហាគ្មានថាមពលអគ្គិសនីគ្រប់គ្រាន់ ដែលជាហេតុតម្រូវអោយគេពឹងផ្អែកលើម៉ាស៊ីនភ្លើង ឬ តម្រូវអោយផ្អាករាល់ការប្រើប្រាស់បរិធានអគ្គិសនីផ្សេងៗទៀត ឬ សុំអោយការិយាល័យផ្សេងៗទៀតត្រូវបិទចរន្តអគ្គិសនី ហើយនិងផ្អាកការងារខ្លួនជាបណ្តោះអាសន្នសិន ដើម្បីបង្កលក្ខណៈអោយបន្ទប់រៀនកុំព្យូទ័រអាចដំណើរការរៀនបាន ។

នៅដើមខែ កញ្ញា ឆ្នាំ២០០៤ គ្រូឧទ្ទេសចំនួនជាងពាក់កណ្តាលនៃគ្រូឧទ្ទេសទាំងអស់ ៦០០ នាក់ មកពីសាលាគរុកោសល្យ និង វិក្រឹតការខេត្ត-ក្រុងទាំង ១៨ និង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង ៦ បានឆ្លងកាត់វគ្គបណ្តុះបណ្តាលបំណិនបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ជាមូលដ្ឋាន និងប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ នៅក្នុងការងាររដ្ឋបាល និងការបង្រៀន និងការរៀន ។ គ្រូឧទ្ទេសមួយនាក់ មកពីសាលាគរុកោសល្យនីមួយៗ បានឆ្លងកាត់វគ្គបណ្តុះបណ្តាលអោយចេះបង្កើតវែបសាយសាមញ្ញដំបូងមួយ ហើយនិងបានដាក់បញ្ចូលគេហទំព័ររៀងខ្លួន ទៅក្នុងវែបសាយក្រសួងអប់រំ យុវជន និង កីឡា ។ ដោយឡែកពីនេះគ្រូឧទ្ទេសមួយនាក់មកពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំងអស់ និង វិទ្យាស្ថានជាតិអប់រំ បានផ្តើមបង្កើតធនធានរៀនតាមវែបសាយ និង ចក្ខុសោតទស្សន៍សំរាប់មធ្យមសិក្សា តាមរយៈសិក្ខាសាលាបណ្តុះបណ្តាលមួយ ហើយនិងបានឆ្លងកាត់វគ្គបណ្តុះបណ្តាលថែរក្សា និង ជួសជុលកុំព្យូទ័រ នៅក្នុងឆ្នាំ ២០០៤ នេះ ។

កម្មវិធីសិក្សាមួយសំរាប់រៀនបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍នៅក្នុងការបង្រៀន និង រៀនកំពុងតែត្រូវបានអភិវឌ្ឍសំរាប់សាលាគរុកោសល្យខេត្ត-ក្រុង និង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ។ កម្មវិធីសិក្សានេះ នឹងមានបញ្ចូលការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ សំរាប់ការងាររដ្ឋបាល ការអភិវឌ្ឍន៍អាជីពបង្រៀន និង សំរាប់បង្កើតធនធានបង្រៀនជាភាសាខ្មែរផងដែរ ។ នៅកំរិតមធ្យមសិក្សាវិញនោះ គេនឹងត្រូវប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ដើម្បីពង្រឹងការបង្រៀនទៅតាមមុខវិជ្ជា ។

### ២.៣.២. បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍នៅក្នុងឧត្តមសិក្សា

ការបោះជំហានឈានចូលក្នុងសេដ្ឋកិច្ចទីផ្សារចាប់តាំងពីឆ្នាំ១៩៩៣ មកនោះ បានបង្កលក្ខណៈអោយមានការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនតូច ធំ ដែលមានគុណភាពប្លែកៗពីគ្នា ។ គ្រឹះស្ថានអប់រំខ្លះដែលមានវគ្គសិក្សាពេញនិយមខ្លាំងបំផុតនោះ បានបើកបង្រៀនមុខវិជ្ជាពាក់ព័ន្ធជាមួយ បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ភាសាបរទេស និង មុខវិជ្ជាជំនួញ ។ ភាគច្រើននៃមហាវិទ្យាល័យទាំងនេះមានទីតាំងនៅក្នុងតំបន់ក្រុង ដោយបានផ្តល់មធ្យោបាយ និងសេវាកម្ម បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ជាទីគាប់ចិត្ត ហើយបានភ្ជាប់ជាមួយនឹងអ៊ិនធឺណែតផងដែរ ។

### ២.៣.៣. ការអប់រំក្រៅប្រព័ន្ធ និង ការអប់រំពីចម្ងាយ

ភាពជឿនលឿនក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ និង ខ្លឹមសារជាភាសាខ្មែរ សំរាប់ការអប់រំក្រៅប្រព័ន្ធ និង ការសិក្សាពីចម្ងាយនោះច្រើនតែសំរេចបានដោយអង្គការក្រៅរដ្ឋាភិបាល ។ ឧទាហរណ៍គួរអោយកត់សំគាល់នោះ រួមមានមជ្ឈមណ្ឌលព័ត៌មាន សហគមន៍ចំនួន២២កន្លែង ដែលកំពុងតែផ្តល់លទ្ធភាពជូនប្រជាពលរដ្ឋនៅតាមទីជនបទ និងទីប្រជុំជន អោយអាចប្រាស្រ័យជាមួយអ៊ិនធឺណែតដោយបង់ថ្លៃតិចតួច ។ សាលារៀនមួយចំនួនតូចនៅតាមតំបន់ដាច់ស្រយាលកំពុងតែប្រើប្រាស់ថាមពលព្រះអាទិត្យ និង ភ្ជាប់ជាមួយតារាវណប ។ អង្គការ "វេទិកាទូទៅនៃកម្ពុជា" (The Open Forum of Cambodia) បានបំពេញតួនាទីឈានមុខ ក្នុងការលើកកំពស់ការប្រើប្រាស់ភាសាខ្មែរក្នុងវិស័យបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ។ បច្ចុប្បន្នអង្គការបានឈានមុខគេក្នុងការអភិវឌ្ឍន៍ខ្លឹមសារវិបផតថល ជាខេមរភាសាដែលជាវេបសាយនាំផ្លូវចូលទៅភ្ជាប់អ៊ិនធឺណែតដ៏ធំជាងគេតែមួយគត់នៅក្នុងប្រទេស ដោយផ្តល់ជូនអ្នកប្រើប្រាស់អោយបានជ្រាបអំពីព័ត៌មានទាក់ទងវិស័យជាច្រើន ដែលរួមមានព័ត៌មានស្តីពីសិទ្ធិមនុស្ស ប្រវត្តិសាស្ត្រ និង បរិស្ថាន ។ល។ ទន្ទឹមនឹងនេះ អង្គការ "វេទិកាទូទៅនៃកម្ពុជា" បានបើកវគ្គបណ្តុះបណ្តាលមិនបង់ថ្លៃជាបន្តបន្ទាប់ដូចជា វគ្គបណ្តុះបណ្តាលអំពីការប្រើប្រាស់អ៊ីមែល និង ការបង្កើតវេបសាយជាភាសាខ្មែរជាដើម ។ ក្រៅពីនេះអង្គការកំពុងអនុវត្ត ( គំរោងផ្តួចផ្តើម

បង្កើតគ្រឿងទន់ “Software” ភាសាខ្មែរ ដែលមានឈ្មោះថា khmeros ) ដែលមានបំណងបង្កើតគ្រឿងទន់ “Software” មានអានុភាពខ្ពស់ជាភាសាខ្មែរ ហើយឥតគិតថ្លៃ ដោយសមស្របទៅនឹងសេដ្ឋកិច្ចរបស់កម្ពុជាយើង ។ ដោយហេតុថាមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធយើងនៅខ្សត់ខ្សោយនោះ ពលរដ្ឋខ្មែរមួយចំនួនធំនៅតាមជនបទ អាចទទួលបានព័ត៌មានតែតាមរយៈវិទ្យុ និង ទូរទស្សន៍ប៉ុណ្ណោះ ហើយគេក៏នៅពុំទាន់ទាញយកគុណប្រយោជន៍អោយបានពេញទំហឹង ពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានចំរុះអប់រំនៅឡើយ ។

### ២.៤. ការត្រៀមលក្ខណៈបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍នៅតាមសាលារៀន

ក្នុងចំណោមសាលាមធ្យមសិក្សាទាំង ៦៩៨ នៅទូទាំងប្រទេសមានតែសាលាចំនួន១៣%ប៉ុណ្ណោះដែលមានអគ្គិសនី ៨% ផ្សេងទៀតមានម៉ាស៊ីនភ្លើង និង ៤% ប្រើថាមពលព្រះអាទិត្យ ។ សាលាមធ្យមសិក្សា ៧៥% ពុំទទួលបានការផ្គត់ផ្គង់ថាមពលអ្វីទាំងអស់ ។[២]

សាលារដ្ឋចំនួនតិចតួចណាស់ ដែលមានកុំព្យូទ័រសំរាប់រៀន ។ អនុវិទ្យាល័យចំនួន ៦% និង វិទ្យាល័យចំនួន ៣៥% មានកុំព្យូទ័រមួយគ្រឿង ឬ ពីរគ្រឿងសំរាប់តែការងាររដ្ឋបាលប៉ុណ្ណោះ ។ វិទ្យាល័យចំនួនត្រឹមតែ ៨ មានកុំព្យូទ័រច្រើនលើសពី ១០ គ្រឿង ។

លើសពីនេះក្រៅពីសាលារដ្ឋ សាលារៀនឯកជនមួយចំនួនធំ បានបើកវគ្គបង្រៀនកុំព្យូទ័រ ។ នៅដើមឆ្នាំ២០០៥ នេះ ក្រសួងអប់រំ យុវជន និង កីឡា មានផែនការធ្វើការអង្កេតក៏រិតជាតិមួយ ដើម្បីប្រមូលព័ត៌មានលំអិតស្តីពីបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ក្នុងការអប់រំ ។

## ៣. យុទ្ធសាស្ត្រលើកកំពស់ការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ក្នុងការអប់រំ

### ៣.១. គោលដៅរយៈពេលមធ្យម

ទិសដៅរយៈពេលមធ្យមសំរាប់រយៈពេល ២០០៤-២០១០ មាន :



[២] ប្រភព : មជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) នាយកដ្ឋានផែនការ (ក្រសួង អយក) ២០០២-២០០៤

ក). កសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ និង ផ្តល់គ្រឿងរឹង "Hardware" សំរាប់ការអប់រំ និង ការបណ្តុះបណ្តាល ។ កិច្ចការនេះ រួមមានការរៀបចំបន្ទប់កុំព្យូទ័រ និង ការបង្កើតបណ្តាញ (ក្នុងស្ថាប័នផ្ទាល់នីមួយៗ អ៊ិនត្រាណែត និង អ៊ិនធឺណែត) ។ ក្រសួងនឹងផ្តល់កុំព្យូទ័រអោយគ្រឹះស្ថានសិក្សា សាលាមធ្យមសិក្សា មហាវិទ្យាល័យ /សកលវិទ្យាល័យ មន្ទីរអប់រំ យុវជន និង កីឡាខេត្ត/ក្រុង ការិយាល័យអប់រំយុវជន និងកីឡា ស្រុក/ខ័ណ្ឌ មជ្ឈមណ្ឌលសិក្សាសហគមន៍ ។ បណ្តានាយកដ្ឋាននៅក្រោមឱវាទក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត/ក្រុង ការិយាល័យអប់រំ យុវជន និង កីឡាស្រុក/ខ័ណ្ឌ នឹងមានបណ្តាញភ្ជាប់ទំនាក់ទំនងជាមួយគ្នា ដើម្បីអាចប្រាស្រ័យទាក់ទង និង ទទួលបានមូលដ្ឋានទិន្នន័យ និង ធនធានផ្សេងៗសំរាប់ការងារគ្រប់គ្រងអប់រំ ។

ខ). អភិវឌ្ឍធនធានមនុស្ស ដើម្បីឆ្លើយតបចំពោះតម្រូវការក្នុងវិស័យបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ និង អប់រំ ។

គ). លើកស្ទួយបំណិនត្រិះរិះថ្លៃប្រឌិត បំណិនប្រាស្រ័យទាក់ទងព័ត៌មាន និង បំណិនដោះស្រាយបញ្ហា បំណិនស្រាវជ្រាវ និង បំណិនកែច្នៃ និង ទាញយកព័ត៌មាន ដោយប្រើបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ដែលជាឧបករណ៍ក្នុងការបង្រៀន និង ការរៀន ។

ឃ). បង្កើនប្រសិទ្ធភាពការងាររដ្ឋបាល ដោយប្រើបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍នៅក្នុងការគ្រប់គ្រងអប់រំ តាមរយៈការប្រើប្រាស់ឧបករណ៍ទាំងនេះ ដូចជាប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំជាដើម ។

## ៣.២. យុទ្ធសាស្ត្ររយៈពេលមធ្យម

### ៣.២.១. ការអភិវឌ្ឍន៍ធនធានមនុស្ស

ក). នៅឧត្តមសិក្សាសាធារណៈ និង ឯកជន ចាំបាច់ត្រូវបើកវគ្គអោយបានច្រើន គ្រប់រូបភាពសំរាប់អាជីព បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ។

ខ). នៅសាលាគរុកោសល្យ ចាំបាច់ត្រូវបណ្តុះបណ្តាលគ្រូឧទ្ទេសទាំងអស់ អោយចេះប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ សំរាប់ ការងាររដ្ឋបាល និង ការអភិវឌ្ឍន៍អាជីព ។ ក្រៅពីនេះត្រូវបណ្តុះបណ្តាល គ្រូបង្រៀននៅវិទ្យាល័យ/អនុវិទ្យាល័យ ទាំងអស់អោយក្លាយជា អក្ខរជនបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ដើម្បីធ្វើអោយ គ្រូទាំងអស់ចេះប្រើបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ សំរាប់ ជួយការបង្រៀន និងការរៀន ។

គ). កែលំអកម្មវិធីសិក្សាអោយតាមទាន់បច្ចុប្បន្នភាពសំរាប់បណ្តុះបណ្តាល គ្រូបឋមសិក្សា ដោយបញ្ចូលការប្រើបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ សំរាប់ការងាររដ្ឋបាល និង ការអភិវឌ្ឍន៍អាជីព ។

ឃ). កែលំអកម្មវិធីសិក្សាអោយមានលក្ខណៈបច្ចុប្បន្នភាពសំរាប់បណ្តុះបណ្តាល គ្រូមធ្យមសិក្សា ដោយបញ្ចូលការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ សំរាប់ការងាររដ្ឋបាល ការអភិវឌ្ឍន៍អាជីព និងប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍នេះ ជាឧបករណ៍ជួយការបង្រៀន និង រៀន ។

ង). ជំរុញសកម្មភាពសិក្សាស្រាវជ្រាវ និង សិក្សាដោយឯករាជ្យពេញមួយ ជីវិតនៅគ្រប់ស្ថាប័នអប់រំទាំងអស់ ។

ច). បណ្តុះបណ្តាលបុគ្គលិកជូនស្ថាប័ននីមួយៗ យ៉ាងហោចណាស់ ១នាក់ អោយចេះថែរក្សា និង ជួសជុលកុំព្យូទ័រ ។

### ៣.២.២. គ្រឿងរឹង “Hardware” និង ហេដ្ឋារចនាសម្ព័ន្ធ

ក). បំពាក់គ្រឿងរឹង និង ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងឡាយ ជូនសាលាគរុកោសល្យ និង សកលវិទ្យាល័យទាំងអស់ ដើម្បីអនុញ្ញាតអោយគ្រូ និង សិស្ស បានប្រាស្រ័យប្រើប្រាស់កុំព្យូទ័រ និងអ៊ិនធឺណែត ។ ផ្តល់ថវិកាសំរាប់ជួសជុល និង ថែរក្សាកុំព្យូទ័រ ។

ខ). ផ្តត់ផ្គង់អគ្គិសនីជូនគ្រប់វិទ្យាល័យ/អនុវិទ្យាល័យ និង បំពាក់គ្រឿងរឹងអោយសាលារៀនទាំងអស់នោះ ដើម្បីអោយសិស្សបានប្រាស្រ័យប្រើប្រាស់កុំព្យូទ័រ វិទ្យុ និង ទូរទស្សន៍ជាជំនួយដល់ការសិក្សារបស់ខ្លួន ។ គេគប្បីប្រើប្រាស់ធនធានដែលមានស្រាប់អោយអស់លទ្ធភាព ជាឧទាហរណ៍ បន្ទប់កុំព្យូទ័ររបស់សាលារៀន គប្បីត្រូវបានប្រើប្រាស់ផងដែរដោយសហគមន៍ និង កុមារក្រៅសាលារៀន ដែលមិនធ្លាប់ចូលរៀនក្នុងសាលារៀន ។

គ). ផ្តល់សេវាកម្មចល័តរៀនបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ជូនចំពោះសហគមន៍ដែលជួបការលំបាក ។

ឃ). ជំរុញការប្រើប្រាស់មជ្ឈមណ្ឌលសិក្សាសហគមន៍ មជ្ឈមណ្ឌលព័ត៌មានសហគមន៍ និង បណ្ណាល័យសហគមន៍ ។ ពង្រីកសកម្មភាពបន្ថែមដោយបញ្ចូលការប្រើប្រាស់វីដេអូ វិទ្យុ និង ទូរទស្សន៍ សំរាប់ការរៀន ។ ដោយធ្វើការជាមួយដៃគូអង្គការក្រៅរដ្ឋាភិបាល ។ បង្កលក្ខណៈងាយស្រួលអោយបានច្រើនថែមទៀតជូនយុវជនក្រៅសាលារៀន ។

ង). បង្កើតស្ថានីយទូរទស្សន៍ ស្ថានីយវិទ្យុ និង ផ្តល់បុគ្គលិកគ្រប់គ្រាន់ដើម្បីបំរើអោយប្រព័ន្ធអប់រំ ។

ច). ផ្តល់ចរន្តអគ្គិសនី និង ការភ្ជាប់អ៊ិនធឺណែត ជូនសាលាមធ្យមសិក្សានៅទីណាដែលអាចធ្វើបាន ។

### ៣.២.៣. ការអភិវឌ្ឍន៍ខ្លឹមសារក្នុងស្រុក និង ការប្រើប្រាស់គ្រឿងទន់ "Software" ដែលមិនចាំបាច់បង់ថ្លៃ

ក). លើកទឹកចិត្តអោយប្រើគ្រឿងទន់ពីប្រភពមិនបង់ថ្លៃឈ្នួល ដូចជា Linux និង Star Office ។ គ្រឿងទន់ពីប្រភពចំហ ឬគ្រឿងទន់មិនចាំបាច់បង់ថ្លៃនេះ សំដៅយោងដល់គ្រឿងទន់ទាំងឡាយដែលគេទាំងអស់គ្នាអាចចម្លង ហើយអាចប្រើប្រាស់បានដោយមិនចាំបាច់បង់ថ្លៃទិញគ្រឿងទន់នោះ ឬ ជាគ្រឿងទន់ដែលមានច្បាប់រក្សាសិទ្ធិមិនតឹងរ៉ឹង ។

ខ). ជំរុញការអភិវឌ្ឍន៍ខ្លឹមសារជាភាសាខ្មែរ សំរាប់សាលារៀនក្នុងប្រព័ន្ធការអប់រំពីចម្ងាយ និង បណ្ណាកម្មវិធីមានតម្លៃសមមូល ដោយផ្តល់រង្វាន់ប្រចាំឆ្នាំជូនបណ្ណាស្នាដៃឆ្នើមៗ ជាធនធានសំរាប់បង្រៀន និង រៀន ដែលបានដាក់ជូនទៅគ្រឹះស្ថានជាតិ ប្រមូល និង ផ្សព្វផ្សាយធនធានបង្រៀន និង រៀនតាមបណ្តាញ (National Clearinghouse) ។

គ). ជំរុញការអភិវឌ្ឍន៍ប្រព័ន្ធប្រតិបត្តិ (Operating System) ជាភាសាខ្មែរ ដែលនឹងបង្កលក្ខណៈងាយស្រួលទូលំទូលាយជូនដល់អក្ខរជននៅក្នុងប្រទេសកម្ពុជាអោយបានប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍នេះ នៅក្នុងការប្រាស្រ័យទាក់ទងព័ត៌មាន និង ការរៀនរបស់ខ្លួន ។

### ៣.២.៤. ការប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍នៅតាមសាលារៀន

ក). នៅតាមសាលាមធ្យមសិក្សាត្រូវជំរុញការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ដើម្បីពង្រឹងគុណភាពបង្រៀន និង រៀន ជាដំបូងក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ ភាសាបរទេស វិទ្យាសាស្ត្រសង្គម និង គណិតវិទ្យា ។

ខ). កែសំរួលកម្មវិធីសិក្សាសំរាប់កំរិតមធ្យមសិក្សា ដោយដាក់បញ្ចូលអោយមានការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ក្នុងការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ភាសាបរទេស វិទ្យាសាស្ត្រសង្គម និង គណិតវិទ្យា នៅទីណាដែលអាចធ្វើបាន ។ កម្មវិធីសិក្សាគប្បីលើកទឹកចិត្តអោយប្រើប្រាស់បច្ចេកវិទ្យាផងដែរ ដូចជាការប្រើវីស៊ីឌី កាសែត្សវីដេអូ និង កាសែត្សស្តាប់ វិទ្យុ និង ទូរទស្សន៍ជាដើម ។

គ). ផ្តល់បំណិនបច្ចេកវិទ្យានេះ ក្នុងរូបភាពជាវគ្គបំប៉នបំណិនជីវិត នៅទីណាដែលមានធនធានល្មមនឹងអាចធ្វើបាន ។

ឃ). ការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ នៅតាមសាលារៀននេះគប្បីគោរពតាមក្រមសីលធម៌ សំដៅឆ្លើយតបទៅនឹងចតុស្តម្ភអប់រំ ។

### ៣.២.៥. ប្រព័ន្ធគ្រប់គ្រងពុទ្ធិ

ក). បង្កើតគ្រឹះស្ថានប្រមូល និង ផ្សព្វផ្សាយធនធានបង្រៀន និង រៀនតាមបណ្តាញជាខេមរភាសា និង ជាភាសាបរទេស ។

ខ). ធានាអោយមានការភ្ជាប់ឃ្លាំងព័ត៌មាន ដែលមានប្រយោជន៍ដល់ការអប់រំ និង វែបសាយ ធានាអោយមានការប្រមូលធនធានបង្រៀន និង រៀន ដែលកសាងដោយគ្រូ និង បុគ្គលអាជីពដទៃៗទៀត និង ធានាអោយមានការប្រមូលគ្រឿងទន់ដែលអាចប្រើប្រាស់បានដោយមិនចាំបាច់បង់ថ្លៃ (freeware) និង គ្រឿងទន់ "Software" ដែលអាចប្រើប្រាស់រួមគ្នាបាន (Shareware Software) ដែលអ្នកប្រើប្រាស់អាចចម្លងចេញ (Download) បានតាមបណ្តាញនៅក្នុងប្រទេសកម្ពុជា និង ពីវែបសាយ នៅលើពិភពលោក ។

## ៣.២.៦. ការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ តាមរយៈ សាលារៀនចំហ និង ការអប់រំពីចម្ងាយ

ដោយហេតុថា កុមារអាយុពី ១២-១៥ឆ្នាំ ត្រឹមតែ ២០% បានចូលរៀននៅកំរិតមធ្យមសិក្សា នៅក្នុងឆ្នាំ២០០៤ នេះ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍នេះ សំរាប់ជួយពង្រីងការចូលសិក្សានៅកំរិតបឋមសិក្សា និង មធ្យមសិក្សាតាមរយៈ "សាលារៀនចំហ" (Open Schools) ។ សាលារៀនចំហ ការអប់រំពីចម្ងាយ ឬ ការអប់រំមានតម្លៃសមមូលនេះ នឹងត្រូវបង្កើតក្នុងក្របខ័ណ្ឌនៃផែនការ ៥ឆ្នាំ (ESSP) បច្ចុប្បន្ន (២០០៤-០៨) ដើម្បីផ្តល់ :

ក). ឱកាសអប់រំនៅតាមទីតាំងដាច់ស្រយាល ដែលគ្មានសាលារៀនធម្មតាក្នុងប្រព័ន្ធនៅទីនោះ ។

ខ). ជំរើសមួយជូនអ្នកសិក្សា ពោលគឺគេចង់រៀនអំពីអ្វី រៀននៅពេលណា និង រៀននៅទីណា ។

គ). បណ្តាញមានសុវត្ថិភាពមួយជូនដល់សិស្សបោះបង់ការសិក្សា អោយអាចបន្តការសិក្សារបស់ខ្លួន ។

ឃ). ការអប់រំដល់អ្នកដែលចង់ធ្វើការផងរៀនផង ។

សេវាអប់រំនេះនឹងត្រូវផ្តល់ជូនតាមរយៈប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានចំរុះ មានអន្តរកម្ម (interactive multi-media) ដែលរួមមានវិទ្យុ ទូរទស្សន៍ ទូរស័ព្ទចល័ត អ៊ិនធឺណែត និង អ៊ីមែលជាដើម ។ ក្រសួងអប់រំ យុវជន និង កីឡា មានចេតនាបង្កើត វិទ្យុអប់រំ និង ទូរទស្សន៍អប់រំផ្ទាល់ខ្លួននៅក្នុងអាណត្តិពេលវេលានៃការអប់រំសំរាប់ទាំងអស់គ្នានេះ ។

### ៣.២.៧. ការប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍នៅតាមសកលវិទ្យាល័យ

ដោយហេតុថា កម្ពុជាកំពុងតែខ្វះខាតសាស្ត្រាចារ្យ ដែលឆ្លងកាត់ការបណ្តុះបណ្តាលល្អត្រឹមត្រូវនោះ សកលវិទ្យាល័យទាំងឡាយ ត្រូវតែប្រើប្រាស់ធនធានមនុស្សដែលខ្លួនមានតិចតួចខ្សត់ខ្សោយនេះ អោយអស់លទ្ធភាព និង សមត្ថភាពតាមរយៈបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ដោយភ្ជាប់អ្នកសិក្សាទៅនឹងធនធានរៀនមានប្រយោជន៍នៅទូទាំងពិភពលោក ។ ក្រសួងអប់រំ យុវជន និង កីឡា នឹងជំរុញការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ នៅក្នុងដំណើរការបង្រៀន និង រៀន ការសិក្សាស្រាវជ្រាវ និង ការងាររដ្ឋបាល ដោយបង្កើតសមាគមគាំទ្រ (a cyber campus consortium) ហើយនិងភ្ជាប់សម្ព័ន្ធនេះ ទៅជាមួយនឹងសកលវិទ្យាល័យបណ្តុះបណ្តាលពីចម្ងាយ (virtual universities) នៅតាមបណ្តាប្រទេសផ្សេងៗទៀត ។ ក្រសួងក៏នឹងគាំទ្រជំរុញប្រែក្លាយសៀវភៅភាសាខ្មែរអោយទៅជាទិន្នន័យឌីហ្សីថល និង បកប្រែសៀវភៅបរទេសដែលមានប្រយោជន៍ខ្ពស់អោយទៅជាសៀវភៅភាសាខ្មែរដែរ ។

### ៣.២.៨. កិច្ចសហប្រតិបត្តិការ និង ការកសាងដៃគូ

ក). លើកកំពស់កិច្ចសហការជាមួយអង្គការជាតិ អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និង សប្បុរសជនទាំងនៅក្នុង និង ក្រៅប្រទេសដើម្បីជំរុញសន្ទុះអភិវឌ្ឍបច្ចេកវិទ្យា ព័ត៌មាន និង សាគមនាគមន៍ ក្នុងការអប់រំនៅកម្ពុជា ។

ខ). កសាងភាពដៃគូជាមួយសហគមន៍ស៊ីវិល និង ក្រុមហ៊ុនឯកជននៅក្នុង និង ក្រៅប្រទេស ដើម្បីចែករំលែកធនធានបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ សំដៅកាត់បន្ថយគំលាតឌីហ្សីថលនៅក្នុងតំបន់ ។

## ៤- ផែនការសកម្មភាព

ផ្អែកលើផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ២00៤-0៨ និង កម្មវិធីគាំទ្រវិស័យអប់រំនោះ រាល់ស្ថាប័នពាក់ព័ន្ធ និង ជាពិសេសក្រសួងនឹងត្រូវអភិវឌ្ឍផែនការសកម្មភាពប្រកដនិយមរៀងខ្លួន ដើម្បីបង្កលក្ខណៈអោយប្រទេសកម្ពុជាអាចប្រែក្លាយគោលនយោបាយ និង យុទ្ធសាស្ត្រអប់រំនេះ ទៅជាលទ្ធផលជាក់ស្តែងប្រកបដោយគុណភាព និង ធានាការអភិវឌ្ឍមួយប្រកបដោយនិរន្តរភាព នៅចំពោះមុខពិភពលោកដែលប្រែប្រួលយ៉ាងឆាប់រហ័សនេះ ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១ : ចំនួនសិស្សរៀនពេញម៉ោងនៅក្នុងប្រទេសកម្ពុជា[៣]

| | ចំនួនសិស្ស | ចំនួនសាលារៀន |
|---|---|---|
| មត្តេយ្យសិក្សា | ៧២,២២៤ | ១,២៣៨ |
| បឋមសិក្សា | ២,៧៤៧,០៨០ | ៦,០៦៣ |
| មធ្យមសិក្សាបឋមភូមិ | ៤៥៩,៩៨៦ | ៤៨៦ |
| មធ្យមសិក្សាទុតិយភូមិ | ១៥៣,៧៥៨ | ២១២ |

## ឧបសម្ព័ន្ធទី ២ : ផលធៀបគរុសិស្ស-កុំព្យូទ័រនៅកម្ពុជា ឆ្នាំ ២០០៤[៤]

| | |
|---|---|
| សាលាគរុកោសល្យខេត្ត-ក្រុង (បណ្តុះបណ្តាលគ្រូបឋមសិក្សា) | ៣៥:១ |
| មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ (បណ្តុះបណ្តាលគ្រូមធ្យមសិក្សាបឋមភូមិ) | ២៧:១ |
| វិទ្យាស្ថានជាតិអប់រំ (បណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ) | ១៨:១ |
| សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម | ២០:១ |

[៣] ប្រភព : មជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) នាយកដ្ឋានផែនការ (ក្រសួង អយក) ២០០៣-២០០៤

[៤] ប្រភព : នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ ក្រសួង អយក / អង្គការ UNESCO (២០០៤)

## ឧបសម្ព័ន្ធទី ៣ : ស្ថានភាពប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអេឡិចត្រូនិច និង ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបោះពុម្ព នៅក្នុងប្រទេសកម្ពុជា [៥]

| ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអេឡិចត្រូនិច | |
|---|---|
| **ទូរទស្សន៍** | |
| ស្ថានីយ៍ជាតិ (១ នៅភ្នំពេញ និង ១នៅខេត្ត) | ២ |
| ស្ថានីយ៍ក្នុងស្រុក (នៅភ្នំពេញ) | ៥ |
| ស្ថានីយ៍ទូរទស្សន៍ខ្សែកាប (នៅភ្នំពេញ) | ២ |
| ចំនួនទូរទស្សន៍ក្នុង ១000 នាក់ | ៨ * |
| **វិទ្យុ** | |
| ស្ថានីយ៍ជាតិ (AM និង FM) | ២ |
| ស្ថានីយ៍ក្នុងស្រុក (FM) | ១៣ |
| ចំនួនវិទ្យុក្នុង ១000 នាក់ | ១១៩* |
| **ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបោះពុម្ព** | |
| សារព័ត៌មានភាសាខ្មែរ | ១៣៥ |
| សារព័ត៌មានភាសាបរទេស | ៣៧ |
| ទស្សនាវដ្ដីភាសាខ្មែរ | ៤0 |
| ព្រឹត្តិបត្រផ្សេងៗ | ២១ |
| **កុំព្យូទ័រ** | |
| ចំនួនកុំព្យូទ័រក្នុង ១000 នាក់ | ១,៥* |
| អ្នកប្រើប្រាស់អ៊ិនធឺណែត | ៦ 000* |
| **ទូរស័ព្ទ** | |
| ចំនួនទូរស័ព្ទខ្សែក្នុង ១ 000 នាក់ | ២* |
| ចំនួនទូរស័ព្ទដៃ ក្នុង ១ 000 នាក់ | ១៧* |
| **អ៊ិនធឺណែត** | |
| អ្នកប្រើប្រាស់អ៊ិនធឺណែតក្នុង ១ 000នាក់ | ១0* |

[៥] ក្រសួងព័ត៌មាន CCI និង ICT/UNESCO 2002

* ស្ថិតិក្រុមទិន្នន័យ-ធនាគារពិភពលោកឆ្នាំ ២00៣

  

គោលនយោបាយនេះ កសាងឡើងដោយ ក្រសួង អប់រំ យុវជន និង កីឡា
ដោយបានជំនួយឧបត្ថម្ភហិរញ្ញវត្ថុពីមូលនិធិជប៉ុន (JFIT) និង
ជំនួយឧបត្ថម្ភបច្ចេកទេសពីអង្គការ យូណេស្កូ (UNESCO)

ក្រសួងអប់រំ យុវជន និង កីឡា

JFIT

UNESCO
PHNOM PENH